ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Aug-2012, 15:18
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៩៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារាវស្មី

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក ឡោ ជុនធី

លោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា
*(Mr. Ferdinand DJAMMEN NZEPA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយង៍ ដេស្មាឯល | បារាំង |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អ៊ុង ចុងហឿង (TCW-490) | ខ្មែរ |
| លោក ស្នួង ស៊ីគឿន (TCW-694) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុង ឆុំហឿង** (TCW-490)
សួរបន្តដោយលោក ម៉ែខល កាណាវាស ផ្ដើមពី៖ ....................ទំព័រ ៣
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី៖ ....................ទំព័រ ៥២

**ការសួរសំណួរទៅសាក្សី៖ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន** (TCW-694)
សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី៖ ....................ទំព័រ ៧២
សួរដោយលោក ហ្សាស្ដេី ប៉ៅ ផ្ដើមពី៖ ....................ទំព័រ ៨២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តនីតិវិធីសវនាការដោយស្តាប់សក្ខីកម្មសាក្សី អ៊ុង ចុងហៀង ហើយនិងអាចបន្តសាក្សីមួយទៀតប្រសិនបើពេលវេលាអំណោយផលដល់ការស្តាប់សក្ខីកម្មបន្ទាប់ គឺសាក្សី សួង ស៊ីគឿន។ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនហើយថា សាក្សីពីររូបនេះ អង្គជំនុំជម្រះរៀបចំធ្វើកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មរបស់គាត់ដោយឆ្លាស់គ្នា។

ហើយនៅចំពោះមុខ នៅព្រឹកនេះ គឺអង្គជំនុំជម្រះសម្រេចផ្តើមការ -- បន្តការតាំងសំណួរដេញដោលចំពោះសាក្សី អ៊ុង ចុងហៀង។ ដោយសារមូលហេតុគាត់រៀនរស់នៅឯប្រទេសក្រៅ នៅឯប្រទេសអឺរ៉ុបឯណោះ ហើយគាត់អស់ពេលវេលានឹងនៅប្រទេសកម្ពុជាទៀតហើយ។ ដូច្នេះ អង្គជំនុំជម្រះកែសម្រួលបន្តិច គឺស្តាប់សក្ខីកម្មលោក អ៊ុង ចុងហៀង មុននៅព្រឹកនេះ។

[០៩:០២:២៥]

ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ។ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធី ដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែកសាក្សីដែលផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ គឺសាក្សី អ៊ុង ចុងហៀង និងសាក្សី សួង ស៊ីគឿន មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:០៣:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី ជាមុនសិន។

អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត អែម សាវឿន គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរពេទ្យ -- នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពរបស់លោក អៀង សារី នៅព្រឹកមិញនេះបានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ពេលធ្វើចលនា នោមញឹក ឈឺខ្នង ឈឺចង្កេះ អស់កម្លាំង និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោម។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះ លោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែគាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ឲ្យលោកអៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី អ៊ុង ចុងហឿង ចូលមកកាន់បន្ទប់សវនាការ!

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៦:៣១]

**ប្រធានអង្គជំនុំ៖**

អរុណសួស្តី លោក អ៊ុង ចុងហឿង នៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោកតទៅទៀត ដែលនឹងបន្តការតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តី ដែលនៅពីរក្រុមទៀត គឺក្រុមមេធាវីការពារក្តីលោក អៀង សារី ហើយនិងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមរំឭកដល់សាក្សីថា សូមសាក្សីស្តាប់នូវសំណួរដែលសួរឲ្យបាន ហើយសូមកំហិតចម្លើយរបស់លោកត្រឹមវិសាលភាពសមស្របតបទៅនឹងសំណួរដែលសួរបានហើយ ចៀសវាងការធ្វើអត្ថាធិប្បាយវែង នាំឲ្យបាត់បង់ពេលវេលា ហើយម្យ៉ាងទៀត វាអាចនឹងប្រឈមនឹងបញ្ហាសម្ពាធខាងអារម្មណ៍របស់លោកផង។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:០៧:៤៨]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោក។ អរគុណលោក លោកស្រី ហើយនិងជម្រាបសួរអស់លោក លោកស្រី នៅក្នុងសាលសវនាការ ហើយនិងសាធារណជនទាំងអស់ ហើយជម្រាបសួរសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** យើងបានចាប់ផ្តើមពីចំណុចដែលយើងបានឈប់កាលពីមុន។ យើងបាននិយាយអំពីការពាក់ព័ន្ធរបស់លោក នៅក្នុងទីក្រុងប៉ារីស កាលដែលលោកជានិស្សិត ហើយបានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា។ ឥឡូវនេះ អនុលោមទៅតាមការបញ្ជាក់លោក ហើយខ្ញុំសូមយោងទៅរកឯកសារខ្មែរ 00832574 រហូតដល់ 75 ហើយខ្ញុំមានអត្ថបទភាសាអង់គ្លេស គឺថាទំព័រ៧៧ ហើយបារាំង ៨៦,៨៧ គឺនៅក្នុងសក្ខីកម្មរបស់លោកនៅថ្ងៃ -- ខែសីហា ឆ្នាំទី៧ (ស៊ីក) បាទ ខែសីហា ឆ្នាំទី៧ (ស៊ីក) នោះ គឺលោកនិយាយអំពីការពាក់ព័ន្ធជាមួយលោក អៀង សារី ហើយមានន័យថា ជាការផ្សះ

ផ្សាជាតិ ហើយនិងជាមិត្តនៅក្នុងនយោបាយ ដើម្បីមានសមាគមជាឯកភាព។ តើលោកនៅចាំដែរឬទេថាលោកបាននិយាយពីខ្លឹមសារទាំងអម្បាលម៉ាននេះ បាទ លោកសាក្សី?

[០៩:០៩:៣៥]

**លោក អុង ថុងហឿន៖**

**ឆ៖** បាទ ខ្ញុំបាននិយាយមែន។

**ស៖** បាទ នៅក្នុងការផ្ដល់សក្ខីកម្មរបស់លោក លោកបាននិយាយម្ដងហើយម្ដងទៀត អំពីចំណុច៥ ដែលគេបានលើកឡើងនៅក្នុងការបញ្ចាក់ជាទស្សនៈ ដែលលោកបានប្រាប់ឲ្យយើងដឹង ដែលយើងយល់ថា គេបានលើកទឹកចិត្តឲ្យលោកចូលរួបរួមជាតិ ដោយសារថា លោកយល់ថា សម្ដេចសីហនុ នៅក្នុងនោះ ហើយមានលោក អៀង សារី ហើយនិងអ្នកណាផ្សេងទៀត។ តើចំណុចទាំងប្រាំនោះលោក -- តើលោកពិតជាបាននិយាយអ៊ីចឹងដែរឬទេ? តើខ្ញុំសន្និដ្ឋានបែបនេះត្រឹមត្រូវទៅតាមសក្ខីកម្មរបស់លោកដែរឬទេ? ខ្ញុំយោងទៅលើសក្ខីកម្មរបស់លោកជាទូទៅលោកសាក្សី។ ដូច្នេះចម្លើយមិននៅក្នុងទំព័រនេះទេ។

**ឆ៖** ជារួម ខ្ញុំទទួលស្គាល់ថាខ្ញុំបាននិយាយ។

**ស៖** បាទ ឥឡូវនេះយើងត្រឡប់ទៅរកអ្វីដែលលោក ដេវីដ ឆេនដ៍ល័រ បានសរសេរអំពីលោកនៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា "សោកនាដកម្មក្នុងប្រវត្តិសាស្ត្រកម្ពុជា" ឯកសារ D108/50/1.175។ សូមអភ័យទោស ខ្ញុំមិនមានអត្ថបទបកប្រែទេ ប៉ុន្តែខ្ញុំយោងទៅរកអត្ថបទភាសាអង់គ្លេស ERN ជាភាសាអង់គ្លេសគឺ 00193373 ហើយខ្ញុំនឹងចូលទៅដល់ -- រហូតទៅដល់ 74 នៅខាងចុងលេខ ERN បាទ។

[០៩:១១:៣៤]

ផ្នែកមួយនោះបាននិយាយ ហើយមានឈ្មោះរបស់លោកនៅកន្លែងនោះ។ តើខ្ញុំអាចសន្និដ្ឋានបានដែរឬទេ នៅពេលមួយលោកបានជួបជាមួយ ដេវីដ ឆេនដ៍ល័រ ឬទេ? ហើយក្រោយពីការជួបជាមួយគាត់នោះ គាត់បានសរសេរនូវខ្លឹមសារមួយចំនួនអំពីលោក។ តើអ៊ីចឹងមែនឬទេ នៅក្នុងសៀវភៅគាត់នោះ? បាទ តើនេះជាការសន្និដ្ឋានត្រឹមត្រូវតាមគំនិតហ្នឹងឬទេ? ដូច្នេះ សំណួរនោះគឺថាមិនមែនស្ថិតនៅក្នុងទំព័រនោះទេ ខ្ញុំមិនទាន់បានយោងទៅរកៗទំព័រនោះទេ។ ខ្ញុំជា -- គ្រាន់តែសួរសំណួរសាមញ្ញជាមុន។ តើលោកបានជួប ឬមិនបានជួបលោក ដេវីដ ឆេនដ៍ល័រ ដែលគាត់សរសេរសៀវភៅរបស់គាត់ដែលមាន

ចំណងជើងថា "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" ដែលលោកបាននិយាយមួយផ្នែកជាមួយគាត់នោះ។ ជាពិសេស គឺគាត់បានសរសេរបី ឬបួនទំព័រពីបញ្ហានេះ។

**ឆ៖** ខ្ញុំជារូម ខ្ញុំបានជួបលោក ឆេនដ័ល័រ និងបានជួបអ្នក -- មនុស្សផ្សេងៗជាច្រើន។ ប៉ុន្តែខ្ញុំសូមបញ្ជាក់បន្តិច ខ្ញុំជាអ្នកសរសេរសៀវភៅ ខ្ញុំទទួលស្គាល់ជារូម ខ្ញុំមិនទទួលស្គាល់សៀវភៅដែលខ្ញុំសរសេរ ហើយខ្ញុំទទួលស្គាល់អត្ថបទដែលខ្ញុំចុះហត្ថលេខា។ ហើយបើចង់ -- លោកចង់ --លោកមេធាវីចង់សួរថា តើខ្ញុំឲ្យខ្ញុំមានធ្វើការវិនិច្ឆ័យពីនរណា សរសេរពីខ្ញុំ ខ្ញុំៗខ្លួន ខ្ញុំអត់ទទួល -- ខ្ញុំមិនអាចវិនិច្ឆ័យហត្ថលេខារបស់អ្នកដទៃដែលសរសេរពីខ្ញុំទេ។

[០៩:១៣:៣០]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់សួរសំណួរលោក តើលោកអាចឆ្លើយបានឬទេ តើលោកបានជួប ឬមិនបានជួបជាមួយសាស្ត្រាចារ្យ ឆេនដ័ល័រ នៅពេលដែលលោកបានសួរសំណួរមួយចំនួននិយាយពីការសរសេរសៀវភៅប្រវត្តិសាស្ត្រនៅពេលដែលលោកបានផ្តល់គំនិតជាមួយដែលមាន -- មានផ្នែកមួយដែលមានចំណងជើងថា "អ៊ុង ថុងហឿង" នេះជាឈ្មោះរបស់លោក តើលោកបានជួបគាត់ ឬមិនបានជួប ជាចម្លើយបាទ ឬទេបាទ?

**ឆ៖** ខ្ញុំបានជួបលោក ឆេនដ័ល័រ មែន។

**ស៖** ឥឡូវនេះ លោកបានជួប ដេវីដ ឆេនដ័ល័រ ហើយគាត់បានណែនាំលោក ហើយលោកបានផ្តល់គំនិតខ្លះទៅក្នុងសៀវភៅមួយនៅក្នុងផ្នែកនោះ តើក្នុងឱកាសណាមួយលោកចាត់ទុកសៀវភៅហ្នឹង ឬក៏លោកបានមើលសៀវភៅហ្នឹង អំពីអ្វីដែលលោក ដេវីដ ឆេដ័ល័រ សរសេរអំពីលោកដែរឬទេ អំពីគំនិតលោកដែរឬទេ និយាយពីសៀវភៅនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១៤:៤៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ អស់លោក លោកស្រីចៅក្រមជាទីគោរព សហភាគីទាំងអស់ជាទីគោរព។ លោកសាក្សី កាលពីមុននោះ សំណួរនេះត្រូវបានចោទមកលោកហើយ។ ហើយ

សំណួរមុនអម្បាញ់មិញនេះក៏អ៊ីចឹងដែរ។ ដូច្នេះ ខ្ញុំគិតថា មិនគួរណាសួរវែងឆ្ងាយទៅសាក្សីទៀតទេ ចំណុចដដែលនេះ -- សំណួរដដែលនេះ។ ហើយពីព្រោះថា គាត់នុំងបានឆ្លើយតបនឹងសំណួរនេះ ហើយទៅហើយ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំនឹងប្រឈមមុខដេញដោលគាត់អំពីសៀវភៅ ដេវីដ ឆេនដ៍ល័រ គាត់និយាយថា គាត់បានជួប ដេវីដ ឆេនដ៍ល័រ ហើយគាត់បាននិយាយជាមួយ ដេវីដ ឆេនដ៍ល័រ។ ខ្ញុំមិនបានសួរថា គាត់អានពីអ្វីដែល ដេវីដ ឆេនដ៍ល័រ សរសេរអ្វីគាត់បានអាន ឬមិនអាននោះទេ គឺថានេះជាសំណួរដែលត្រឹមត្រូវ ដែលខ្ញុំអាចសួរសំណួរនេះ ដើម្បីខ្ញុំសួរតទល់គាត់ទាក់ទងទៅនឹងឯកសារនេះបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៦:១២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់ មានមូលដ្ឋានត្រឹមត្រូវ ដោយសារជាសំណួរច្រំដែល។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីការពារក្តី លោក អៀង សារី នេះទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងចូលទៅដល់ខ្មែរ 0082568 (ស៊ីក), អង់គ្លេស --

**អ្នកបកប្រែ៖**

ពីអ្នកបកប្រែ លោកប្រធាន សូមអនុញ្ញាតឲ្យមេធាវីគាត់បន្ថយល្បឿន ពេលគាត់ហៅលេខ ERN អ្នកបកប្រែបកមិនទាន់ទេបាទ។ សូមឲ្យបញ្ជាក់ឡើងវិញបាទ។

[០៩:១៦:៥៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ហើយសូមឲ្យយឺតជាងនេះ ជាពិសេសលេខឯកសារលេខ ERN នេះសូមឲ្យយឺត ដើម្បីឲ្យអ្នកបកប្រែហ្នឹងអាចតាមទាន់។ អម្បាញ់មិញនេះ អ្នកបកប្រែតាម

មិនទាន់ទេ។ មិនអាចបកប្រែបានទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំយោងទៅរកប្រតិចារឹកថ្ងៃទី០៧ សីហា ខ្មែរ 00832528(ស៊ីក), អង់គ្លេសទំព័រ 70, បារាំងទំព័រ 78 ដល់ 89។ លោកនិយាយថា "ខ្ញុំបានដឹងអំពីហ្នឹងៗ នៅពេលដែលខ្ញុំសិក្សាស្រាវជ្រាវសរសេរសៀវភៅរបស់ខ្ញុំ"។ សំណួរ តើលោកបានធ្វើការសិក្សាស្រាវជ្រាវដើម្បីសរសេរសៀវភៅ បើលោកពិតជាបានសិក្សាស្រាវជ្រាវ តើលោកបានអានសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ ដែរឬទេជាទូទៅ?

[០៩:១៨:០៣]

**លោក អុង ថុងហឿង៖**

**ឆ៖** ខ្ញុំអត់បានអានសៀវភៅលោក ឆេនដ៍ល័រ ទេ។

**ស៖** បាទ ឥឡូវនេះ នៅក្នុងសៀវភៅរបស់គាត់ នៅពេលដែលគាត់សរសេរអំពីលោក គាត់និយាយថា -- ខ្ញុំយោងទៅរកទំព័រ ដែលនៅលើអេក្រង់ ហើយគឺ អង់គ្លេស 00193373 ដែលនិយាយនៅចំណុចនេះថា "អុង ថុងហឿង បានកើតនៅឆ្នាំ១៩៥៤ បានទទួលអាហារូបករណ៍រដ្ឋាភិបាលដើម្បីទៅសិក្សាឧត្តមសិក្សានៅប្រទេសបារាំង។ នៅពេលដែលគាត់អាយុ ២០ឆ្នាំ គាត់រស់នៅក្នុងប៉ារីស ក្នុងរយៈពេល ១១ឆ្នាំ ហើយក៏បានចូលទៅក្នុងវង់ នយោបាយឆ្វេងនិយម បន្ទាប់ពីមានការតស៊ូនិស្សិតនៅឆ្នាំមួយពាន់ប្រាំបួន -- បាទ នៅក្រោយពីរដ្ឋប្រហារនៅឆ្នាំ៧០ ក្រោយមក។ ហឿង គឺជាអ្នកមានសមានចិត្ត ជាអ្នកគាំទ្រដល់សហភាពនិស្សិតខ្មែរ ហើយគាត់ពេញចិត្តទៅលើសម្តេច សីហនុ ហើយនិងគាត់មានកំហឹងទៅសហរដ្ឋអាមេរិក ជាពិសេសដែលគាំទ្ររបប លន់ នល់។ កម្មវិធីនយោបាយសំខាន់នោះទំនងជាលោក ហឿង យល់ថា គឺជាការចាកចេញពីអតីតកម្ពុជាមួយទៅរកជីវិតថ្មីដ៏ល្អប្រសើរ"។

[០៩:១៩:២៨]

ឥឡូវនេះ គឺពីមុននោះ លោកបាននិយាយថា លោក ងាកទៅរកសម្តេច សីហនុ ប៉ុន្តែនៅទីនេះ គឺថាលោកមិនពេញចិត្តព្រះអង្គទេ។ ប៉ុន្តែគាត់ -- លោក ពេញចិត្តកម្មវិធីនយោបាយរបស់គំនិតនោះ ហើយលោកក៏បាននិយាយថា លោកស្ថិតនៅក្រោមការដឹកនាំរបស់លោក អៀង សារី តើខ្ញុំសង្ខេបប៉ុណ្ណឹងត្រឹមត្រូវតាមគំនិតរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំសូម -- ខ្ញុំបញ្ជាក់ឡើងវិញថា ខ្ញុំមិនអាចឆ្លើយនឹងអ្វីដែលអ្នកផ្សេងៗសរសេរពីខ្ញុំទេ។ ខ្ញុំទទួលឆ្លើយតែអ្វីសៀវភៅដែលខ្ញុំសរសេរផ្ទាល់ខ្លួនខ្ញុំ និងអត្ថបទ ឬក៏អ្វីៗដែលខ្ញុំបានចុះហត្ថលេខាដោយ

រូបខ្ញុំផ្ទាល់។ ហើយនេះឈរលើកិច្ចវត្តមានខ្ញុំនៅទីនេះ គឺឈរលើការពិសោធន និងរបស់ខ្ញុំផ្ទាល់។

[០៩:២០:៥១]

**ស៖** ឥឡូវនេះយើងមិនយោងទៅរកឯកសារនេះជាថ្មីម្តងទៀតទេ នៅទំព័រដដែលនេះ ទំព័របន្ទាប់គឺ 00193374។ ដេវីដ ឆេនដ៍ល័រ បានសរសេរផ្អែកតាមការសម្ភាសជាមួយលោក គឺថា "ការបណ្តុះបណ្តាលអំពីបញ្ញវន្តទាំងនោះ ហើយគាត់បានចូលទៅក្នុងនយោបាយបក្សបដិវត្តន៍"។ តើនេះគំនិតត្រឹមត្រូវដែរឬទេ ដែលថាលោកបាននិយាយគំនិតនេះជូនទៅ ដេវីដ ឆេនដ៍ល័រ នោះ?

**ឆ៖** ខ្ញុំសូមឆ្លើយម្តងទៀត ខ្ញុំមិនអាចធ្វើអត្ថាធិប្បាយ ពីព្រោះអ្នកសរសេរពីខ្ញុំច្រើនណាស់ ខ្ញុំមិនអាចធ្វើអត្ថាធិប្បាយពីអ្នកដទៃសរសេរពីខ្ញុំទេបាទ។

**ស៖** គាត់បន្តនិយាយថា៖ "ក្នុងឆ្នាំ១៩៧៦ គាត់ធ្វើការនៅៗប្រទេសកម្ពុជា ហើយគាត់ធ្វើការនៅតាខ្មៅ នៅជាយក្រុងភ្នំពេញ"។ តើនេះជាការបញ្ជាក់ត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយម្តងទៀត។ ខ្ញុំ -- ត្រឹមត្រូវ ឬមិនត្រឹមត្រូវ ខ្ញុំមិនធ្វើអត្ថាធិប្បាយពីអ្នកដទៃជាគោលការណ៍សរសេរពីខ្ញុំទេបាទ។ បើលោកចង់ដឹងច្បាស់ សូមអានសៀវភៅដែលខ្ញុំបានសរសេរ ឬអត្ថបទដែលខ្ញុំបានសរសេរ ហើយចុះហត្ថលេខាពីខ្លួនខ្ញុំផ្ទាល់។

[០៩:២២:៤៩]

**ស៖** នៅចំណុចចុងបញ្ចប់ យើងមើលឯកសារនេះសាស្ត្រាចារ្យ ឆេនដ៍ល័រ ដែលគាត់បានផ្តល់សក្ខីកម្ម ហើយគាត់ជាអ្នកជំនាញនៅក្នុងតុលាការនេះ កាលពីមុននោះគាត់បានសរសេរក្នុងសៀវភៅរបស់លោកថា៖ "លោកបានប្រាប់គាត់ គឺថាលក្ខខណ្ឌការងារនោះគឺធ្ងន់ធ្ងរ ប៉ុន្តែអាហារគឺគ្រប់គ្រាន់"។ តើលោកបានប្រាប់ចំណុចនេះទៅ ដេវីដ ឆេនដ៍ល័រ ទេនៅពេលដែលលោកបានផ្តល់សម្ភាសសម្រាប់គាត់សរសេរសៀវភៅនោះ?

**ឆ៖** ខ្ញុំឆ្លើយដដែល គឺថាបើលោកចង់ដឹងច្បាស់សូមមេត្តាអានសៀវភៅខ្ញុំ ស្រួលៗស្តាប់ជាង។ ខ្ញុំមិនដឹងថាលោកមានទិសដៅអីយកសៀវភៅ ដែលដទៃសរសេរពីខ្ញុំមកសួរ បើស្រួលមើលសៀវភៅខ្ញុំ ឬអត្ថបទខ្ញុំសរសេរទៅវាស្រួលពិភាក្សាគ្នាជាង។

[០៩:២៣:៤៣]

**ស៖** ឥឡូវនេះនៅពេលដែលលោកផ្តល់សក្ខីកម្ម ភាគីបានសួរលោកចំណុចមួយថាតើលោក អៀង សារី គាត់ពាក់ព័ន្ធទៅជាអ្នកជាតិនិយម ហើយនិងអ្នកស្នេហាជាតិ ដើម្បីបញ្ចុះបញ្ចូលឲ្យបញ្ញាជន

ឱ្យត្រឡប់មកកម្ពុជាដែរឬទេ? គឺប្រតិចារឹកថ្ងៃទី០៨ សីហា ទំព័រខ្មែរ ៥៣, អង់គ្លេស ៦៦ ហើយបារាំង ហុក -- បារាំង ៧២ ទំព័រ៧២ បាទ។ តើលោកនៅចាំថា ភាគី ឬក៏ចៅក្រមសួរលោកពីនេះទេ ហើយបានលោកឆ្លើយថា៖ "គាត់និយាយជាសំខាន់អំពីការស្នេហាជាតិ ជាតិនិយម ហើយម្ចាស់ការ ហើយឯករាជ្យ ហើយខ្លួនទីពឹងខ្លួន ហើយគាត់បានបញ្ជាក់ចំណុចមួយថា កម្ពុជាមិនមែនជារណបរបស់វៀតណាមទេ។ តើលោកនៅចាំទេ ថាលោកបាននិយាយបែបនេះក្នុងសក្ខីកម្មរបស់លោក កាលពីអាទិត្យមួយមុន ឬពីរមុននេះ?

**ឆ៖** សូមអរគុណលោកមេធាវីបានសួរសំណួរនេះ គឺថាខ្ញុំចាំច្បាស់សំណួរនេះ គឺ -- ហើយចាំច្បាស់ថាខ្ញុំបាននិយាយជារួមដូច្នេះមែន។ ហើយខ្ញុំសូមបញ្ជាក់ថា ចំពោះរូបខ្ញុំលោក អៀង សារី នេះ ហើយដែលនាំពួកយើងខ្ញុំ ណែនាំពួកយើងខ្ញុំទាំង ១.៧០០នាក់ មកពីបរទេស។

[០៩:២៥:១៧]

**ស៖** ដូច្នេះ ខ្ញុំចង់ឱ្យលោកបញ្ជាក់ឱ្យច្បាស់ គឺថាមុនពេលដែលលោក អៀង សារី មកជួប គឺថាក្នុងឆ្នាំ១៩៦៨ នៅពេលដែលលោកបាននិយាយជាមួយ ដេវីដ ឆេនដ៏ល័រ លោកបានពាក់ព័ន្ធជាមួយនឹងចលនាឆ្វេងនិយម ហើយពីរសប្តាហ៍មុនគឺថា ឆ្នាំ១៩៧០ ជាមួយរដ្ឋាភិបាល លន់ នល់ នោះ ដែលគេធ្វើរដ្ឋប្រហារហ្នឹង អៀង សារី គឺមិនពាក់ព័ន្ធអ្វីនៅក្នុងរឿងហ្នឹងទេ។ តើអ៊ីចឹងឬទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរហ្នឹងបាទ។ សូមបញ្ជាក់ឡើងវិញ។

**ស៖** បាទ តាមសម្តីរបស់ ដេវីដ ឆេនដ៏ល័រ ដែលបានសម្ភាសលោក ហើយលោកបានចាប់ផ្តើមចូលពាក់ព័ន្ធនៅក្នុងនយោបាយឆ្វេងនិយម នៅដើមឆ្នាំ១៩៦៨ នៅពេលដែលមានការបះបោរមួយ គឺចលនាមួយនៅប៉ារីស។ តើលោកនៅចាំទេចលនាហ្នឹងបាទ? ហើយ នេះហើយគឺជាចលនា ដែលនាំឱ្យលោកចូលទៅនយោបាយខាងឆ្វេងនិយមនោះ។

**ឆ៖** ខ្ញុំជារួមទៅ ខ្ញុំបាន -- ខ្ញុំដែលបញ្ជាក់ឡើងវិញ គឺថា ខ្ញុំមិនឆ្លើយអ្វីដែលអ្នកដទៃសរសេរពីខ្ញុំទេ។ ខ្ញុំមិនឱ្យតម្លៃថាត្រូវ ឬខុសអីទេ គឺថាគឺសិទ្ធិអ្នកនិពន្ធ គេមានសិទ្ធិសរសេរពីខ្ញុំគ្រប់រូប ហើយខ្ញុំទទួលស្គាល់អ្វី ដែលខ្ញុំសរសេរផ្ទាល់ខ្លួន ខ្លួនឯង។

[០៩:២៧:១១]

**ស៖** មានសំណួរដែលគេសួរលោកមួយ នៅថ្ងៃទី០៧ ខែសីហា ក្នុងសវនាការនេះ អំពីនៅពេលដែលអ្នកស្នេហាជាតិត្រឡប់មកកម្ពុជា នៅទំព័រខ្មែរគឺ 00832578, អង់គ្លេសទំព័រ ៨២, បារាំង ៩១។

លោកនិយាយថា "នៅថ្ងៃមួយគឺថា អារម្មណ៍របស់កម្ពុជា គឺយើងមិនចង់រស់នៅ នៅបរទេសនោះទេ យើងចង់ត្រឡប់មកស្លាប់នៅក្នុងប្រទេសកំណើតរបស់ខ្លួន"។ បន្ទាប់មក លោកនិយាយតទៅទៀតថា "ខ្ញុំមិនដែលចង់ -- មិនចង់បន្តរស់នៅរហូតដល់ខ្ញុំស្លាប់នៅបរទេសនោះទេ"។ ដូច្នេះ ខ្ញុំសូមពិភាក្សាជាមួយលោកពីចំណុចនេះ លោកបានចេញទៅរៀនអាហារូបករណ៍ នៅប្រទេសបារាំង។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំនិយាយពី -- ខ្ញុំបានធ្វើអត្ថាធិប្បាយមែន។ ពីមនោសញ្ចេតនារបស់ខ្មែរយើងជំនាន់នោះ គឺស្រឡាញ់ជាតិ ចង់ត្រឡប់មករស់នៅក្នុងមាតុភូមិរបស់ខ្លួនវិញ។ ហ្នឹង ខ្ញុំបាននិយាយមែនបាទ។

**ស៖** សំណួរ ខ្ញុំសួរឡើងវិញគឺថា យើងនឹងទៅមួយជំហានម្តង។ លោកបានស្ម័គ្រចិត្តទៅទីក្រុងប៉ារីស គឺទទួលអាហារូបករណ៍ ដើម្បីទៅសិក្សា។ តើត្រូវឬទេ?

**ឆ៖** បញ្ហាទាំងអស់នេះ ខ្ញុំមិនបាន -- ខ្ញុំសូមអត់ឆ្លើយទេបាទ ជាបញ្ហាដែលមិន -- គ្មានអ្វីទាក់ទងនឹងបញ្ហាដែលខ្ញុំមក មានវត្តមាននៅទីនេះ។

**ស៖** តើអ្វីរារាំងលោក ដោយលោកមិនៗបានទទួលសញ្ញាបត្រសាកលវិទ្យាល័យ។ កាលពីសប្តាហ៍មុនលោក -- តើអ្វីដែលអាចរារាំងមិនឱ្យលោកត្រឡប់មកកម្ពុជា នៅក្នុងឆ្នាំ១៩៦៨, ៦៩, ៧០, ៧១, ៧២, ៧៣, ៧៤, និង ៧៥? តើអ្វីជាកត្តារារាំង ដែលមិនឱ្យលោកត្រឡប់មកកម្ពុជាវិញនោះក្រោយពីបញ្ចប់អាហារូបករណ៍ហើយនោះបាទ?

[០៩:២៩:៤៧]

**ឆ៖** លោកចេះតែជីកពីបញ្ហាកកូរកកាយ ដែលលោកបំភ្លៃពីបញ្ហាផ្ទាល់ខ្លួន ប៉ុន្តែខ្ញុំមិនយកបញ្ហាអស់នេះជាបញ្ហា ដែលពាក់ព័ន្ធនឹងវត្តមានរបស់ខ្ញុំនៅទីនេះទេ។

**ស៖** ខ្ញុំផ្អែកការសំណួររបស់ខ្ញុំ គឺផ្អែកលើចម្លើយរបស់លោកបានឆ្លើយ ហើយផ្អែកទៅលើអ្វីដែលចង់ឱ្យអង្គជំនុំជម្រះជឿថា ថាតើស្នេហាជាតិ ជាតិនិយម ជាអ្នក កត្តាជំរុញឱ្យលោកត្រឡប់មកវិញ ហើយការលោកទទួលស្គាល់នៅទីនេះ លោកចង់ត្រឡប់មកវិញមកកម្ពុជា ហើយលោកមិនចង់ស្លាប់នៅក្នុងបរទេសនោះទេ។ ហើយខ្ញុំចង់លើកចំណុចនេះគឺថា ក្នុងរយៈពេល១០ -- ១១ឆ្នាំ មិនមានអ្វីរារាំងមិនឱ្យលោកត្រឡប់មកវិញទេ ដែលលោកចប់ការសិក្សាហើយ។ សូមឆ្លើយសំណួរនេះមកខ្ញុំបាទ។

**ឆ៖** នៅៗពីមុនគឺខ្ញុំមិនទាន់ -- កាលៗជំទាន់នោះ ខ្ញុំមិនគ្មានទិសដៅត្រឡប់មកប្រទេសវិញ ដោយសារបញ្ហាផ្ទាល់ខ្លួនផ្សេងៗ ហើយដល់ ដល់ខ្ញុំមានជំនឿលើការណែនាំរបស់លោក អៀង សារី

យើងខ្ញុំខ្មែរទាំងអស់គ្នាក៏ត្រឡប់មកស្រុកទាំងអស់គ្នា ភាគច្រើនបាទ។ ហើយក្នុង -- មិនមែនតែខ្ញុំម្នាក់ទេ គឺមានខ្មែរច្រើនណាស់ដែល ដោយសភាពការណ៍ក្នុងប្រទេសផ្សេង -- ពេលនោះមានលក្ខណៈផ្សេងៗ មិនអាចអនុញ្ញាតឲ្យយើងខ្ញុំមកៗកាន់ប្រទេសកម្ពុជាវិញ។ នេះជាការកន្លងទៅហើយ ដែលជាឆន្ទៈរបស់យើងពេលនោះ។

[០៩:៣២:០៧]

**ស៖** លោកបាននិយាយថា លោកបានជួបលោក អៀង សារី ពីរឬបីដងនៅពេលដែលគាត់នៅទីក្រុងប៉ារីស។ ប៉ុន្តែខ្ញុំមិនច្បាស់ទេ ថាតើលោកបានជួបគាត់ដោយផ្ទាល់ ហើយបានជជែកផ្ទាល់ជាមួយគាត់នោះទេបាទ។ តើលោកអាចប្រាប់ខ្ញុំបានទេពីការនេះ?

**ឆ៖** បាទ ខ្ញុំមិនបានជួបនិយាយគាត់ផ្ទាល់ៗទេ គឺបានជួបជាមួយខ្មែរផ្សេងទៀត ដែលទៅជួបគាត់ពេលអង្គប្រជុំ។

**ស៖** ចុះអំពីសម្តេច សីហនុ នៅពេលដែលព្រះអង្គនៅបរទេសនោះ យើងដឹងថាប្រហែលជាឱកាសមួយលោកបានទៅចូលគាល់ព្រះអង្គនៅប៉ុយការ៉េសៗ។ តើលោកមានឱកាសដើម្បីសំណេះសំណាលជាមួយព្រះអង្គដែរឬទេ? ឬក៏លោកបានជួបជាមួយព្រះអង្គ ហើយបានស្តាប់អ្វីព្រះអង្គមានព្រះឱង្ការទេនៅកាលនោះ?

**ឆ៖** បាទ ខ្ញុំបានធ្វើសវនាការជាមួយព្រះអង្គ ក្នុងក្របខ័ណ្ឌដែលព្រះអង្គទទួលខ្មែរនៅបរទេសផ្សេងទៀត។

[០៩:៣៣:៣៨]

**ស៖** ហើយលោកអាចជម្រាបខ្ញុំថា សម្តេច សីហនុ បានមានព្រះបន្ទូលអ្វីពិតប្រាកដនោះ ពេលដែលលោកបានជួបគាត់? ហើយក្នុង -- តើព្រះអង្គមានបន្ទូលនៅពេលនោះក្នុងឋានៈជាអ្វីដែរ?

**ឆ៖** យើងបានជួបព្រះអង្គពេលនោះ ក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋស្របច្បាប់នៃប្រទេសកម្ពុជា ហើយព្រះអង្គបានរាយការណ៍ពីការដែលព្រះអង្គបានជួប ធ្វើទស្សនកិច្ចជួបប្រមុខរដ្ឋផ្សេងៗ នៅអឺរ៉ុប និងនៅដូចជាជួបលោក ទីតូ ឬក៏អ្នកប្រមុខរដ្ឋផ្សេងទៀត ដែលខ្ញុំអត់ចាំទេ។

**ស៖** ដូច្នេះ នេះមានន័យថានៅមុនរដ្ឋប្រហារ មុនឆ្នាំ១៩៧០ ដែលថា ព្រះអង្គក្នុងពេលនោះក្នុងឋានៈជាប្រមុខរដ្ឋស្របច្បាប់ គឺលោកបានជួបព្រះអង្គនៅមុនឆ្នាំ១៩៧០ មិនអ៊ីចឹងមែនទេ?

**ឆ៖** ទេ។ ខ្ញុំនិយាយថាខ្ញុំជួបព្រះអង្គក្នុងឆ្នាំ -- ក្រោយឆ្នាំ១៩៧០។ កាលនោះព្រះអង្គជាប្រមុខ

ស្របច្បាប់ ខ្ញុំឈរលើដោយសារ អង្គការសហប្រជាជាតិទទួលស្គាល់ព្រះអង្គជាប្រមុខរដ្ឋស្របច្បាប់នៃប្រទេសកម្ពុជា។

**ស៖** តើនៅពេលនោះ ព្រះអង្គជាផ្នែកមួយនៃហ្វ៊ុង នៃរណសិរ្សរួបរួមជាតិកម្ពុជា ឬក៏រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែរឬទេ?

**ឆ៖** សូមគោរពលោកមេធាវី សំណួរនេះខ្ញុំបានឆ្លើយហើយ។ ខ្ញុំបានបញ្ជាក់ទៀត គឺសម្តេចសីហនុនេះហើយជាៗ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ហើយជាប្រមុខរដ្ឋនៃរាជរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា។

[០៩:៣៦:០០]

**ស៖** ឥឡូវនេះ គឺថាលោកបានបញ្ជាក់ចំណុចនោះ តើនៅពេលនោះព្រះអង្គមានព្រះបន្ទូលទៅប្រជាជនកម្ពុជានៅក្រៅប្រទេស ដើម្បីឲ្យជួយព្រះអង្គហ្នឹង ដើម្បីឲ្យជួយទម្លាក់រដ្ឋាភិបាលដែលទម្លាក់ព្រះអង្គនោះដែរឬទេ?

**ឆ៖** បាទ ព្រះអង្គបាន -- នេះជាកម្មវិធី ជាគោលការណ៍ដែលព្រះអង្គបាន តែងតែបាននិយាយជាទូទៅ ប៉ុន្តែខ្ញុំមិនដឹងជាព្រះអង្គនិយាយក្នុងឱកាសណា ប៉ុន្តែមានបន្ទូលឱកាសណាទេ ប៉ុន្តែទិសដៅព្រះអង្គគឺថា ចង់ៗរួមចំណែកដើម្បីៗ ប្រាប់ទៅប្រជារាស្ត្រខ្មែរទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេសឲ្យរួបរួមគ្នាដើម្បីៗធ្វើ ធ្វើការតស៊ូប្រឆាំងនឹងរបបដែលធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ។

**ស៖** បាទ ខ្ញុំសូមរៀបឃ្លានេះឡើងវិញ ថាតើគាត់មានអំពាវនាវនិយាយអំពីការស្នេហាជាតិអំពីជាតិនិយមទៅដល់និស្សិតទាំងអស់ ដើម្បីជួយទៅដល់ចលនាតស៊ូប្រឆាំងជាមួយនឹងរដ្ឋាភិបាល លន់ នល់ ដែរឬទេ?

**ឆ៖** ខ្ញុំជឿថាមែន។ អានេះ គឺជា តាមមើលមិនបាកទេ គឺថាឯកសារ វាមាននៅគ្រប់។ គឺឯកសារ គេអាចស្រាវជ្រាវ ឃើញពេលនោះព្រះអង្គបានសរសេរ និងមានអំពាវនាវជាច្រើន ហើយប្រមុខរដ្ឋ អ្នកដឹកនាំផ្សេងទៀត ដូចជាលោក អៀង សារី ជាដើមក៏បានអំពាវនាវដូច្នេះដែរ។

[០៩:៣៨:១០]

**ស៖** សូមអរគុណលោក។ តើលោកដែលមានឱកាស ដែលលោកមានវត្តមាននៅក្នុងកិច្ចប្រជុំរវាងលោក អៀង សារី ជាមួយនឹងសម្តេច សីហនុ ដែរឬទេ?

**ឆ៖** សូមសួរម្តងទៀតបាទ។

**ស៖** តើលោកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំណាមួយរវាងសម្តេច សីហនុ ជាមួយនឹង អៀង សារី ដែលនិយាយបញ្ហាណាមួយនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំដែលៗបានចូលរួម។ ប៉ុន្តែក្នុងពេលចូលរួមជាមួយព្រះករុណា ខ្ញុំមិនដែល -- មានតែព្រះករុណា ព្រះអង្គមានបន្ទូលម្នាក់ឯង។ លោក អៀង សារី តែពេលណាមានវត្តមានព្រះករុណា ខ្ញុំមិនបានចាំថា លោកមានធ្វើការចាប់អារម្មណ៍អ្វីទេ។

**ស៖** ដូច្នេះ ខ្ញុំយល់ថា សំណួររបស់ខ្ញុំ។ ឥឡូវខ្ញុំសូមសួរសំណួរតទៅទៀត។ ថាតើលោកដែលមានឱកាសមានវត្តមានដែរឬទេ នៅពេលដែលលោក អៀង សារី និងសម្តេច សីហនុ មានការពិភាក្សាអ្វីមួយនៅក្នុងចំណោមពួកគាត់ទាំងពីរនេះ?

**ឆ៖** បាទ ខ្ញុំអត់មានទេ។

[០៩:៣៩:៥២]

**ស៖** នៅក្នុងសក្ខីកម្មរបស់លោក ខែសីហា ទី០៩ ប៉ុន្មានថ្ងៃមុននេះនៅឆ្នាំ២០១២ ដែលមាន ERN ជាភាសាខ្មែរ 008332930, ERN -- នៅភាសាអង់គ្លេស ទំព័រ១៤, បារាំង ទំព័រ១៥។ លោកត្រូវបានសួរថា អំពីអតីតកាលថា អៀង សារី មានឥទ្ធិពលយ៉ាងខ្លាំង នៅពេលដែលសម្តេច សីហនុ ចង់ឲ្យធ្វើអ្វីមួយនោះ ក៏ប៉ុន្តែបើអ្វីដែលត្រូវបាន អៀង សារី ជំទាស់នោះ គឺមិនអាចធ្វើបានទេ។ គឺនៅក្នុងឯកសារ E3/97។ ហើយបន្ទាប់មក លោកនិយាយបន្តទៅទៀត នៅពេលដែលសួរថា តើលោកដឹងដោយរបៀបណា? លោក អៀង សារី តែងតែ -- លោក អៀង សារី គឺគេស្គាល់គាត់ជាច្រើនដោយសារគាត់តំណាងទៅឲ្យចលនានេះ។ ហើយមានមនុស្សមួយចំនួន គឺថាដើរតាមគាត់ហ្នឹង ទាំងងងឹតងងុលនោះ។ ខ្ញុំសួរដោយឲ្យបានច្បាស់ថាដូច្នេះ តើលោកអាចជម្រាបបានទេ លោកដែលមាននិយាយទល់មុខគ្នាជាមួយ អៀង សារី ទេ? ពីព្រោះថា លោកបានផ្តល់សក្ខីកម្មថា លោកបាននិយាយជាមួយ -- ថា អៀង សារី បាននិយាយចំណុចនេះ នៅពេលដែលលោកមានវត្តមាននៅទីនោះដែរ?

[០៩:៤១:៥០]

**ឆ៖** ខ្ញុំនិយាយសរុបឡើងវិញ គឺថាបញ្ហានេះ សូមលោកមេធាវីជ្រាប គឺថាបើសិនជាយើងតាមដានបញ្ហាខ្មែរ ចលនាខ្មែរនៅបរទេស គឺបញ្ហាខ្មែរបរទេស គឺៗដល់នៅបរទេស គឺលោក អៀង សារី គាត់មានៗខ្សែររយៈរបស់គាត់ធ្វើការងារ។ គឺថាមានអ្នកស្គាល់គាត់ ហើយបន្ទាប់ពី វង់ -- ពួកធ្វើការគាត់ភាគីច្រើន គឺអ្នកនៅវង់ម៉ាក្ស-ឡេនីនជាមួយគ្នា ហើយពួកវ៉ាំង -- ពួកវង់ម៉ាក្ស-ឡេនីន នេះហើយ

ជាអតីតអ្នកធ្វើការ អ្នកស្គាល់គាត់។ ហើយជាស្នូល ហៅថា ជាស្នូល នៃ -- សម្រាប់ធ្វើការជាស៊ីជម្រៅ ខ្មែរនៅបរទេសទាំងអស់។ ដូច្នេះ ខ្ញុំៗដែលធ្វើ ខ្ញុំបាននិយាយ គឺឈរលើគោលការណ៍ហ្នឹង។ ហើយ តាមៗយោបល់ខ្ញុំ គឺថាការនេះជាការទទួលស្គាល់របស់អ្នកសង្កេតការណ៍រួមទាំងអស់ ដែលៗបាន សិក្សាពីបញ្ហាខ្មែរនៅបរទេស។

**ស៖** ប្រសិនជាលោកអាចឆ្លើយនឹងសំណួរខ្ញុំបាន។ សំណួររបស់ខ្ញុំ គឺដូច្នេះ។ តើលោកនៅចាំ សំណួរខ្ញុំបានទេ? លោកសាក្សី ខ្ញុំបានសួរសំណួរច្បាស់លាស់ណាស់ទៅលោក នៅពេលដែលលោកមាន វត្តមាននោះ លោកថា លោកមានវត្តមាននៅក្នុងកិច្ចប្រជុំមួយ គឺធ្វើឡើងរវាងសម្តេចព្រះ សីហនុ និងលោក អៀង សារី។ តើលោកដែលឮលោក អៀង សារី និយាយអំពីអ្វីដែរឬក៏អត់? ដូច្នេះ ខ្ញុំចង់បាន ចម្លើយរបស់លោក បើថា បាទ ឬក៏ដឹង ឬក៏មិនដឹង?

[០៩:៤៤:១៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលអាន់ឆ្លើយតប។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ បាទ សំណួរពីដំបូងនោះ គឺចង់ថា តើអៀង សារី បាន និយាយពាក្យពេចន៍ទាំងអស់នេះ ដែរឬក៏អត់? ក៏ប៉ុន្តែមិនបានលើកឡើងអំពីការដែលថា តើពេលនិយាយ នោះ មានវត្តមាន សីហនុ ឬក៏អត់ទេ? ហើយសំណួរទី២ គឺបែបមកកម្រិតសំណួរនេះ មកត្រឹមតែថា សាក្សីមានវត្តមាន ពេលដែលប្រជុំរវាង សីហនុ ហើយនិង អៀង សារី។ ដូច្នេះ វាហាក់ដូចជាមាន កម្រិត រឹតត្បិតសំណួរនេះ ហើយមកឲ្យសាក្សីឆ្លើយកម្រិតថា បានចូលរួមទេ ឬក៏មិនបានចូលរួមទេ? ហើយដូចបានឮសម្តីទាំងអស់នេះឬទេ? ហើយ ខ្ញុំសូមឲ្យសំណួរ ចោទសំណួរនេះឡើងវិញ ឲ្យបើក សំណួរនេះឲ្យទូលាយបន្តិច។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** លោកប្រធាន គឺៗប្រហែលដោយសារតែការបកប្រែ។ ដូច្នេះ ខ្ញុំអាចកំណត់សំណួរ -- តាំងសំណួរនេះឡើងវិញ។ ខ្ញុំមិនមែនគ្រាន់តែចង់ដឹងថា តើគាត់មានវត្តមាននៅក្នុងកិច្ចប្រជុំ ឬអត់ គាត់ធ្វើ គាត់ផ្តល់ចម្លើយមិនច្បាស់លាស់។ ខ្ញុំសួរគាត់ថា តើគាត់មានវត្តមាននៅពេលណាមួយដែរឬទេ?

ឬក៏វត្តមានដែលៗជាមួយតែ អៀង សារី ឬក៏គាត់មានវត្តមាននៅពេលដែលសម្តេចមានការជំនួបជាមួយនឹងអៀង សារី ។ នេះជាសំណួររបស់ខ្ញុំ លោកអាចឆ្លើយបានទេ?

[០៩:៤៦:២២]

**លោក អុង ធុងហឿន៖**

**ឆ៖** ខ្ញុំបាននិយាយហើយថា ខ្ញុំមិនដែល -- ខ្ញុំដែលចូលរួមអង្គប្រជុំដែលមានវត្តមានសម្តេចព្រះនរោត្តម សីហនុ និងលោក អៀង សារី ចូលរួមជាមួយគ្នា ប៉ុន្តែខ្ញុំមិនដែលបានចូលរួមប្រជុំពេលដែលលោកទាំងពីរពិភាក្សាគ្នាពីរឿងអ្វីមួយទេ។ ហើយពេលប្រជុំដែល -- ខ្ញុំនិយាយហើយនិយាយទៀតពេលប្រជុំដែលមានវត្តមានសម្តេច នរោត្តម សីហនុ ហើយមានវត្តមានលោក អៀង សារី នោះមានតែសម្តេច នរោត្តម សីហនុ ទេដែលគាត់ លោកៗបានធ្វើ លោកបានធ្វើឧទ្ទេសនាម។ ឯចំណែកលោក អៀង សារី ជាទូទៅ -- ខ្ញុំមិនដែលបានឮគាត់និយាយអ្វីពេលប្រជុំនោះទេ។

**ស៖** សូមអរគុណលោកសាក្សី។ សូមបន្តទៅប្រធានបទមួយផ្សេងទៀត។ នៅពេលដែលលោកបានមកដល់ប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ១៩៧៦ ខ្ញុំចាំថាកន្លែងទី១ ដែលលោកបានទៅគឺ ក-១៥ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[០៩:៤៧:៥៥]

**ស៖** ហើយតាមដែលខ្ញុំចាំសក្ខីកម្មរបស់លោកនោះគឺថា នៅក-១៥ គឺ កម្មសិទ្ធិមួយចំនួនដូចជាសៀវភៅជាដើមនេះ គឺត្រូវបានគេដកហូតយកអស់ទៅ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើគេយកតែ -- ដកហូតយកតែសៀវភៅប៊ិក ខ្មៅដៃ សៀវភៅកត់ត្រា កូនសៀវភៅកត់ត្រាដែរឬយ៉ាងម៉េច?

**ឆ៖** ជារួមគេយកវិទ្យុ គេយកអ្វីៗដែលឥតប្រយោជន៍ទាំងអស់ ហើយសៀវភៅមើលក៏គេយកដែរ។ ហើយសៀវភៅសរសេរក៏ៗ ខ្លះក៏គេយក ខ្លះក៏គេមិនយក។

**ស៖** តើលោកអាចឆ្លើយមកខ្ញុំដែរឬទេថា តើអ្នកណាដែលអនុញ្ញាតឱ្យរក្សាទុកកូនសៀវភៅសរសេរ អ្នកណាអាចគេយកដកទៅបាត់ ហើយតើអ្នកណាខ្លះអនុញ្ញាតឱ្យមានការកាន់កាប់កម្មសិទ្ធិ ឬទ្រព្យសម្បត្តិមួយចំនួន អ្នកណាដែលមិនត្រូវគេអនុញ្ញាតនោះ?

**ឆ៖** ខ្ញុំមិនបានដឹងទេ គ្រាន់ថាពេលគេមកដល់អ៊ីចឹងទៅ គេៗឲ្យ -- គេផែកវ៉ាលិសអ៊ីចឹងទៅ ហើយគេយករបស់មួយចំនួនទៅ ហើយមិនគេយកហ្នឹងវាឈរលើអី ឬក៏អ្នកណាឈរលើអីទេគឺថាគេ -- របស់អ្វីដែលគេយក គេយកទៅ ហើយរបស់អ្វីដែលគេមិនយក គេអត់យកទៅ អាហ្នឹងខ្ញុំមិនដឹងថាគេឈរលើអីទេបាទ។

[០៩:៥០:០១]

**ស៖** នៅពេលនោះ តើលោកដឹងទេថា អ្នកណាទទួលខុសត្រូវនៅក-១៥នោះ? អ្នកណាជាអ្នកទទួលនៅអង្គភាពនោះ?

**ឆ៖** មកដល់ភ្លាម ខ្ញុំមិនដឹងជាអ្នកណាទេ ប៉ុន្តែនៅបន្តិចទៅ គេដឹងថាអ្នកទទួលខុសត្រូវឈ្មោះភុំ។

**ស៖** អ៊ីចឹងគាត់ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តើ ភុំ ធ្វើការឲ្យអ្នកណា? អ្នកណាជាមេរបស់ ភុំ ទៀត?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ គ្រាន់ដឹងថាគាត់ជាតំណាងអង្គការ។

**ស៖** នៅក្នុងសៀវភៅរបស់លោក លោកបានធ្វើការសិក្សាស្រាវជ្រាវខ្លះ តាមចម្លើយរបស់លោក តាមការទទួលស្គាល់របស់លោកនោះ។ នៅក្នុងសៀវភៅគឺថា លោកសរសេរ ខ្ញុំអត់មានលេខជាភាសាខ្មែរទេ សូមអធ្យាស្រ័យ។ ប៉ុន្តែជាភាសា -- ERN ជាអង់គ្លេស 00785761, ERN បារាំង 00287929 ដែលលោកនិយាយថា "អតីតវិទ្យាស្ថានមិត្តភាពកម្ពុជា-សូវៀត គឺថា ត្រូវបានកែប្រែទៅជាអង្គភាពមួយសម្រាប់អ្នកមកពីបរទេស ដូចជាយើងខ្ញុំដែល គេហៅថា ក-១៥ គឺគេត្រូវបានរៀបចំបម្រុងទុកសម្រាប់ឲ្យបញ្ញវន្តស្នាក់នៅ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា"។ តើលោកនៅប្រកាន់អ្វីដែលលោកបានសរសេរនេះទេ?

[០៩:៥២:១៩]

**ឆ៖** បាទ ខ្ញុំបាន -- ខ្ញុំនៅប្រកាន់អ្វីដែលខ្ញុំបានសរសេរ។ អានេះដែល ខ្ញុំមកដល់ភ្លាមគឺខ្ញុំអត់បានដឹងទេ ប៉ុន្តែនៅពេលសរសេរសៀវភៅ ខ្ញុំដឹងថា នៅក្រោមការត្រួតត្រាផ្ទាល់របស់គណៈមជ្ឈិមនៅកិច្ចការនយោបាយរបស់គណបក្ស -- គណៈមជ្ឈិម អានេះខ្ញុំបានឮសួរគេនិយាយបាទ។

**ស៖** សូមអរគុណលោកសាក្សី។ អ្វីដែលខ្ញុំចង់ផ្តោតនេះ គឺៗគេបានស្នើសុំឲ្យរៀបចំអង្គភាពសម្រាប់ឲ្យបញ្ញវន្តទាំងអស់ស្នាក់នៅនោះ យ៉ាងហោចណាស់ជាភាសាអង់គ្លេសដែលនិយាយថា "មន្ទីរ

ក-៥ ក៏ដូចជាមន្ទីរផ្សេងៗទៀត គឺសម្រាប់បញ្ញវន្តស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ នេះគឺអ្វីដែលការស្រាវជ្រាវរបស់លោក ធ្វើឲ្យលោកឈានដល់ការសន្និដ្ឋានបែបនេះ តើអ៊ីចឹងមែនទេ?

[០៩:៥៣:៣០]

**ឆ៖** បាទ ខ្ញុំឮសួរគេនិយាយគ្រប់គ្នាអ៊ីចឹង ថាដែល ភុំ ហ្នឹងស្ថិតនៅក្រោម -- ដឹងគាត់ថ្នាក់គាត់ប៉ុន្មានទេ ប៉ុន្តែគាត់នៅក្រោមការត្រួតត្រា -- ទទួលខុសត្រូវរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ អានេះខ្ញុំដឹងក្រោយមកពេលខ្ញុំសរសេរសៀវភៅបាទ។

**ស៖** ហើយបន្ទាប់មកលោកក៏បានកំណត់និយមន័យថា អ្នកណាជាប្រធានក្តោបក្តាប់បញ្ញវន្ត គឺ -- បញ្ញវន្តគេមានក្រុមនិស្សិត វិស្វករ មន្ត្រីរាជការស៊ីវិល ក៏ដូចជាមន្ត្រីរាជការនៃរបបចាស់។ នេះ គឺអ្វីដែលលោកបានធ្វើសេចក្តីសន្និដ្ឋានក្រោយការសិក្សាស្រាវជ្រាវរបស់លោក។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

**ស៖** ដូច្នេះបើសិនណាជាខ្ញុំយល់មិនច្រឡំទេ គឺបន្ទាប់ពីក-១៥ ទៅលោកបានទៅនៅឯបឹងត្របែក ឬក៏លោកទៅនៅកន្លែងផ្សេង? តើអ៊ីចឹងទេ?

**ឆ៖** បាទ បន្ទាប់ពីក-១៥ ខ្ញុំបាទបានទៅ ដ-២។

**ស៖** តាមរយៈសក្ខីកម្មរបស់លោក គឺលោកបានទៅនៅបឹងត្របែកនៅក្នុងឆ្នាំ១៩៧៨ ប្រហែលជាក្នុងខែតុលា ឬក្នុងខែវិច្ឆិកា ពីព្រោះថាគឺលោកបានទៅទីនោះពីរបីខែមុនភ្នំពេញដួលរលំទៅ។ បើសិនណាជាលោកទៅមុននោះ តើលោកអាចប្រាប់ខ្ញុំបានទេ ថាវាក្នុងពេលណា? ក្នុងអំឡុងពេលណា? ក្នុងឆ្នាំណាដែរ?

[០៩:៥៥:៤៤]

**ឆ៖** ជារួមដូចខ្ញុំបានទៅបឹងត្របែកហ្នឹងពីរហ្នឹង។ ម្តងមុនៗ ខ្ញុំទៅដីក្រហម។ ម្តងទៀតនៅដូចមុនក្នុងឆ្នាំ១៩៧៨ ដូចៗលោកមេធាវីបាននិយាយអ៊ីចឹង។

**ស៖** លើកទី១ ដែលលោកទៅទីនោះ គឺនៅក្នុងឆ្នាំ១៩៧៦ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ដូច្នេះ ចម្លើយដែលលោកបានផ្តល់នៅទីនេះ គឺអង្គភាពផ្សេងៗទៀតដែលទុកសម្រាប់បញ្ញវន្តគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា។ តើខ្ញុំអាចធ្វើការសន្និដ្ឋាន

ដោយត្រឹមត្រូវតាមរយៈសំណេររបស់លោកបានទេថា នៅពេលដែលលោកនៅបឹងត្របែកជាលើកទី១ គឺនៅពេលនោះវាស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អ៊ីចឹងទេ?

[០៩:៥៧:០៩]

**ផ៖** នេះជាការដែលខ្ញុំបានឮសួរ ហើយខ្ញុំបានធ្វើការស្រាវជ្រាវផ្ទាល់ខ្លួនបាទ។ ខ្ញុំបាន -- ខ្ញុំយល់ដូច្នេះមែន។

**ស៖** នៅពេលដែលលោកៗ និយាយសន្និដ្ឋានខ្ញុំសូមសង្កត់បន្តិច។ ខ្ញុំមិនចង់ឲ្យលោកសន្និដ្ឋាន គឺខ្ញុំចង់ឲ្យលោកសំអាងទៅលើអ្វីដែលលោកសរសេរនៅក្នុងសៀវភៅរបស់លោកនេះ។ ដូច្នេះ លោកសូមបញ្ជាក់ឲ្យច្បាស់លាស់ គឺសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់ កុំស្មាន។

**ផ៖** បាទ ខ្ញុំបានសរសេរដូច្នេះមែន។

**ស៖** ខ្ញុំមិនបានសួរថា តើលោកបានសរសេរ ឬក៏អត់នោះទេ? ខ្ញុំសួរថា ឲ្យលោកបញ្ជាក់ថា តាមការស្រាវជ្រាវរបស់លោក ឈានដល់ការសរសេរសៀវភៅនេះ លោកនិយាយថា គឺអ្វីដែលលោកសរសេរនេះ គឺវាត្រឹមត្រូវពិតប្រាកដ ដែលថាមន្ទីរផ្សេងៗទៀត ក៏សម្រាប់ដាក់បញ្ញវន្តស្ថិតនៅក្រោមការគ្រប់គ្របរបស់មជ្ឈិមបក្ស -- គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាតែម្តងនៅក្នុងឆ្នាំ១៩៧៦។ ដូច្នេះលោកបញ្ជាក់បានទេ តាមការស្រាវជ្រាវរបស់លោក គឺនៅឆ្នាំ១៩៧៦ បឹងត្របែក គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា តាមការស្រាវជ្រាវរបស់លោក។ តើលោកអាចបញ្ជាក់បានទេ?

[០៩:៥៨:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតយើង -- ខាងការពារក្តីនោះឈរមូលដ្ឋានលើសៀវភៅដែលសរសេរដោយសាក្សីនេះ នៅក្នុងចោទសំណួរយោងទៅលើសាក្សីនោះ គឺថាឲ្យគាត់បែងចែកឲ្យច្បាស់ពីអ្វីដែលគាត់ឆ្លងកាត់នៅសម័យនោះ និងអ្វីដែលគាត់បានស្រាវជ្រាវនៅពេលក្រោយមក។ ហើយយើងមិនបានចោទសំណួរប្រភេទដែលខាងការពារក្តីសួរនោះទេ គឺថាគេ -- ឥឡូវនេះកំពុងតែឲ្យសាក្សីនេះ

តាំងខ្លួនជាអ្នកជំនាញហើយ ហើយសាក្សីនេះគាត់មិនមែនជាអ្នកជំនាញទេ គាត់គ្រាន់តែជាសាក្សី។ អ៊ីចឹងសូមឲ្យចៀសវាងសំណួរបែបនេះលោកប្រធាន។

[០៩:៥៩:៥១]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេបទៅសហព្រះរាជអាជ្ញា។

នៅពេលដែលសហព្រះរាជអាជ្ញាបង្ហាញខ្លួន គឺថាលោកក៏បានប្រើសៀវភៅដែរ ក៏មិនជាបញ្ហាទេ។ ឥឡូវនេះ ខ្ញុំសួរដេញដោលសាក្សី ហើយខ្ញុំប្រើសៀវភៅ ហើយខ្ញុំសួរសៀវភៅ អ៎! សួរគាត់អំពីសៀវភៅរបស់គាត់។ ឥឡូវនេះ ខ្ញុំសួរសៀវភៅ អំពីសៀវភៅរបស់គាត់ ហើយមិនមានការបញ្ជាក់អ្វីដែលថា អ្វីជាមូលដ្ឋាននៃការបញ្ជាក់ ដោយថាគាត់បានធ្វើការសិក្សាស្រាវជ្រាវ ហើយខ្ញុំសួរឲ្យគាត់បញ្ជាក់។ នេះជាបញ្ហាដ៏សំខាន់សម្រាប់ខ្ញុំនៅទីនេះ។ យើងអាចនិយាយថា អ្វីដែលគាត់សរសេរគឺក្លែងក្លាយ ឬមិនពិត យើងអាចទទួល ហើយបើសិនជាមិនប្រកាន់ជំហរបែបហ្នឹងត្រឹមត្រូវ គាត់មិនប្រាកដហើយគាត់អាចដឹងអ្វីក្រោយពីហ្នឹង។ ហើយគាត់អាចសរសេរស្មាន នៅពេលដែលគាត់ដឹង ឬក៏គាត់អាចមិនដឹងរឿងហ្នឹងច្បាស់ទេ គាត់សរសេរ គឺមានជម្រើសមួយចំនួននៅទីនេះ។

ប៉ុន្តែភាពជឿជាក់របស់គាត់នោះ គឺចោទជាបញ្ហានៅទីនេះ ហើយសក្ខីកម្មរបស់គាត់ ក៏ចោទជាបញ្ហានោះដែរ ហើយបន្ទាប់មកទៀត ដោយគាត់ទៅបឹងត្របែក ហើយនរណាជាអ្នកត្រួតត្រានៅបឹងត្របែក នៅចំណុចពេលណាមួយ នោះជាចំណុចសំខាន់ពីព្រោះសក្ខីកម្មរបស់គាត់ គាត់និយាយអំពីលក្ខខណ្ឌនៃការរស់នៅ។ នេះហើយ ដែលខ្ញុំសួរដេញដោលសាក្សី អំពីបញ្ហាទាំងនេះបាទ។

[១០:០១:១៧]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយ របស់ -- ដែលសួរឡើងឡើងមេធាវីទេ ពីព្រោះជាសំណួរច្រំដែល។ សាក្សីបានឆ្លើយរួចហើយសំណួរនេះ។ ទី២ លោកមេធាវី លោកទេដែលរៀបចំសំណួរឲ្យសាក្សីឆ្លើយជាសេចក្តីសន្និដ្ឋាន ក្រោយមកលោកថា មិនមានបំណងថា មិនឲ្យសាក្សីឆ្លើយជាសេចក្តីសន្និដ្ឋានទេ។ នេះជារឿងរបស់លោក។ ដូច្នេះ លោករៀបចំសំណួរធ្វើម៉េចឲ្យបានត្រឹមត្រូវ។ បញ្ហាមួយទៀត យើងកត់សម្គាល់ឃើញថា លោកមានសំណួរ តាំងសំណួរប្រភេទម៉្យាងដែលមិនអាចប្រើប្រាស់នៅទីនេះទេ ឲ្យឆ្លើយ សាក្សីឆ្លើយថា "បាទ" ឬក៏ "ទេ"។ សំណួរនេះ មិនអាចអនុវត្តបាននៅ

**អ.វ.ត.ក ទេ។**

[១០:០២:១១]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបលោកប្រធាន គឺថាខ្ញុំមានអង្គជំនុំជម្រះ ជាអត្ថបទអំពីចម្លើយរបស់គាត់ គាត់ដែលនិយាយថា តើគាត់ប្រកាន់ជំហរហ្នឹងដែរឬទេ ពីព្រោះថា យើងសំណួរឲ្យគាត់ឆ្លើយថាតើបើមិនបញ្ជាក់អ៊ីចឹង យើងមិនដឹងថា ចម្លើយរបស់គាត់បែបណានោះទេ។

**ប្រធានអង្គជំនុំ៖**

តាំងសំណួរធ្វើម៉េចកុំឲ្យមានការខុសឆ្គង។ លោកអំមិញលោកសួរទៅ គាត់ធ្វើសេចក្ដីសន្និដ្ឋានពីព្រោះគាត់បានរៀបរាប់ហើយថា គាត់សរសេរដូច្នេះ គឺគាត់ស្រាវជ្រាវ ក្រោយពេលដែលគាត់ឆ្លងកាត់បទពិសោធន៍រស់នៅទីនោះ ហើយនិងអំឡុងពេលដែលគាត់សរសេរសៀវភៅ។ ដល់ពេលគាត់ឆ្លើយជាសេចក្ដីសន្និដ្ឋាន លោកថា កុំឲ្យគាត់ឆ្លើយជាសេចក្ដីសន្និដ្ឋាន ប៉ុន្តែសំណួរ គឺសួរ គាត់នឹងឆ្លើយជាសេចក្ដីសន្និដ្ឋាន។

[១០:០៣:០៨]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តាមសេចក្ដីសង្កេតរបស់លោក លោកសាក្សី តើលោកអាចរៀបរាប់ប្រាប់ខ្ញុំបានទេ អំពីលក្ខខណ្ឌ ដែលលោកនៅទីនោះដំបូង ហើយនិងលោកនៅទីនោះជាលើកទី២ និយាយពីបឹងត្របែក?

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** ខ្ញុំអាចបញ្ជាក់ជូនលោកមេធាវីជាទីគោរពបានថា កាលខ្ញុំមុន ពួកយើងខ្ញុំនៅឆ្នាំ១៩៧៦ ជីវភាពរស់នៅ នៅបឹងត្របែកមានការតានតឹងពិបាក។ ដល់ឆ្នាំ៧៨ ពួកយើងខ្ញុំមកវិញ គឺជីវភាពរស់នៅបានធូរស្រាលបាទ។

**ស៖** តើមានអាហារគ្រប់គ្រាន់ដែរឬទេ នៅឆ្នាំ១៩៧៨ គឺថាមានប្រសើរ ឬច្រើនជាងឆ្នាំ១៩៧៦បាទ?

**ឆ៖** បាទនៅឆ្នាំ១៩៧៨ មានអាហារហូបគ្រប់គ្រាន់ វាមិនសម្បូរដូចអ្នកខ្លះថាទេ ប៉ុន្តែចំពោះយើងខ្ញុំដែលធ្លាប់អត់នោះគឺថា វាគ្រប់គ្រាន់ ហើយដែលមានគ្នាយើងមួយចំនួនឡើងសាច់ពេលនោះ។

**ស៖** នៅក្នុងសៀវភៅរបស់លោក ហើយមានសំណួរមួយចោទទៅលោក ដោយចៅក្រម

ឡាវែន៍ តាមខ្ញុំចាំ សួរយ៉ាងពិស្ដារ ហើយលោកបានចង្អុលបង្ហាញថា គឺមាន ជាម ដែលលោកបានជួប នៅពេលដែលលោកបានទៅបឹងត្របែកជាលើកទី២?

[១០:០៥:១៧]

**ឆ៖** បាទ តាមខ្ញុំចាំគឺលោកហ្នឹងហើយ ដែលទៅទទួលពួកយើងខ្ញុំពីទូតមក។

**ស៖** បាទ តាមអ្វីដែលខ្ញុំយល់លោកបានជួបៗ ជាមួយគាត់នៅក្រសួងការបរទេសនៅពេលមួយ ហើយគាត់នោះគឺនៅក្រោមការគ្រប់គ្រងរបស់ សួរ ហុង តើត្រូវដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលទៅក្រសួងការបរទេសទេ ប៉ុន្តែខ្ញុំ -- ខ្ញុំដែលនិយាយរៀបរាប់ក្នុងសៀវភៅគឺថា គាត់បានទទួលពួកយើងខ្ញុំកាលពួកយើងខ្ញុំមកពីដីក្រហម ហើយនាំពួកយើងខ្ញុំមកសំណាក់នៅជិតវត្តភ្នំ មួយយប់ ហើយនាំ -- បន្ទាប់មកព្រឹករព្វកឡើងនាំពួកខ្ញុំយើងខ្ញុំទៅ -- មកកាន់បឹងត្របែក។

**ស៖** ប្រហែលជាមានការបាត់ខ្លឹមសារខ្លះ បើតាមបកៗប្រែ។ ខ្ញុំមិននិយាយថាលោកទៅក្រសួងការបរទេសទេ។ តើតាមការយល់ដឹងរបស់លោក ថាតើបុគ្គលម្នាក់ដែលមានឈ្មោះថា ជាប ឬ ជាម នេះជាមនុស្សមកពីក្រសួងការបរទេសដែរឬទេ?

**ឆ៖** បាទ គាត់ច្បាស់ជាមកពីក្រសួងការបរទេស ពីព្រោះគាត់ៗថាបង អៀង សារី ឲ្យខ្ញុំមកទទួលពួកបងៗ។

[១០:០៦:៥៦]

**ស៖** តាមសក្ខីកម្មរបស់លោក ខ្ញុំយោងទៅរកប្រតិចារឹក ខែសីហា ទី០៩ ខ្មែរ 00833358, អង់គ្លេសទំព័រ៥0 បារាំងទំព័រ៥៤។ លោកបាននិយាយថា នៅពេលដែលលោកឆ្លើយនឹងសំណួរមួយអំពីបុគ្គលរូបនេះ៖ "ខ្ញុំបានជួបគាត់ ហើយនៅពេលដែលខ្ញុំបានឃើញមុខគាត់ ខ្ញុំស្គាល់មុខគាត់ដោយថាគាត់មានរូបថតនៅលើការបោះពុម្ពផ្សាយ។ ខ្ញុំគិតថាជាគាត់។ គាត់គឺអាយុប្រហាក់ប្រហែលទៅនឹង សួរ ហុង។ បាទ គឺជាដៃស្ដាំរបស់ សួរ ហុង ផងដែរ"។ ឥឡូវខ្ញុំសូមសួរលោក ថាតើតាមការយល់ដឹងរបស់លោកនៅពេលនោះថា គាត់គឺជាដៃស្ដាំរបស់ សួរ ហុង ផ្អែកទៅលើអ្វីដែលលោកដឹង ឬក៏ផ្អែកទៅលើអ្វីដែលគាត់បាននិយាយនោះ?

**ឆ៖** ខ្ញុំដល់បានឃើញ រូបថត ខ្ញុំឃើញថាគាត់ ខ្ញុំមិនច្បាស់ជា១00ភាគរយ ខ្ញុំគ្រាន់ថា ខ្ញុំប្រហែលជាគាត់ហើយ ប្រហែល -- បើសិនជាគាត់មែន គឺពេលនោះគាត់ជាអ្នកធ្វើការជិតដិតជាមួយលោក សួរ ហុង បាទ។

[១០:០៨:២៨]

**ស៖** បាទ។ ដូច្នេះខ្ញុំសូមសួរដេញទៅទៀត ដែលថាលោកបានឃើញរូបថត។ តើលោកបានឃើញរូបថតគាត់នៅពេលណា? ពីព្រោះលោកនិយាយនៅទីនេះថា លោកបានឃើញនៅក្នុងកាសែត តាមដែលខ្ញុំអាននេះ។ តើលោកអាចប្រាប់ខ្ញុំបានទេ នៅក្នុងបរិបទណាដែលលោកបានឃើញរូប រូបថត ឬក៏មុខគាត់នៅលើសារព័ត៌មាន នៅកាសែតនេះ?

**ឆ៖** ខ្ញុំបានឃើញនៅតាមវិស័យ អ៊ីនធឺណេត។

**ស៖** បាទ សូមលោកនិយាយឲ្យជាក់លាក់ជាងនេះ នៅពេលដែលលោកតាមដានដំណើរការនីតិវិធី ហើយក្រោយពីតាមដានលោកបានឃើញរូបថត ឬក៏លោកអានអត្ថបទសារព័ត៌មាន ទាក់ទងនឹងសក្ខីកម្មរបស់គាត់ ឬនៅពេលដែលគាត់មកធ្វើសក្ខីកម្មនៅក្នុងសម្បថ។ តើលោកបានឃើញរូបថតហ្នឹងក្នុងបរិបទណាមួយតាមប្រព័ន្ធ អ៊ីនធឺណេតនោះ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ ប៉ុន្តែគ្រួសារខ្ញុំគាត់ឃើញអ៊ីចឹងទៅ គាត់បង្ហាញខ្ញុំ ហើយខ្ញុំគិតគ្នាថា ប្រហែលជាគាត់ហ្នឹងហើយ។ ខ្ញុំនិយាយម្ដងទៀត គឺខ្ញុំមិនច្បាស់ ដូចខ្ញុំបានធ្វើសក្ខីភាពហើយ ខ្ញុំមិនច្បាស់១០០ភាគរយទេ។ ហើយខ្ញុំអត់បានអានអីផ្សេងទៀត គ្រាន់តែបានឃើញអ៊ីចឹងបាទ។

**ស៖** បាទ ហើយយើងមានសាក្សីម្នាក់ដែលមកសក្ខីកម្ម ឈ្មោះ ជាម។ តើ ជាប ឬ ជាម តាមដែលលោកចាំនោះ? នៅក្នុងសៀវភៅរបស់លោក គឺ ស៊ី-អេច-អ៊ី-អេ-ភី ដែលអានថា ជាប។ បាទ ដែលជាមនុស្សដែលធ្វើការឲ្យលោក សួរ ហុង គឺវាអាចដែលថា លោកយកឈ្មោះខុស ដែលអាចឈ្មោះ ជាម ឬក៏ឈ្មោះ ជាប។ តើណាមួយខុស ណាមួយត្រូវ?

[១០:១១:០១]

**ឆ៖** ខ្ញុំ ការទាំងអស់ ខ្ញុំនិយាយទាំងអស់ គឺខ្ញុំមិនឈរការពិត -- ការដែលដែលខ្ញុំច្បាស់ប្រាកដខ្លួនឯង១០០ភាគរយទេ។ នេះខ្ញុំបាននិយាយតាំងពីមុនមក។ ហើយអាឈ្មោះដាក់នោះ គឺថាខ្ញុំមិន ឈ្មោះខ្ញុំសរសេរ ជួនកាល អ្នកខ្លះ ខ្ញុំដាក់ទៅ វាមានក្លែងឈ្មោះខ្លះ ដើម្បីកុំឲ្យមានបញ្ហា។ ដូច្នេះ ទាំងអស់នេះ ខ្ញុំមិនធានាថា ខ្ញុំច្បាស់១០០ភាគរយ ក៏ខ្ញុំមិនធានាដែរ។ គឺខ្ញុំសូមនិយាយហើយនិយាយទៀត បាទ។

**ស៖** តាមអ្វីដែលលោកយល់ គឺថាអាចនឹងលោកក្លែងឈ្មោះរបស់គាត់ គឺថាលោកប្រើឈ្មោះគាត់ ជាប។ នេះហើយ ដែលគាត់សរសេរ -- លោកសរសេរអំពីគាត់នៅក្នុងផ្នែកមួយចំនួន ដោយប្រើឈ្មោះថា ជាប ដែលគេ -- ដែលគាត់ជាមនុស្សប្រើម៉ូតូហុងដា បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:១២:២២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខាងការពារក្ដី នាំឲ្យសាក្សីឆ្លើយព្រាវៗ ហើយ ព្រោះសំណួរដដែលៗ។ ហើយព្រោះថា ចៅក្រម ឡាវែន៍ បានសួរហើយ។ ហើយចាប់ផ្ដើមសំណួរគាត់អំមិញ គាត់ចាប់ផ្ដើមសំណួរដោយប្រើពាក្យ "ប្រហែល" ហើយបន្ទាប់មកទៀត សូមឲ្យសាក្សីធ្វើការសន្និដ្ឋានហើយអ៊ីចឹង របៀបសួរបែបនេះ មិនមែនជារបៀបសួរសមរម្យនោះទេ លោកប្រធាន។

**លោក ម៉ែខល កាណាវាស៖**

លោកចៅក្រម មានចំណុចមួយ ដែលខ្ញុំត្រូវការប្រើសួរដេញដោលនេះ។

[១០:១៣:០០]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកបានបញ្ជាក់ថា លោកបានសរសេរសៀវភៅ ហើយគាត់បានសរសេរជាច្រើនកន្លែងហើយគាត់អះអាងពីមនុស្សម្នាក់ឈ្មោះថា ជាប។ ឥឡូវនេះ លោកអាចមើលទៅខាងលើខាងក្រោមប៉ុន្តែថាយើងរកមិនឃើញឈ្មោះនេះទេ ដែលធ្វើការនៅក្រោម សួរ ហុង នៅក្នុងក្រសួងការបរទេស។ អ្វីដែលយើងឮ គឺឈ្មោះ ជាម ទេ ដែលឈ្មោះម្យ៉ាងទៀត ហៅថា ភី ភួន។ នេះហើយ ជាមូលហេតុដែលខ្ញុំសួរ ខ្ញុំចង់ឲ្យប្រាកដថា តើនេះមិនមែនកំហុសវាយអង្គុយលើលេខទេ? អានេះ ជាចំណុចដែលគេបានប្រើឈ្មោះ ហើយ ឬក៏សាក្សីអាចថា ជាឈ្មោះបដិវត្តមួយផ្សេងទៀត ប៉ុន្តែតាមភស្តុតាង គឺថា ជាមមានឈ្មោះ ជាប ប៉ុន្តែ ជាប ហ្នឹង មាន មិនមាន យើងមិនដឹងទេ។ ដូច្នេះ ហើយទើបខ្ញុំបានសួរដេញដោលសាក្សីរូបនេះ ដើម្បីឲ្យគាត់ឆ្លើយច្បាស់ ថាតើ ជាប ហ្នឹង មាន ឬមិនមាន បាទ?

[១០:១៤:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៤:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះ ជាសំណួរច្រំដែល។ សាក្សីមិនបាច់ឆ្លើយទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ហើយយើងបាន -- ចៅក្រមបានសួរសំណួរជាច្រើនទៅលើលោក ដើម្បីឱ្យលោកបំភ្លឺផ្ទៀងផ្ទាត់អំពីសេចក្តីដកស្រង់មួយចំនួន ដែលអាចរកឃើញនៅក្នុងសៀវភៅរបស់លោក ហើយនៅក្នុងសក្ខីកម្មរបស់លោក។ សំណួររបស់ខ្ញុំ ប្រសិនបើលោកពិតជាបានកត់ត្រា លោកមានកូនសៀវភៅមួយដើម្បីកត់ត្រា នៅពេលដែលលោកសរសេរក្នុងជំពូកនេះ។ តើក្នុងពិភពលោកនេះ ថាតើលោកអាចទទួលឈ្មោះទៅវួចទេថាលោកប្រើឈ្មោះ កត់ត្រាឈ្មោះហ្នឹងខុសទៅវួចនោះបាទ?

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** ធម្មតាអ្នកសរសេរសៀវភៅតាមខ្ញុំ -- គឺឈ្មោះអ្នកខ្លះខ្ញុំក្លែងឈ្មោះខ្លះ ឈ្មោះអ្នកខ្លះខ្ញុំដាក់ឈ្មោះមិនចំ អាហ្នឹងមាន ប៉ុន្តែចំពោះដែរ ជាប ឬ ជាម នេះ គឺខ្ញុំបានចាំថាគាត់ ជាប ឬក៏គាត់អាចឈ្មោះ ជាម ហ្នឹង ក៏ខ្ញុំមិនច្បាស់ទេអាហ្នឹង ព្រោះខ្ញុំសរសេរពេលក្រោយមកបាទ។ ហើយខ្ញុំៗអាចៗត្រចៀកស្តាប់ទៅវាច្រឡំក៏អាចមានដែរ បញ្ហា គ្រាន់ថាឈ្មោះ ជាប ឬឈ្មោះ ជាម គឺៗមានអ្នកជិះម៉ូតូទៅចាំទទួលពួកយើងខ្ញុំ អាហ្នឹងគឺមាន។ អាហ្នឹងខ្ញុំអាចប៊ាននិយាយ ប៊ានថាអះអាងថាវាពិត ១០០ភាគរយដូច្នេះមែន។

[១០:១៦:៤១]

**ស៖** ខ្ញុំចង់ឱ្យលោកបញ្ជាក់ឱ្យច្បាស់ ដើម្បីឱ្យខ្ញុំយល់ច្បាស់ត្រឹមត្រូវតាមចម្លើយរបស់លោក តើលោកនិយាយថាលោកបានជួបគាត់ហ្នឹងតែម្តងទេ ដែលថាៗជួបម្តងហ្នឹងហើយជាមូលហេតុដែលលោកកត់ឈ្មោះគាត់ខុសនោះ។ តើអ៊ីចឹងឬទេ?

**ឆ៖** បាទ ខ្ញុំជួបគាត់ពីរដង ថ្ងៃម្តងៗ ពីៗដីក្រហម ហើយព្រឹកឡើងគាត់នាំពួកខ្ញុំមកបឹងត្របែកហ្នឹង ជួបគាត់ពីរដងហ្នឹង។ ហើយក្រោយមកគាត់មកបឹងត្របែកទៀត ប៉ុន្តែខ្ញុំមិនដែលបានឃើញគាត់ទេ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេថា តើឈ្មោះដែលលោកកត់នៅក្នុងសៀវភៅកំណត់ដៃរបស់គាត់លោក ដែលយើងនឹងយកប្រើនោះ លោកដាក់ឈ្មោះអ្វី? តើលោកមានសៀវភៅកត់ត្រាហ្នឹងដែរឬទេកាលពីសម័យនោះ?

**ឆ៖** ខ្ញុំដាក់ឈ្មោះថា ជាប បាទ។

**ស៖** ឥឡូវនេះ យើង -- ឥឡូវនេះ យើងផ្តោតកំណត់ត្រាសៀវភៅរបស់លោកហ្នឹង ថាតើៗ

សៀវភៅទុកនៅឯណា? តើលោកធ្លាប់បានៗបង្ហាញទៅអ្នកណាផ្សេងទេ ដូចលោក ហេដឌ័រ លោកបានជួបនៅក្នុងឆ្នាំ១៩៨០ ៧៩ ឬ៨០ នៅព្រំដែន។ សាស្ត្រាចារ្យ ឆេនដ៍ល័រ, ហាង់រី ឡូកា, អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ បាទ តើលោកបានបង្ហាញសៀវភៅកំណត់ត្រាហ្នឹងទៅពួកអ្នកទាំងហ្នឹងដែរឬទេ?

[១០:១៩:២២]

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំធ្លាប់បង្ហាញអ្នកស្រាវជ្រាវខ្លះ ប៉ុន្តែខ្ញុំមិនចាំថាអ្នកណាមួយប្រាកដទេ។

**ស៖** តើលោកអាចបញ្ជាក់ឈ្មោះអ្នកស្រាវជ្រាវណាម្នាក់បានឬទេ? ព្រោះថាគេសម្ភាសលោកហ្នឹងខែកុម្ភៈ, មីនា ឆ្នាំ១៩៨០ គឺថា ស្ទីវ ហេដឌ័រ ជាអ្នកសម្ភាសលោក។ បន្តិចទៀត ខ្ញុំចូលទៅដល់បទសម្ភាសន៍នោះ ហើយបន្ទាប់ពីលោកបានចេញពីភ្នំពេញភ្លាមៗបាទ គឺលើកដំបូងហ្នឹងគឺក្នុងឆ្នាំ១៩៧៩ ដែលបានជួប ហើយលោកក៏បានទៅព្រំដែន តើពេលនោះ តើលោកមានសៀវភៅហ្នឹងទេ? តើលោកបានបង្ហាញសៀវភៅនឹងទៅ ហេដឌ័រ ទេ? នេះជាអ្នកដែលប្រមូលព័ត៌មានពេលនោះ នៅពេលដែលលោកបានសរសេរពីកំណត់ហេតុមួយជាព័ត៌មានដ៏លម្អិតអំពីករណីហ្នឹង។

**ឆ៖** ខ្ញុំអត់ចាំថា ខ្ញុំបានបង្ហាញទៅអ្នកណាម្នាក់ បើបង្ហាញក៏បង្ហាញជាថៃដន្យព្រោះខ្ញុំមិនត្រូវការអីទៅបង្ហាញអ្នកដទៃពីស្អីដែលខ្ញុំសរសេរសម្រាប់ផ្ទាល់ខ្លួនរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំគ្រាន់ ដែលខ្ញុំមិនៗមាន មិនបានយល់ឃើញថា មានសារៈសំខាន់អី ខ្ញុំទៅបង្ហាញអ្វីដែលខ្ញុំទុកថាជារបស់សំខាន់សម្រាប់ខ្លួនខ្ញុំផ្ទាល់។ ហើយទុកជាអ្នកដទៃដែលជួបខ្ញុំក៏គេមិនដែលទាមទារថា ដូច្នេះ ដូច្នោះដែរ។

[១០:២១:០៧]

**ស៖** គាត់បានទៅជួបលោកដើម្បីប្រមូលព័ត៌មានអំពីបទពិសោធន៍របស់លោក បាទ ហើយជាបទពិសោធន៍នៅបឹងត្របែក ហើយនៅកន្លែងផ្សេងៗទៀតជាដើមនោះ។ ហើយគាត់ក៏ -- ខ្ញុំសូមរំឭកលោកថា គាត់ក៏បានអានសរសេរ ហើយក៏និយាយភាសាខ្មែរផងដែរ លោកម្នាក់នោះ បាទ លោក ហេដឌ័រ នោះ។ តើលោកៗមានសៀវភៅកំណត់ដៃជាមួយលោកទេ នៅពេលនោះ ដែលលោកទំនងជាបានចងចាំសេចក្ដីដកស្រង់ ឬពាក្យដកស្រង់មួយចំនួន ពីព្រោះថាគាត់សរសេរគាត់បានលើកឡើងពីចំណុចនេះឯង អំពីបទសម្ភាសន៍ជាមួយលោកនោះ?

[១០:២១:៥៥]

**ឆ៖** ខ្ញុំៗអត់ចាំទេ គ្រាន់ថា ចាំច្បាស់ខ្ញុំបានជួប ស្ទីវ ហេដឌ័រ មែន នៅប្រទេសថៃ។

**ស៖** នៅក្នុងការជួបនោះ តើគាត់មកជួបលោក ឬក៏លោកទៅជួបគាត់? បាទ គាត់មកពីសាកលវិទ្យាល័យ ខូរណែល ជានិស្សិតបញ្ចប់ការសិក្សា គាត់ធ្វើការស្រាវជ្រាវ។ ដូច្នេះ តើលោកនៅចាំដែរឬទេ ថាតើការជួបគ្នាហ្នឹង បាទជួបជាមួយ ហេដឌ័រ ហ្នឹងគាត់ជាអ្នកមកជួបលោក ឬក៏លោកទៅជួបគាត់?

**ឆ៖** ខ្ញុំអត់មានលុយទិញកប៉ាល់ហោះ ហើយខ្ញុំក៏គ្មានសិទ្ធិទៅជួបលោកនៅ ខូរណែល នៅញូវយ៉កដែរ គឺខ្ញុំអង្គាល់ហ្នឹង ខ្ញុំជាប់នៅជំរំភៀសខ្លួន។ ដូច្នេះ គាត់មកជួបខ្ញុំ។

**ស៖** បាទ ខ្ញុំសូមអភ័យទោស ដោយសារថា ការបកប្រែហ្នឹងគឺថា អាចខុស ខ្ញុំមិនអាច -- ខ្ញុំមិនបាននិយាយថា លោកទៅ ខូរណែល នោះទេ។ ឥឡូវនេះ ខ្ញុំសួរឡើងវិញៗ។ តើលោកជួបគាត់ដោយវិធីណា? តើគាត់មកជួបលោក ឬក៏លោកទៅជួបគាត់? តើណាមួយ? តើលោកចាំដែរឬទេ ក្នុងករណីពីរនេះ?

[១០:២៣:៣១]

**ឆ៖** គាត់ៗមានសិទ្ធិដើរមក ជិះកប៉ាល់ហោះមក មកជួបខ្ញុំ។ ខ្ញុំទៅជួបគាត់ម៉េចកើត។

**ស៖** លោកសាក្សី ខ្ញុំសូមសង្កត់ចំណុចនេះ លោកនៅព្រំដែននៅក្នុងប្រទេសថៃ ហើយខ្ញុំចង់ដឹងថាតើលោកជួបគាត់ដោយវិធីណា? តើលោកដឹងថា គាត់នៅទីនោះជាអ្នកធ្វើការសិក្សា លោកទៅជួបគាត់ ឬក៏គាត់ដើរស្វែងរកអ្នកភៀសខ្លួនណាម្នាក់ដើម្បីសម្ភាស? តើករណីណាមួយក្នុងចំណោមពីរនេះនេះជាសំណួរសាមញ្ញបំផុតបាទ?

**ឆ៖** ហើយសំណួរសាមញ្ញ ខ្ញុំឆ្លើយជាសាមញ្ញវិញ គឺថាគាត់មកជួបខ្ញុំបាទ។

**ស៖** បាទ តើគាត់រកឃើញលោកដោយវិធីណា? បាទ ហេតុអីក៏គាត់ដឹងថា លោកនៅទីណា? តើលោកនៅចាំដែរឬទេ ថាគាត់ដឹងថាលោកទីណា ហើយជួបដោយរបៀបម៉េចនោះ?

**ឆ៖** ខ្ញុំអត់ចាំទេបាទ។

[១០:២៥:០១]

**ស៖** តើលោកនៅចាំទេ បានជួបគាត់ និងផ្តល់សម្ភាសទៅគាត់ប៉ុន្មានថ្ងៃ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ ព្រឹត្តិការណ៍នេះកើតមានយូរហើយ ប៉ុន្តែខ្ញុំគ្រាន់តែខ្ញុំដឹងច្បាស់ថាខ្ញុំបានជួបគាត់ពិតប្រាកដមែន។

**ស៖** ឥឡូវនេះខ្ញុំនឹងទៅមុខបន្តិចមុននឹងចូលទៅដល់បទសម្ភាសន៍របស់លោក ហើយត្រឡប់ទៅ

អ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក។ លោកនិយាយនៅទំព័រ១៥ថា៖ “សៀវភៅនេះមិនអាចមានទេ ប្រសិនបើ ហង់រី ឡូកា មិនបានឃើញសៀវភៅនេះនៅក្នុងកន្លែងរបស់ ស្ទីវ ហេដឌ័រ ទេ”។ តើនេះជាករណីដែលថា ហើយទុកនៅក្នុងកន្លែងរបស់ ស្ទីវ ហេដឌ័រ ហើយ ហង់រី ឡូកា បានឃើញសេចក្ដីព្រាងហ្នឹង។ តើលោកអាចពន្យល់បានទេពីចំណុចនេះ?

[១០:២៦:២២]

**ផ៖** ខ្ញុំបានសរសេរមែន ជា១ការពិតមែន ប៉ុន្តែអានេះជាការគួរសមចំពោះមនុស្សធ្លាប់ស្គាល់។ ប៉ុន្តែខ្ញុំមិនដឹងជាលោកមេធាវីចង់បានអីទេ គ្រាន់ថាខ្ញុំបានសរសេរហើយ ហើយមានអ្នក -- ស្ទីវ ហេដឌ័រ ថ្ងៃមួយ ឮសួរថាបងសរសេរសៀវភៅ? ខ្ញុំថា “ខ្ញុំសរសេរសៀវភៅ”។ គាត់ថា ខ្ញុំសរសេរជាភាសាបារាំង គាត់ថា ភាសាបារាំងក៏គាត់ចង់បានមួយកូពីដែរ ហើយខ្ញុំក៏បញ្ជូនឱ្យគាត់ទៅ។ ហើយថ្ងៃមួយស្រាប់តែខ្ញុំ -- ស្ទីវ ហេដឌ័រ គាត់ទៅលេង ឡុង ទៅផ្ទះ១ ហេដឌ័រ ហើយគាត់ក៏ គាត់ -- ហង់រី ឡូកា ក៏គាត់ថា យី! បានសរសេរអ៊ីចឹងម៉េចក៏មិនបោះពុម្ពផ្សាយ? ហើយដូច្នេះ គឺរឿងហ្នឹងបញ្ចប់ប៉ុណ្ណឹង អត់មានរឿងអីផ្សេងទៀតទេបាទ។

**ស៖** បាទ អរគុណ។ តាមដែលខ្ញុំយល់តើត្រឹមត្រូវឬទេ លោកបានបញ្ជូនសំណេរផ្ទាល់ដៃទៅឱ្យលោក ស្ទីវ ហេដឌ័រ នៅឡុងដុង ដែរឬទេ?

[១០:២៧:៣៦]

**ផ៖** បាទ ខ្ញុំ ដូចខ្ញុំនិយាយហើយ ខ្ញុំបានសរសេរចប់ទៅមាន ខ្ញុំបញ្ជូនសៀវភៅហ្នឹងគឺថាវាច្រើនទៅអ្នកដែលគេចង់បាន ខ្ញុំបញ្ជូនឱ្យច្រើនគ្នាបាទ មិនមែនតែ ស្ទីវ ហេដឌ័រ មួយទេ។

**ស៖** ស្ទីវ ហេដឌ័រ ត្រឡប់មក -- បញ្ជូនមកឱ្យលោកវិញនូវអំពីមតិយោបល់ពីសៀវភៅរបស់លោកទេ ដែលនៅជាសេចក្ដីព្រាងនោះ?

**ផ៖** ខ្ញុំអត់ចាំទេបាទ ដូចជាគ្មានទេ។

**ស៖** ចាប់ពីលោកបង្ហាញសៀវភៅព្រាង ហើយនិងរហូតដល់បោះពុម្ពផ្សាយ តើ ស្ទីវ ហេដឌ័រ ធ្លាប់បានសូមឱ្យលោកចែករំលែកនូវកំណត់សៀវភៅ កូនសៀវភៅដែលលោកកត់ត្រាក្នុងពេលបច្ចុប្បន្ននាកាលនោះ ដែលលោកបានរៀបរាប់អ៊ីចឹងដែរឬទេ?

[១០:២៨:៤៩]

**ផ៖** អត់ បាទអត់មាន ដូចជាអត់មានទេបាទ។ គាត់មិនដែលសុំអ្វីដែលខ្ញុំមិនឱ្យគាត់ទេបាទ។

**លោក ម៉ៃខល កាណាវ៉ាស៖**

បាទ ឥឡូវនេះខ្ញុំចូលជិតទៅដល់បទសម្ភាសន៍ហើយលោកប្រធាន ខ្ញុំឃើញថាពេលនេះដូចជាយូរបន្តិច អ៊ីចឹងគឺថាអាចនឹងប្រើពេល៥នាទី ឬក៏១០មីនុត ហើយប្រហែលជាពេលសមស្របលោកប្រធានគួរតែសម្រាកសិន ឬក៏អនុញ្ញាតឲ្យខ្ញុំបន្តបាទ?

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលប៉ុន្មានទៀត ទំនង ចំណាយពេលប៉ុន្មាន ប្រហែលប៉ុន្មានទៀត?

**លោក ម៉ៃខល កាណាវ៉ាស៖**

ផ្នែកនេះ គឺថាអាចនឹងវែងបន្តិច ខ្ញុំគិតថា នឹងត្រូវប្រើពេលមួយព្រឹក ហើយប្រហែលជានៅថ្ងៃត្រង់ខ្ញុំអាចនឹងបញ្ចប់ការសួរដេញដោលលោកសាក្សី ប្រសិនបើលោកប្រធានសម្រាកពេលនេះ គឺខ្ញុំមានឱកាសដើម្បីបង្រួម អាចបំព្រួញការ -- វិធីសួរដេញដោលរបស់ខ្ញុំ។ នោះគឺ ខ្ញុំសូមជម្រាបតុលាការបែបនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដោយសារអង្គជំនុំជម្រះ បានស្តាប់លោកកាលពីថ្ងៃចុងក្រោយ នៃការសួរដេញដោលសាក្សីរូបនេះ លោកបានព្យាករនូវពេលវេលារបស់លោក ថាប្រហែលជាមួយម៉ោងទៀតទេ។ អ៊ីចឹង ហើយបានជាយើងសួរ ដើម្បីថា បើសិនជា១០មីនុតអី យើងបន្តឲ្យចប់ទៅ ដើម្បីឈានទៅក្រុមមេធាវីផ្សេងទៀត ដែលនឹងបន្តតាំងសំណួរ។ អ៊ីចឹងការដែលលោកព្យាករប្រហែល១ម៉ោង កាលពីលើកមុននោះវាខុសទទេ ព្រោះឥឡូវវាដល់ជាង២ម៉ោងឯណោះ មួយព្រឹកវា២ម៉ោង៤០នាទី ឯណោះ។

បាទ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដែលបានកំណត់អម្បាញ់មិញនេះ គឺម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោល ចំពោះសាក្សី អ៊ុង ចុងហឿង។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមបន្តអ្វីដែលយើងទើបបានបញ្ចប់ ដែលលោកជួបជាមួយលោក ស៊ីវ ហេងឌ័រ ដែលលោកបញ្ជាក់ថា លោកបានជួបជាមួយគាត់។ បើយើងមើលទៅលើឯកសារ D108/27.19 ឯកសារនេះបានបង្ហាញជូនលោកកាលពីសប្តាហ៍មុនហើយ។

[១០:៥៣:១៥]

ខ្ញុំចង់មើលទៅភាសាខ្មែរ ដែលមាន ERN 00324684, ERN អង់គ្លេស 00170708, ហើយ ERN ជាភាសាបារាំង 00648967 ដល់ 68។ សូមបញ្ជាក់ថានៅទំព័រខាងមុខនោះ គឺនិយាយអំពីប្រភពនៃឯកសារគឺ អ៊ុង ចុងហឿង និង គឹមហុង នៅក្នុងឆ្នាំ១៩៨០។ នៅពេលដែលលោកមានការសម្ភាសជាមួយលោកស៊ីវ ហេងឌ័រ តើលោកស៊ីវ ហេងឌ័រ សម្ភាសលោកតែម្នាក់ឯង ឬក៏មានអ្នកដទៃទៀតដែលធ្វើឲ្យលោក ស៊ីវ ហេងឌ័រ ហ្នឹងគាត់បញ្ជាក់អំពីប្រភពព័ត៌មាននេះ តើលោកអាចនៅចាំបានទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេបាទ។

**ស៖** តើលោកនៅចាំបានទេ ថាតើការសម្ភាសធ្វើនៅត្រង់ណា? នៅទីកន្លែងណា? នៅក្នុងបន្ទប់ ឬនៅកន្លែងតៀមកាហ្វេ ឬនៅកន្លែងណាមួយ? លោកចាំបានទេ?

**ឆ៖** ខ្ញុំចាំប្រហែលជួប មិនដឹងប៉ុន្មានដងទេ ប៉ុន្តែមានពេលខ្លះ គឺជួបនៅខ្ទមខ្ញុំ នៅជំរំជនភៀសខ្លួន។

**សៈ** នៅពេលដែលលោកបានជួបជាមួយនឹងគាត់ នេះគឺជាសំណួរជាក់លាក់មួយ ថាតើលោកជួបគាត់តែម្នាក់ឯង ឬក៏មានអ្នកណាម្នាក់នៅជាមួយលោកដែរ ដែលអ្នកនោះ ក៏បានចូលរួមផ្តល់ចម្លើយទៅដល់លោក ស៊ីវ ហេឧដ័រ ដែរឬក៏យ៉ាងណានោះ?

**ឆៈ** ខ្ញុំអត់បានចាំទេបាទ។

**សៈ** តើលោកនៅចាំបានទេ ថាលោកស្គាល់លោក សួយ គឹមហុង ដែលជាប្រភពនៃការផ្តល់ព័ត៌មានទៅដល់អ្នកសម្ភាសនេះដែរឬទេ?

**ឆៈ** បាទ ខ្ញុំស្គាល់គាត់។

[១០:៥៦:៣០]

**សៈ** តើលោកស្គាល់ សួយ គឹមហុង នេះ ដោយរបៀបណាដែរ?

**ឆៈ** បាទ គាត់ជាខ្មែរនៅបរទេស ហើយដែលចូលស្រុកដូចខ្ញុំដែរ។

**សៈ** មុននឹងការជួលរលំភ្នំពេញនោះ តើគាត់រស់នៅបឹងត្របែក ដែលលោកស្គាល់គាត់នៅទីនោះ ឬក៏យ៉ាងណា?

**ឆៈ** បាទ ខ្ញុំស្គាល់គាត់តាំងពីស្រុកបារាំងមក ប៉ុន្តែគាត់ -- ខ្ញុំអត់បានរស់នៅជាមួយគាត់យូរទេ គឺថាបាន -- ប្រហែលជាបានជួបគ្នានៅបឹងត្របែក ឆ្នាំ -- ក្នុងឆ្នាំ១៩៧៨។ បានន័យថា គាត់អត់បានរស់នៅក្នុងប្រទេសកម្ពុជាជាមួយខ្ញុំអស់រយៈពេលយូរទេ។

**សៈ** អ្វីដែលខ្ញុំមានចំណាប់អារម្មណ៍នោះ ថានៅពេលដែលលោកនៅបឹងត្របែកនៅឆ្នាំ១៩៧៨ ជាលើកទី២ តើគាត់នៅទីនោះ ជាមួយលោកដែរឬទេ? ព្រោះដូចយើងមាន ប-៣០, ប-៣១, ប-៣២ នៅកន្លែងអស់នេះ។ តើគាត់ -- លោកបានឃើញជួបគាត់នៅក្នុងឆ្នាំ១៩៧៨ ដែរឬទេ?

**ឆៈ** ខ្ញុំបានជួបគាត់ ប៉ុន្តែដល់ -- ខ្ញុំអត់បាននៅជាមួយគាត់ទេ ព្រោះបន្ទាប់មកគាត់ចេញបាត់ទៅ ប៉ុន្តែមិនដឹងគាត់ទៅណា ខ្ញុំមិនចាំទេបាទ។ គ្រាន់តែខ្ញុំបានជួបគាត់ ពេលខ្ញុំមកពីដីក្រហមវិញ ក្នុងឆ្នាំ១៩៧៨។

**សៈ** ដូច្នេះ ជាការច្បាស់ហើយ ដែលថានៅខែតុលា ខែវិច្ឆិកា ខែធ្នូ ១៩៧៨ តាមដែលលោកចាំ គឺថាគាត់នៅទីនោះ តើអ៊ីចឹងមែនទេ?

**ឆៈ** ខ្ញុំមិនចាំច្បាស់ថាគាត់នៅទីកន្លែងណាទេ ប៉ុន្តែពេលខ្ញុំទៅនៅ -- ខ្ញុំទៅដល់បឹងត្របែកក្នុងឆ្នាំ១៩៧៨ ខ្ញុំបានឃើញគាត់មួយរយៈហើយបាត់គាត់ទៅ។ ខ្ញុំមិនដឹងជាគាត់ទៅណាពិតប្រាកដទេបាទ។

[១០:៥៩:៣៧]

**សៈ** នៅពេលដែលលោកជួបគាត់នៅព្រំដែន តើលោកមានបានសួរគាត់ថា មានអ្វីកើតឡើងដល់គាត់ ឬក៏យ៉ាងណាដែរទេ?

**ផៈ** យើងបាននិយាយគ្នាខ្លះដែរ -- អ៎! ច្រើនដែរ ប៉ុន្តែខ្ញុំអត់មានចាំទេបាទ។

**សៈ** ឥឡូវនេះសូមចូលទៅទំព័រដែលខ្ញុំមានចំណាប់អារម្មណ៍មួយ។ ដូចខ្ញុំបានបញ្ជាក់ពីដើមហើយ គឺ ERN 00324684 ហើយ នេះជា ERN ភាសាខ្មែរ, ERN ជាភាសាអង់គ្លេស 00170700 ទៅដល់ 9, ហើយជាភាសាបារាំង 00648967 ដល់ 78។ ខ្ញុំសូមអានផ្នែកមួយសិន មុននឹងខ្ញុំតាំងសំណួរទៅលោក ដោយយើងមិនដឹងថាលោកជាប្រភពនៃអ្នកផ្តល់ព័ត៌មាននេះ ឬក៏លោកម្នាក់ទៀតនោះជាអ្នកផ្តល់ព័ត៌មាននេះ? បាន -- លោក គឺមានលើកឡើងថា៖ "ខ្ញុំគិតថាបន្ទាប់ពីខួបបក្សក្នុងឆ្នាំ១៩៧៨ រួចមក សារ៉ន ត្រូវបានគេចាប់ខ្លួនជាមួយនឹងជំនួយការពីរនាក់របស់គាត់ ហើយត្រូវបានគេបញ្ជូនទៅគុកទួលស្លែង ហើយបន្ទាប់មកក៏ត្រូវបានគេប្រហារជីវិតចោល។ ក្រោយមក អៀង សារី ក៏បានប្រាប់យើងយើងខ្ញុំថា សារ៉ន ជាជនក្បត់បម្រើឲ្យវៀតណាម។ បន្ទាប់មក បឹងត្របែកត្រូវបានបំបែកជា ប-៣០, ប-៣២ និង ប-៣១។

[១១:០១:៣៨]

តើលោកនៅចាំទេ ថាលោកជាអ្នកផ្តល់ព័ត៌មាននេះ ឬក៏លោកម្នាក់ទៀត?

**ផៈ** ខ្ញុំមិនដឹងជាគាត់ -- វាអាច -- ខ្ញុំៗចាំថា -- ខ្ញុំមិនចាំទេ ប៉ុន្តែការព័ត៌មាននេះគឺថា ខ្ញុំៗក៏បានព័ត៌មានអ៊ីចឹងដែរបាទ។

**សៈ** នៅពេលដែលលោកមានវត្តមាននៅទីនោះ នាពេលនោះ តើអ្វីដែលខ្ញុំទើបតែអានឲ្យលោកស្តាប់អម្បាញ់មិញនេះ វាស្របគ្នាទៅនឹងការចងចាំព្រឹត្តិការណ៍នៅពេលនោះ ដែលព្រឹត្តិការណ៍ដែលបានកើតឡើងនៅពេលនោះ បើសិនណាជាលោកនឹកឃើញ តើវាស៊ីសង្វាក់គ្នាទេ?

**ផៈ** បាទ ស៊ីសង្វាក់គ្នា។

**សៈ** ដូច្នេះតើវាជាការត្រឹមត្រូវទេ ដែលថាបើលោកមើលឯកសារនេះទៅ មានសំណួរដ៏ច្រើនដែលបានសួរទៅលោកអំពីបឹងត្របែក តើលោកនៅចាំដូច្នេះទេ?

**ផៈ** សំណួរបែបម៉េច ខ្ញុំៗ -- សំណួរជាច្រើនៗហ្នឹងឈរលើអីបាទ?

[១១:០៣:២៤]

**សៈ** លោក ស្ទីវិន ហេដឌ័រ បានជួបជាមួយនឹងលោក ដោយសារលោកគឺជាបញ្ញាជនដែលរស់នៅបឹងត្របែក និងកន្លែងដទៃទៀត ហើយសំណួរជាច្រើនគឺសួរទៅលើការកត់សម្គាល់ក៏ដូចជាបទពិសោធន៍របស់លោក ដែលលោករស់នៅបឹងត្របែក តើនេះត្រឹមត្រូវទេ?

**ឆៈ** បាទ នេះជាការត្រឹមត្រូវហើយ។

**សៈ** ហើយលោកបានបញ្ជាក់ថា ការសម្ភាសគឺលោកបានផ្តល់បទសម្ភាសន៍ទៅគាត់អស់រយៈពេលជាច្រើនថ្ងៃ។ តើមានពេលណាមួយដែលគាត់សួរឲ្យលោកគិតទៅដល់ព្រឹត្តិការណ៍ ឬក៏ឲ្យផ្តល់ទៅគាត់នូវឯកសារ ឬក៏ព័ត៌មានណាមួយ ដោយយោងទៅលើបទពិសោធន៍របស់លោកនៅពេលនោះ ឬក៏ក្រោយមក ដូចជានៅពេលដែលលោកទៅធ្វើការនៅសារមន្ទីរទួលស្លែងនៅស-២១ នេះជាដើម?

[១១:០៤:៤៦]

**ឆៈ** បាទ ខ្ញុំមានប្រគល់ឯកសារមួយចំនួនជូនគាត់ ប៉ុន្តែខ្ញុំមិនចាំថាអ្វីខ្លះទេបាទ។ ពីព្រោះក្នុងទិសដៅពេលនោះ ខ្ញុំចង់ឲ្យគាត់ហ្នឹងផ្សាយពីទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរ។

**សៈ** ហើយគាត់ក៏បានសួរទៅលោកដោយយោងទៅលើការសិក្សាស្រាវជ្រាវរបស់គាត់ ហើយលោកបានៗផ្តល់នូវចម្លើយដ៏ទូលំទូលាយ តាមដែលអាចលោកធ្វើទៅបាន តើនេះត្រឹមត្រូវដែរទេ?

**ឆៈ** និយាយម្តងទៀតគឺថាខ្ញុំច្បាស់ហើយ ថាខ្ញុំបានជួបគាត់ ហើយខ្ញុំបានបង្ហាញអ្វីដែលខ្ញុំបានឃើញជូនទៅគាត់។ ប៉ុន្តែខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតគឺថា គាត់ អាការគាត់ -- ការកត់ត្រារបស់គាត់ខ្ញុំអត់បានមើលឡើងវិញទេ។

**សៈ** ខ្ញុំសូមចូលទៅសំណួរខ្ញុំឡើងវិញ។ តាមរយៈសំណួរមួយចំនួនដែលគាត់សួរទៅលោកនោះគឺថាគាត់ព្យាយាមចង់បានព័ត៌មានពីលោកឲ្យបានសុក្រឹត និងឲ្យបានពេញលេញ ឲ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ដោយយោងទៅលើអ្វីដែលលោកបានឃើញនិងបទពិសោធន៍របស់លោកនៅកន្លែងមួយចំនួន។ បឹងត្របែក គឺជាកន្លែងមួយក្នុងចំណោមកន្លែងជាច្រើនដែលគាត់បានសួរទៅលោក តើលោកចាំទេ?

[១១:០៦:៣៨]

**ឆៈ** បាទ ពិតមែនហើយគាត់បានសួរខ្ញុំពីកន្លែងផ្សេងៗដែលខ្ញុំបានរស់នៅ។

**សៈ** ប្រសិនបើយើងអាចចូលទៅមើល ERN ភាសាខ្មែរ 00324684 (ស៊ីក) អង់គ្លេស 001701708 (ស៊ីក) និង ERN ជាភាសាបារាំង 00648969។ គឺថានេះគឺជាការចងក្រងនូវប្រភព

ព័ត៌មានពីរ ហើយខ្ញុំនឹងសួរសំណួរប្រហាក់ប្រហែលគ្នានេះទៅលោក។ លោក អៀង សារី បាននិយាយថាពីរខែមុននឹងវៀតណាមចូលមកឈ្លានពាន គឺគណៈមជ្ឈិមនៅពេលនោះ គឺមានចំនួន ៤៥នាក់ ហើយជំនួយការមួយមានម្នាក់ឈ្មោះ គង់ បាននិយាយថា កម្មាភិបាលរបស់បក្សខ្លះ សូមដកស្រង់ “គឺគោលការណ៍របស់បក្សគឺត្រូវ -- ដើម្បីគឺ -- ហើយដើរតាមមាគ៌ាឆ្វេងនិយមជ្រុល និងបានធ្វើឲ្យរង្គោះរង្គើដល់ផ្ទៃក្នុងបក្ស សូម្បីតែអ្នកស្តាំនិយមក៏បានប្រើយុទ្ធសាស្ត្រក្នុងការអនុវត្តតាមមាគ៌ាឆ្វេងនិយមជ្រុល ដើម្បីធ្វើឲ្យអន្តរាយដល់បក្សដែរ។ យើង -- តាមរយៈនេះ យើងយល់ថាបញ្ហាមួយនោះគឺបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើននោះ គឺក្នុងសហករណ៍នីមួយៗត្រូវបានគេសន្មតថា ជាសង្គមតូចមួយដែលពឹងអាស្រ័យលើខ្លួនឯង ហើយថាគ្រប់សហករណ៍ទាំងអស់ត្រូវផ្តល់នូវស្ថិតិអំពីការបង្កបង្កើនផលស្រូវចំនួនប្រជាជន និងតម្រូវការរបស់ប្រជាជនជូនទៅថ្នាក់លើ។ ចំនួនស្រូវដែលត្រូវបានបញ្ជូនទៅរដ្ឋ គឺជាការទទួលខុសត្រូវតែមួយគត់របស់ប្រធានសហករណ៍នីមួយៗ ប៉ុន្តែប្រធានសហករណ៍ -- ប៉ុន្តែប្រធានសហករណ៍ជាច្រើនបានបំប៉ោងតួលេខផលិតផល ដើម្បីធ្វើឲ្យបក្សមើលទៅពួក -- ឃើញថាពួកគេជាមនុស្សល្អ។ ហើយពួក គេបានបញ្ជូនស្រូវទៅឲ្យរដ្ឋយ៉ាងច្រើនរហូតដល់ធ្វើឲ្យប្រជាជនខ្វះខាតអង្ករបរិភោគ”។

[១១:០៩:២០]

តើលោកនៅចាំទេថា តើចម្លើយនេះដែលលោក ប្រហែលជាលោកជាអ្នកផ្តល់ទៅឲ្យ ស៊ីវ ហេងឆ័រ នេះ តើលោកអាចនៅចាំបានទេ?

**ឆ៖** ខ្ញុំសូមអះអាងដោយច្បាស់លាស់ថា ចម្លើយរបៀបនេះមិនអាចចេញមកពីមជ្ឈដ្ឋានខ្មែរមកពីបរទេសទេ គឺ ស៊ីវ ហេងឆ័រ ច្បាស់ជាជួបអតីតកម្មាភិបាលអ្នកដឹកនាំធំណាមួយហើយ បានអាចនិយាយរបៀបនេះបាន។ ចំពោះខ្ញុំដែលនៅជាប់មន្ទីរឃុំឃាំងមិនអាចមានសមត្ថកិច្ចធ្វើសេចក្តីរាយ-ការណ៍បែបនេះទេ គឺវាជ្រុលហួសពីសមត្ថភាពរបស់ខ្ញុំដែលជាជនជាប់ចោទ -- អ៎!ជនជាប់ខ្លួននៅមន្ទីរឃុំឃាំងហើយ។

**សៈ** មូលហេតុដែលខ្ញុំសួរទៅលោកនេះ បើសិនណាជាលោកមើលទៅទំព័រដើម ដែលនិយាយថា នៅខែ -- នៅ២៩ កុម្ភៈ ១៩៨០ ERN ជាភាសាខ្មែរ 00324681, ជាភាសាអង់គ្លេស 006489 (ស៊ីក) ទៅដល់ -- និង69 (ស៊ីក) ដែលនិយាយថា ប្រភពព័ត៌មានគឺ អុង ថុងហឿង និង សួយ គឹមហុង ហើយបើយើងទៅមើលទំព័របន្ទាប់នោះ គឺឃើញប្រភពព័ត៌មានហើយ។ មិនមានបញ្ជាក់ថា អ្នកណាជា

ប្រភពព័ត៌មានក្រៅពីនេះទេ។ គឺប្រភពព័ត៌មាននេះអាចលោកជាអ្នកផ្តល់ ឬក៏ សួយ គឹមហុង ជាអ្នកផ្តល់ ដែលលោកបានស្គាល់គាត់ ហើយដែលលោកបានចូលរួមជាមួយគាត់ និងនិយាយជាមួយគាត់នៅបឹងត្របែកនៅឆ្នាំ១៩៧៨។

អ៊ីចឹងតាមចម្លើយរបស់លោកនេះ គឺលោកបានឆ្លើយថា លោកមិនបានផ្តល់ចម្លើយបែបនេះទេ អ៊ីចឹងមែនទេ?

[១១:១១:៤៣]

**ឆ៖** ខ្ញុំសូមអះអាងជាឱឡារិកថា ចម្លើយរបស់របៀបនេះ ខ្ញុំគ្មានលទ្ធភាពជូនទេ ពីព្រោះខ្ញុំ វាហួសពីការដែលខ្ញុំបានដឹងហើយ។

**ស៖** អរគុណលោកសាក្សី។ នៅពេលដែលនិយាយអំពីបឹងត្របែក គឺថាលោកបានដឹង ឧទាហរណ៍ បើលោកបានចូលរួមក្នុងកិច្ចប្រជុំណាមួយដែលគេបានប្រាប់ឈ្មោះ ហើយលោកបានប្រាប់ឈ្មោះបន្ត ហើយតាមភាសា គឺថាដុតរោល គឺថាសូមស្រង់គឺថា "លោកស្ថិតនៅក្នុងជំហរមួយដែលថាលោកអាចផ្តល់ព័ត៌មានបែបនេះ ជូនលោក ស្មីរ ហេដឌ័រ បាន"?

**ឆ៖** ខ្ញុំមិនជឿ ដែលថាខ្ញុំ -- ខ្លួនខ្ញុំផ្ទាល់ខ្ញុំមិនអាចដឹងពីសមាជិកគណបក្សមជ្ឈិមមានប៉ុន្មានអីប៉ុន្មាន វាហួសពីសមត្ថភាពរបស់ខ្ញុំ ហើយខ្ញុំមិនចាំថា ខ្ញុំធ្លាប់ដឹងរឿងអស់ហ្នឹងទេ។ អង្កាល់ខ្ញុំនៅជំរំខៅអ៊ីដាង ឬនៅជំនាន់នោះលោក។

[១១:១៣:១១]

**ស៖** អរគុណម្តងទៀត។ ប្រហែលជាការបកប្រែថ្ងៃនេះ ពិបាកយល់មែនទែន ថ្ងៃនេះពីព្រោះខ្ញុំមិនបាននិយាយអ្វីដែលលោកឆ្លើយនេះទេ។ ដូច្នេះ ខ្ញុំសូមសួរឡើងវិញ ពាក់ព័ន្ធទៅនឹងបឹងត្របែក គឺថានៅពេលនោះ គឺលោកស្ថិតនៅក្នុងឆ្នាំ១៩៧៨ អាចខែកុម្ភៈ ដែលលោកបានផ្តល់ព័ត៌មានយ៉ាងប្រត្យក្សទៅដល់លោក ស្មីរ ហេដឌ័រ លោកចាំទេ? តើនេះត្រឹមត្រូវដែរទេ?

**ឆ៖** សូមទោសត្រង់ហ្នឹងយ៉ាងប្រត្យក្សរបៀបម៉េចលោក? ខ្ញុំអត់យល់សំណួរលោក។

**ស៖** បាទ ខ្ញុំសូមរៀបសំណួរឡើងវិញម្តងទៀត។ លោក ស្មីរ ហេដឌ័រ បានសួរលោកអំពីបឹងត្របែក ខ្ញុំបានបង្ហាញសារនេះ គឺថាលោកមិនអាចមានលទ្ធភាពដឹង ឬផ្តល់ព័ត៌មានបែបនេះបានទេ។ ដូច្នេះ ខ្ញុំសួរទៅលោកថា ដោយសារលោកនៅបឹងត្របែក ជាពិសេសនៅឆ្នាំ១៩៧៨ លោកស្ថិតនៅក្នុងជំហរមួយដែលថា អាចផ្តល់ព័ត៌មានទៅឲ្យ ស្មីរិន ហេដឌ័រ ពាក់ព័ន្ធទៅនឹងអង្គភាពបឹងត្របែកនៅ

ពេលដែលលោកនៅទីនោះ រួមទាំងព័ត៌មានពាក់ព័ន្ធទៅនឹងអង្គប្រជុំដែលលោកបានកត់សម្គាល់ឃើញ ឬក៏លោកបានចូលរួមប្រជុំនៅពេលនោះ តើប៉ុណ្ណោះជាការត្រឹមត្រូវដែរឬទេ?

[១១:១៥:០១]

**ឆ៖** បាទ ខ្ញុំអាចនិយាយប្រាប់គាត់ថា អ្វីដែលខ្ញុំបានឃើញ ដែលក្នុងការរស់នៅរបស់ខ្ញុំ នៅតាមជំរំមន្ទីរឃុំឃាំងនានានៅប្រទេសកម្ពុជា។ ប៉ុន្តែខ្ញុំមិនដឹងខ្ញុំបាននិយាយអីខ្លះទេ ពីព្រោះពេលនិយាយហើយគឺវា ពេលកន្លងយូរហើយខ្ញុំវាភ្លេចអស់ហើយ។

**ស៖** ខ្ញុំចង់ឲ្យលោកឆ្លើយលម្អិតទេ។ តាមខ្ញុំយល់មិនច្រឡំទេ គឺថាលោកមានលទ្ធភាពអាចឆ្លើយបញ្ហាបឹងត្របែកនៅឆ្នាំ១៩៧៨ ដែលជាប្រធានបទមួយដែលអ្នកសម្ភាសបានសួរទៅលោក។ ដូច្នេះចម្លើយរបស់ហ្នឹង គឺថាលោកដឹង ឬក៏លោកមិនដឹងតែប៉ុណ្ណោះ?

**ឆ៖** នៅបឹងត្របែកខ្ញុំដឹង ក្នុងឆ្នាំ១៩៧៨ នៅមន្ទីរដែលខ្ញុំរស់នៅ។

**ស៖** ហើយទាក់ទងទៅនឹងចំណុចលម្អិតដែលលោក ស៊ីវ ហេងឆ័រ ចង់ឲ្យលោកបង្ហាញគាត់នោះ គឺលោកបានជូនឯកសារខ្លះទៅគាត់ ដែលនិយាយគ្នាអំពីបឹងត្របែក អ្វីដែលកើតឡើងនៅបឹងត្របែក ឬអ្វីដែលលោកបានកត់សម្គាល់នៅក្នុងកិច្ចប្រជុំដែលមានវត្តមានលោក អៀង សារី។ ឧបមាថាលោកមានកូនសៀវភៅកត់ត្រារបស់លោក លោកអាចពិនិត្យកូនសៀវភៅនេះបាន ដើម្បីផ្តល់ព័ត៌មានលម្អិត។ តើនេះត្រឹមត្រូវដែរឬទេ?

[១១:១៦:៥២]

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ សំណួរបែបឧបមានវិធី មិនអាចប្រើប្រាស់បានទេនៅក្នុងការតាំងសំណួរដេញដោលនៅក្នុងកិច្ចដំណើរការនៅ អ.វ.ត.ក នេះ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនិយាយអំពីកិច្ចប្រជុំ ឬការជួបគ្នាជាមួយ ហេងឆ័រ គឺលោកក៏បាននិយាយអំពីស-២១ដែរ។ តើត្រឹមត្រូវទេ?

**លោក អ៊ុង ឆុងហឿង៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ហើយនៅពេលនោះ គឺគាត់ក៏បានសួរទៅលោកនូវសំណួរលម្អិតមួយចំនួន ទាក់ទងអ្វីដែល

លោកកត់សម្គាល់ឃើញនៅស-២១ ឬទួលស្លែងនេះ នៅពេលដែលលោកធ្វើការនៅទីនោះ។ បើតាមដែលខ្ញុំ គឺថាលោកនិយាយគ្នាអំពីបណ្ណសារ។ តើនេះត្រឹមត្រូវដែរឬទេ?

[១១:១៧:៥៨]

**ឆ៖** សូមទោស បណ្ណសារបានន័យថាម៉េច?

**ស៖** ឥឡូវខ្ញុំសូមសួរមួយជំហានម្តងមើល៍។ យើងមើលទៅ ERN ជាភាសាខ្មែរ 0032468 -- 91 ដល់ 92, អង់គ្លេស 00170708 នៅទំព័រទី១៤, ជាភាសាបារាំង 00648971។ នៅទំព័រខាងលើនោះ នេះជាភាសាអង់គ្លេស គឺនៅខែកុម្ភៈ ១៩៧០ -- ១៩៨០ ប្រភពព័ត៌មានគឺបង្ហាញឈ្មោះរបស់លោក។ តើលោកឃើញទេលោក?

**ឆ៖** បាទ ឃើញ។

**ស៖** ព័ត៌មានថា "ខ្ញុំជាអ្នករក្សាបណ្ណសារនៅទួលស្លែង រយៈពេល២ខែ ចាប់ពីដើមខែសីហា រហូតដល់ពេលដែលខ្ញុំចាកចេញពីទីក្រុងភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៩"។ នេះគឺជាសម្តីរបស់លោកយ៉ាងហោចណាស់ គឺក៏គាត់បានសរសេរថា លោកបានប្រាប់ទៅគាត់ថា លោកបានធ្វើការនៅបណ្ណ-សារដ្ឋាន គឺនៅទួលស្លែងនោះនៅពេលនោះ។ តើត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយបាទ។

**ស៖** ហើយនៅត្រង់ចំណុចដដែលនេះលោកបន្តនិយាយថា "ក្នុងដើមខែសីហា ១៩៧៩ វៀតណាមបានរៀបចំកាត់ទោស ប៉ុល ពត ហើយពួកវៀតណាមគឺត្រូវឲ្យខ្ញុំពិនិត្យមើលបណ្ណសារទាំងនោះ។ ដូច្នេះខ្ញុំក៏បានទៅធ្វើការបណ្ណសារដ្ឋាននៅទួលស្លែង ហើយទទួលបានអង្ករបីកំប៉ុង ក្នុង១ថ្ងៃសម្រាប់ការងារនោះ"។ បាទ ខ្ញុំសូមផ្អាកត្រឹមនេះសិន។ នៅពេលនោះ តើលោកបានដឹងថានឹងមានការកាត់ទោសដែរឬទេ? ហើយបើដឹងថាតើអ្នកណាខ្លះ ដែលគេត្រូវកាត់ទោសនោះ?

[១១:២០:៣៣]

**ឆ៖** កាត់ទោស -- ការកាត់ទោស តាមខ្ញុំចាំមានពីរនាក់ មាន ប៉ុល ពត និង អៀង សារី។

**ស៖** នៅពេលដែលមានការជំនុំជម្រះទោសនោះ លោកចាំថា មានការជំនុំជម្រះទោសនៅពេលណាដែរទេ?

**ឆ៖** ខ្ញុំមិនចាំថ្ងៃខែណាច្បាស់លាស់ទេ ប៉ុន្តែពេលដែលខ្ញុំធ្វើការនៅមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។

**ស៖** លោកបានជម្រាបថា លោកបានជួយធ្វើការបកប្រែ ដល់អ្នកដែលត្រូវមកពិនិត្យមើលទៅលើឯកសារទាំងអស់នេះ។ យើងដឹងថា មានការកាត់ទោសពីតាំងពីថ្ងៃទី១៨ ទៅដល់ ១៩ សីហា ១៩៧៥ តាមដែលលោកចាំតើអំឡុងពេលនេះ គឺវាត្រឹមត្រូវដែរឬទេ?

**ផ៖** ខ្ញុំមិនប៉ាននធានា ប៉ុន្តែខ្ញុំប្រហែលជាអ៊ីចឹងហើយបាទ។

**ស៖** ហើយតាមដែលខ្ញុំចាំបាន សក្ខីកម្មរបស់លោកពីសប្តាហ៍មុន គឺលោកអះអាងថា លោកមិនបានដឹងថា សវនាការធ្វើនៅទីកន្លែងណាទេ។ លោកបានស្មានថា អាចនៅកន្លែងណាមួយក្នុងទីកន្លែងពីរកន្លែង។ តើនៅពេលនោះ ដែលលោកនៅភ្នំពេញ ដែលជាសវនាការមួយយ៉ាងធំនេះ គឺលោកបានជួយទៅដល់វៀតណាម ដើម្បីរៀបចំសវនាការនេះ ប៉ុន្តែលោកមិនបានដឹងសវនាការនោះ ថាធ្វើនៅកន្លែងណាទេ។ តើលោកចាំថាអ៊ីចឹងទេ?

[១១:២២:៤៣]

**ផ៖** បាទ ខ្ញុំបាន -- ខ្ញុំមិនចាំថា ធ្វើកន្លែងណាពិតប្រាកដ។ ខ្ញុំភ្លេចទៅបាទ។

**ស៖** តើលោកបានចូលរួមការជំនុំជម្រះហ្នឹងទេ?

**ផ៖** ខ្ញុំអត់បានចូលទេបាទ។

**ស៖** តើលោកអាចរៀបរាប់ប្រាប់ខ្ញុំបានទេ តើលោកបានជួយទៅដល់ពួកខាងវៀតណាមអ្វីខ្លះដើម្បីការជំនុំជម្រះបែបនេះនោះ?

**ផ៖** ខ្ញុំបានៗជួយរៀបចំសំណុំរឿងខ្លះ ហើយនិងៗបកប្រែជាភាសាបារាំង នូវសារភាពរបស់ជនដែលគេសម្លាប់ហើយខ្លះ ប៉ុន្តែខ្ញុំមិនចាំថា ខ្ញុំជួយបកសារភាពណាខ្លះទេបាទ។

**ស៖** តើអ្នកណាជាអ្នកជ្រើសរើសចម្លើយសារភាព? លោកនិយាយថា លោកបានជួយក្នុងការរៀបចំឯកសារ តើលោកចូលរួមក្នុងកម្រិតណា ទាក់ទងទៅនឹងការរៀបចំសវនាការរយៈពេល៤ថ្ងៃនេះនោះបាទ?

**ផ៖** ជាក់ស្តែងខ្ញុំបានធ្វើ គ្រាន់តែថា ក្នុងកម្រិតថាគេឲ្យខ្ញុំជួយបកប្រែ ខ្ញុំជួយបកប្រែទៅជាមួយបងប្អូនយើងមួយចំនួនទៀត ដែលធ្វើការជាមួយគ្នានៅពេលនោះ។

[១១:២៤:៥៧]

**ស៖** បាទ ជាមួយពួកវៀតណាម តើលោកនិយាយភាសាវៀតណាម ឬក៏លោកនិយាយភាសាបារាំង ឬក៏និយាយភាសាខ្មែរ ឬក៏មាននិយាយភាសាអ្វីទេ? បាទ អង់គ្លេសមានប្រើទេ?

**ឆ៖** អ្នកដែលមក -- ខ្ញុំមិនចាំឈ្មោះគាត់ ប៉ុន្តែអ្នកដែលមកទាក់ទងដើម្បីបកហ្នឹងជាអ្នក -- ជាខ្មែរបាទ មិនមែនៗវៀតណាមទេ។ តាមបើខ្ញុំចាំច្បាស់គឺអ្នក -- អង្កាល់ហ្នឹងដូចជាលោក កែវ ចិន្តា គាត់អ្នកទទួលខុសត្រូវធំ ប៉ុន្តែមានសហការីគាត់មកជួបពួកខ្ញុំផ្ទាល់។ ប៉ុន្តែខ្ញុំអត់ចាំឈ្មោះ ភ្លេចឈ្មោះហើយ គាត់អ្នកសហការីដែលមកៗជួបខ្ញុំពេលនោះ។

**ស៖** បាទ ខ្ញុំចង់ឲ្យលោកបំភ្លឺចំណុចៗមួយចំនួនទាក់ទងទៅនឹងចម្លើយ និងសក្ខីកម្មរបស់លោកដែលលោកអាចបាននិយាយជូនសារព័ត៌មាន។ យើងបានឃើញនៅក្នុងឯកសារមួយនេះគឺ D108/27.19 លោកនិយាយថា៖ "នៅចាប់ផ្តើមខែសីហា -- ដើមខែសីហា នៅពេលដែលបានចាប់ផ្តើមធ្វើការនៅទួលស្លែងកាលនោះ"។

[១១:២៦:២៤]

ឥឡូវនេះយើងមើលសក្ខីកម្មរបស់លោកនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ នេះ ខ្មែរ 00832589, ហើយនិងភាសាអង់គ្លេស ទំព័រ១០៤ ជាសេចក្តីព្រាង បារាំង១១៤ ជាសេចក្តីព្រាងប្រតិចារឹក។ នៅកន្លែងនេះលោកនិយាយថា៖ "ខ្ញុំបានត្រឡប់មកភ្នំពេញ ខែឧសភា ឬមិថុនា ឆ្នាំ៧៩។ នៅពេលនោះខ្ញុំបានទៅទួលស្លែង ដែលគេហៅថាស-២១ ហើយខ្ញុំបានធ្វើការនៅទីនោះក្នុងមួយរយៈពេល"។ ឥឡូវនេះខ្ញុំត្រូវតែឲ្យប្រាកដជាមួយលោក តើលោកនិយាយថា នៅពេលដែលលោកមកដល់ភ្នំពេញនៅខែឧសភា មិថុនា ឬក៏លោកនិយាយថា នៅក្នុងផ្នែកនៃចម្លើយនេះ គឺថាលោកបានទៅទួលស្លែងខែឧសភា ឬក៏មិថុនា ឆ្នាំ១៩៧៩ ដែលអាចនឹងជាខែសីហា ឆ្នាំ១៩៧៩ តើកាលបរិច្ឆេទណាមួយដែលត្រឹមត្រូវនោះ?

[១១:២៧:៥៤]

**ឆ៖** ខ្ញុំមិនចាំមិនច្បាស់ទេ ប៉ុន្តែខ្ញុំធ្វើការប្រហែលជាងពីរខែ។ ប៉ុន្តែខ្ញុំចាំច្បាស់អាចអះអាងខែ -- គឺថ្ងៃដែលខ្ញុំចេញពីភ្នំពេញ ខែដប់មួយ ប៉ុន្តែខ្ញុំរយៈពេលធ្វើការ -- ខ្ញុំចូលធ្វើការនៅទួលស្លែងថ្ងៃណាខ្ញុំអត់ -- ខ្ញុំភ្លេចអស់ហើយបាទ។

**ស៖** បាទ នៅក្នុងចម្លើយរបស់លោក ដែលលោកបានឆ្លើយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ លោកចង្អុលបង្ហាញថា ឯកសារ E3/97 ខ្មែរERN 00270697 ដល់ 99, អង់គ្លេស 00287107, បារាំង 00241890 ដល់ 01 -- ដល់ 91 បាទ បារាំង "តើលោកធ្វើការនៅទួលស្លែងខែសីហា ដល់ខែវិច្ឆិកា? ការងាររបស់ខ្ញុំគឺរៀបចំបញ្ជីដែល -- មនុស្សដែលបានបាត់ខ្លួន ហើយបកប្រែចម្លើយសារភាពឲ្យទៅជាភាសាបារាំង ហើយនិងត្រៀម -- ដើម្បីត្រៀមរៀបចំការជំនុំជម្រះនៅឆ្នាំ១៩៧៩"។ ហើយ

លោកបាននិយាយបែបនេះទៅឲ្យលោក ក្នុងសម្ភាសជាមួយ ស៊ីវ ហេងឆ័រ។

[១១:២៩:៣៣]

ឥឡូវនេះនៅក្នុងចំណុចនេះគឺមានរបាយការណ៍មួយ ដែលបានផ្តល់សម្ភាសនៅក្នុងឆ្នាំ២០០៦ ដែលលោកបានចង្អុលបង្ហាញថាៈ “ប្រហែលជាអាចនៅក្នុងខែកក្កដា ឆ្នាំ១៩៧៩ ដែលលោកបានជួប ចម្លើយសារភាព ដែលគេបានប្រើយកមកខ្ចប់នំចេកចៀន ហើយលោកបានិយាយថា -- ហើយក៏លោកបានបញ្ឈាក់រឿងហ្នឹង នៅកាលនោះ។ តើលោកនៅចាំពីរឿងហ្នឹងទេ?

**ប្រធានអង្គជំនុំៈ**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៣០:២៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

បាទ សូមអរគុណលោកប្រធាន។ ខាងការពារក្តីលើកប្រភពឯកសារមួយ ដែលអត់មានអត្តសញ្ញាណត្រឹមត្រូវ ប្រហែលជាពុំមាននៅក្នុងសំណុំរឿងទេ។ ហើយសំណួរនេះ ផ្តោតលើតែអ្វីដែលសាក្សីបានផ្តល់ចម្លើយហើយ។ ហើយប្រភពឯកសារនេះ អត់មានលេខកូដ អត់មានអីទេ លោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាសៈ**

**សៈ** តើលោកចាំថាប្រាប់ខ្ញុំទេ លោកសាក្សី? របៀបដែលលោកបានទៅដល់ ស-២១ គឺថានៅថ្ងៃមួយ លោកបានឃើញចម្លើយសារភាពមួយ ដែលគេយកទៅខ្ចប់ បាទ គេយកទៅខ្ចប់នំចេកចៀន តើលោកនឹកឃើញរឿងហ្នឹងទេ?

**ប្រធានអង្គជំនុំៈ**

សាក្សីមិនបាច់ឆ្លើយតបទេ។ សំណួរនេះ សំណួរច្រំដែលទេ។ សាក្សីឆ្លើយរួចហើយ មើលប្រតិចារឹក។

[១១:៣១:២៦]

**សួរដោយលោក ម៉ៃខល កាណាវាសៈ**

**សៈ** បាទ ខ្ញុំសូមឲ្យតុលាការ -- ឲ្យលោកបំភ្លឺលោកទៅ ស-២១ ថាតើគេយកចម្លើយសារភាពហ្នឹង ទៅខ្ចប់នំចេកចៀន ឬក៏លោក -- តើមានអ្នកណាម្នាក់ គេប្រាប់ឲ្យលោកទៅធ្វើការនៅ ស-២១

ថាតើលោកទៅទីនោះ ដោយរបៀបណា មកពីចាប់អារម្មណ៍ថាឃើញចម្លើយសារភាព គេយកខ្ចប់ចេក ចៀន បានទៅធ្វើ ឬក៏អ្នកណាមកប្រាប់លោកឲ្យទៅកន្លែងនោះ?

[១១:៣២:១០]

**លោក អុង ថុងហឿង៖**

**ឆ៖** ខ្ញុំសូមឆ្លើយលោកមេធាវី គឺពេលនោះ ខ្ញុំ ថ្ងៃខែ ខ្ញុំអត់ចាំទេ ប៉ុន្តែខ្ញុំនៅផ្សារទួលទំពូង ខ្ញុំបាន ទិញចេកចៀន ហើយខ្ញុំឃើញឈ្មោះមិត្តខ្ញុំម្នាក់ដែលខ្ញុំស្គាល់ គាត់ឈ្មោះ គឺឈ្មោះ កុល ដូរាធី។ ហើយ ដូច្នេះ ដល់ខ្ញុំឃើញដូច្នេះ ខ្ញុំចង់ដឹងថា ប្រភពដែលក្រដាសនោះមកពីណា ហើយខ្ញុំបានសួរគេទៅ គេថា មកពីទួលស្លែង។ ដូច្នេះ ដោយមូលហេតុធំ ខ្ញុំចង់ដឹង តើអ្វីទៅដែលប្រភពហ្នឹងចេញពីណាមក? ហើយ វាយ៉ាងម៉េចរឿងអស់ហ្នឹង? កាលនោះ ខ្ញុំមិនដឹងថា ខ្ញុំអត់មានការចាប់អារម្មណ៍ថាមាន អេសវ៉ាំងតេអង ឬទួលស្លែងនោះយ៉ាងម៉េចទេ។ ឃើញដូច្នេះទៅបានខ្ញុំទៅ។ នេះជាគោលបំណងខ្ញុំ គឺចង់ៗបានដឹងឲ្យ ច្បាស់ថាតើមិត្តភក្តិរបស់យើងខ្ញុំដែលបាត់ទៅហ្នឹង គឺបាត់នៅកន្លែងណា។ អាហ្នឹង គឺជាគោលបំណង របស់ខ្ញុំពេលនោះ។

[១១:៣៣:២៤]

**ស៖** បាទ នេះហើយជាចំណុច ដែលខ្ញុំចង់ឲ្យលោកបំភ្លឺ។ ឥឡូវនេះ លោកបានឆ្លើយថា គឺលោកខ្លួនឯង ផ្អែកទៅលើក្រដាសដែលគេខ្ចប់ចេកចៀន ដែលលោកចង់ស្វែងទួលស្លែង ហើយ ស៊ីរិន ហេដឌ័រ នៅខែកុម្ភៈ ឆ្នាំ -- អ៎! ២៩ ១៩៨០ លោកនិយាយថា វៀតណាមបានត្រៀមរៀបចំកាត់ទោស របបខ្មែរក្រហម ហើយគេចង់ឲ្យមានការរៀបចំបណ្ណសារ ឯកសារនៅទួលស្លែង ហើយជាចំណុច ដែលលោកទៅធ្វើការនៅទីនោះ។ ថាតើលោកប្រាប់ខ្ញុំបានទេ តើខ្លឹមសារមួយណា ជាខ្លឹមសារត្រឹមត្រូវ ដែលផ្ទុះបញ្ចាំង ដែលថានាំឲ្យលោកទៅទួលស្លែងនោះ ទៅធ្វើការនៅទួលស្លែងនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ភាគីការពារក្តី ខ្ញុំចង់បង្ហាញថា មានសំណៅពីរផ្ទុយគ្នា ក៏ ប៉ុន្តែតាមការពិតទៅ គឺសំណៅទាំងពីរនេះ វាស៊ីគ្នា ហើយគ្រាន់តែថាមាន -- អ៊ឺចឹង មានហេតុផល ប្រហែលជាទាំងពីរហ្នឹង ដែលអាចឲ្យគាត់ទៅធ្វើការនៅទួលស្លែង។

អ៊ីចឹងហើយកាលណា យើងបែងចែកសំណៅទាំងពីរនេះ ឲ្យខុសគ្នានេះ។ នេះ ជាការមិនត្រឹមត្រូវនោះទេ។

[១១:៣៥:០០]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ក្រៅពីការជំទាស់ដែលមិនត្រឹមត្រូវទាក់ទង គឺថាដែលថាសាក្សីលោកមានបំណងនឹងឆ្លើយ ប៉ុន្តែសហព្រះរាជអាជ្ញាជំទាស់។ ខ្ញុំសូមជម្រាបតុលាការថា នេះគឺជាជំហរដ៏ត្រឹមត្រូវ ដែលមេធាវីធ្វើបែបនេះ។ ហើយខ្ញុំគោរពទៅតាមគោលការណ៍វិជ្ជាជីវៈ។ ខ្ញុំមានសិទ្ធិ សុំឲ្យមានការបំភ្លឺពីសាក្សីដោយខ្លួនឯង។ សហព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង គឺថាតើខ្លួនត្រូវធ្វើដូចម្តេច? មិនចាំបាច់រំឭកមេធាវីនៅពេលនេះនោះទេ។ ដូច្នេះគាត់បានឆ្លើយចម្លើយពីរ ទី១ថា វៀតណាមគាត់មកជួបគាត់។ ទី២ គាត់បានឃើញក្រដាសខ្ទប់ចេកចៀន ដែលនាំឲ្យថាគាត់អាចជាកត្តានាំឲ្យគាត់ចង់ធ្វើការនៅទីនោះ។ បាទ ឬថាដែលថាតើយើងត្រូវទទួលយកអំពីសេចក្តីដកស្រង់ ថាអ្វីដែលកូនក្តីរបស់ខ្ញុំអាចនិយាយ៣០ឆ្នាំមកហើយ។ ហើយខ្ញុំមិនគិតថាសហព្រះរាជអាជ្ញាក្រោកឈរឡើងដើម្បីជំទាស់ ដើម្បីផ្តាច់សាក្សីនៅក្នុងចំណុចនេះ ដែលថាគាត់បម្រុងនឹងផ្តល់ចម្លើយ ដែលជាសក្តានុពលស្វែងរកការពិតនៅក្នុងករណីនេះបាទ។

[១១:៣៦:២៨]

**ប្រធានអង្គជំនុំ៖**

ជាគោលការណ៍គឺសេចក្តីជំទាស់អាចធ្វើតែម្តងបាន មិនអាចធ្វើពីរដងបានទេ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើដូច្នេះឡើយ។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយលោកមេធាវី។ សេចក្តីជំទាស់មិនច្បាស់លាស់របស់តំណាងសហព្រះរាជអាជ្ញាគ្មានប្រសិទ្ធភាព។

**លោក អ៊ុង ឆុងហៀង៖**

**ឆ៖** ខ្ញុំគឺដែលច្បាស់ក្នុងខ្លួនខ្ញុំហ្នឹងគឺថា ដល់ខ្ញុំបានឃើញសំណុំរឿងហ្នឹង ក៏ខ្ញុំទៅទួលស្លែង ដល់ទៅទួលស្លែងទៅ ក៏ពេលនោះដឹងថានៅនៅទួលស្លែងនោះ គេត្រូវការមនុស្ស។ ដល់គេរៀបចំត្រូវការអ្នកថ្មីធ្វើការ ដោយសារគេរៀបចំធ្វើតុលាការកាត់ក្តី ប៉ុល ពត, អៀង សារី។ ដូច្នេះគឺ ដល់ខ្ញុំបានឃើញក្រដាសហ្នឹងហើយ បានខ្ញុំទៅទួលស្លែង។ អាហ្នឹងដែលខ្ញុំតែងតែនិយាយអ៊ីចឹងតាំងពីដើមមក។

[១១:៣៧:៣៩]

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** សូមអរគុណ។ ឥឡូវនេះ នៅពេលដែលលោកចូលទៅដល់ទួលស្លែង តើលោកនៅចាំអ្វីខ្លះ លោកអាចប្រាប់តុលាការបានទេ ថាតើមានអ្នកយាម ឬក៏កន្លែងដែលបើកចំហ អ្នកណាក៏ចូលបានដែរ ហើយថាតើមានឯកសារអ្វីខ្លះនៅទីនោះ ពេលដែលលោកទៅដល់នោះ? បាទ ហើយយើងសួរសំណួរឡើងវិញដោយសារថា ការបកប្រែមិនត្រឹមត្រូវ។ នៅពេលដែលលោកទៅទួលស្លែង តើលោកអាចនៅចាំដែរឬទេ? លោកប្រាប់ខ្ញុំបានទេ? ថាតើៗអ្នកយាម តើលោកត្រូវសុំការអនុញ្ញាតចូល ដើម្បីទៅមើលឯកសារ? ឬតើមានអ្នកយាម ឬមិនមានអ្នកយាមទាក់ទងទៅនឹងករណីលោក ថាលោកអាចដើរបានចូលទៅដោយសេរី ហើយអ្នកផ្សេងក៏អ៊ីចឹងដែរឬទេ ទៅមើលឯកសារនោះ?

[១១:៣៨:៤៧]

**ឆ៖** ខ្ញុំទៅដល់មុនដំបូង ខ្ញុំមិន -- តាមខ្ញុំចាំគឺមិនសេរីទេ មិនអ្នកណាចូលបានស្រេចចិត្តទេ។ ហើយដែលខ្ញុំ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំចូលទៅ ហើយក៏ខ្ញុំជួបអ្នកស្គាល់ ហើយគេទទួលខ្ញុំទៅ ហើយៗគេឲ្យៗខ្ញុំហ្នឹង ដែលទៅជួបលោក ម៉ៃឡាំ គាត់ៗពេលនោះគាត់ជាអ្នកទទួលខុសត្រូវនៅទួលស្លែងនោះបាទ។

**ស៖** សូមអរគុណ។ តាមអ្វីដែលខ្ញុំយល់ គឺថាបន្ទាប់មកពីការងារនោះ តើលោកមិនបានបន្តអនុវត្តការស្រាវជ្រាវចម្លើយសារភាពនៅស-២១ ហើយលោកបានជួយក្នុងការបកប្រែនូវចម្លើយសារភាពមួយចំនួន។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទអ៊ីចឹងមែនហើយ។

**ស៖** នៅក្នុងការសិក្សា សរសេរអត្ថបទរបស់លោកគឺថា របស់ ឡូរ៉ា សាំម៉ី តើលោកដឹងពីរឿងហ្នឹងដែលឬទេ?

**ឆ៖** បាទខ្ញុំបានស្គាល់ ឡូរ៉ា សាំម៉ី ។ ធ្លាប់មានការទាក់ទងគាត់យូរហើយ។

**ស៖** តាមពិតលោកបានបកប្រែចម្លើយសារភាពស-២១ ឲ្យទៅគាត់ហ្នឹង ឬក៏ធ្វើការជាមួយគាត់ តើមែនឬទេ?

**ឆ៖** ពេលខ្ញុំមានពេល ខ្ញុំធ្លាប់បានជួយគាត់ និងជួយអ្នកផ្សេងទៀតក៏ខ្ញុំធ្លាប់បានជួយដែរ ជួយបកប្រែតទៀត។

**ស៖** សំណួររបស់ខ្ញុំពេលនេះគឺថា តើលោកអាចមានលទ្ធភាពទៅមើលចម្លើយសារភាពស-២១

ដោយរបៀបណា? តើនៅក្នុងសម័យពេលដែលលោកធ្វើការនៅក្នុងផ្នែកបណ្ណសារ ហើយនិងបកប្រែឲ្យវៀតណាម ឬក៏នៅពេលណាមួយខុសពីពេលហ្នឹង?

**ឆ៖** ខ្ញុំធ្វើការបកប្រែឯកសារដែលមាននៅទួលស្លែងហ្នឹង បន្ទាប់ពីខ្ញុំបានទៅដល់បរទេសហើយ។ ពេលនៅក្នុងស្រុកខ្ញុំអត់ដែលបានធ្វើឲ្យពួកក្រៅពីធ្វើឲ្យតុលាការកាត់ទោស ប៉ុល ពត, អៀង សារី ទេ។

[១១:៤២:១១]

**ស៖** សូមអរគុណ។ ខ្ញុំសួរថាតើ លោកនិយាយពីឆ្នាំណាដែលលោកបកប្រែចម្លើយសារភាពហ្នឹង? ក្នុងការជួយអ្នកផ្សេងទៀត ជាដើមហ្នឹង?

**ឆ៖** ខ្ញុំចង់និយាយចាប់ពីឆ្នាំ១៩៨០ ទៅ។

**ស៖** តាមដែលខ្ញុំយល់ លោកមិនបាននៅប្រទេសកម្ពុជាទេកាលណោះ ហើយបើសិនជាខ្ញុំចាំតាមត្រឹមត្រូវនោះគឺអ៊ីនធឺណេតគឺមិនធ្វើការទេ យើងមិនមានអ៊ីម៉ែលតាមប្រព័ន្ធអេឡិចត្រូនិក ហើយយើងមិនមានឯកសារទេ។ ថាតើលោកមានលទ្ធភាពទទួលបាននូវចម្លើយសារភាពនៅកន្លែងដែលលោកធ្វើការនោះបានដោយរបៀបណា? តើគេផ្តល់ឲ្យលោកហ្នឹងដោយរបៀបណា? ឬក៏លោកយកចម្លើយសារភាពហ្នឹងជាមួយលោក ហើយនៅពេលដែលលោកចាកចេញពីការងារនៅក្នុងបណ្ណសារហ្នឹងទៅលោកយកទៅជាមួយ?

**ឆ៖** ខ្ញុំ ពេលខ្ញុំចេញពីប្រទេសកម្ពុជាពេលនោះ ខ្ញុំយកឯកសារមួយចំនួន ជាមិត្តភក្តិ ឬបងប្អូនជិតដិតរបស់ខ្ញុំ ដែលមានកូពី ខ្ញុំយកទៅមួយចំនួនដាក់ជាមួយខ្ញុំទៅប្រទេសថៃ។

[១១:៤៣:៥៨]

**ស៖** នៅពេលដែលលោកនិយាយពីឯកសារ តើលោកនិយាយពីឯកសារដែលទទួលបានពីស-២១ ដែលលោកយកទៅជាមួយលោក។ តើអ៊ីចឹងឬ?

**ឆ៖** បាទ។ ប៉ុន្តែខ្ញុំយកឯកសារណាដែលវាមានច្រើន មានៗគេធ្វើច្រើនកូពី។

**ស៖** តើលោកធ្លាប់ប្រគល់ឯកសារហ្នឹងមកឲ្យវិញ មកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឲ្យគេទុកក្នុងបណ្ណសាររបស់គេទេ?

**ឆ៖** ខ្ញុំមិនដែលប្រគល់មកវិញទេ ពីព្រោះឯកសារទាំងអស់ហ្នឹងវាមិន -- គឺមាន -- អត់មានគឺវាមាននៅ -- គឺខ្ញុំយកទៅ គឺអ្វីដែលមានកូពី។ អ្វីដែលអត់មានកូពី ខ្ញុំអត់យកទៅទេបាទ។

[១១:៤៥:០០]

**សៈ** នៅពេលដែលលោកនិយាយថាច្បាប់ដើម តើមានម៉ាស៊ីនថតចម្លង ដើម្បីប្រើថតចម្លង ឬក៏កត់ចម្លងជាអក្សរដៃ ឬក៏ដែលថាលោកមានច្រើនច្បាប់ហ្នឹង តើជារបៀបម៉េច លោកពន្យល់បានទេ? ឬក៏មានវាយជាអង្គុយលីលេខ?

**ផៈ** ខ្លះជាអង្គុយលី ខ្លះជា -- ខ្លះអក្សរដៃ ប៉ុន្តែខ្ញុំយកតែស្ទីដែលមានគេដាក់កាបោនៗ គឺ ហើយខ្ញុំយកកូពី ខ្ញុំអត់យកៗឯកសារដើមទៅ គឺខ្ញុំយកស្ទីដែលចេញមកពីឯកសារដើម។

**សៈ** ខ្ញុំមានសំណួរពីរបីទៀតទាក់ទងទៅនឹងបញ្ហាទូទៅនេះ តាមរយៈការអាន ហើយលោកបានអានចម្លើយសារភាពស-២១ ហើយលោកបានធ្វើការឲ្យក្រុមវៀតណាម ហើយលោកយកចម្លើយសារភាពមួយចំនួនជាច្បាប់ចម្លង ហើយលោកបានជួយក្នុងការបកប្រែដូចជាបកប្រែទៅឲ្យ សាំម៉ី តើត្រឹមត្រូវដែរឬទេនៅក្នុងអំឡុងឆ្នាំនោះ? លោកបានអានឯកសារជាច្រើនដែលយកចេញមកពីការសិក្សាស្រាវជ្រាវព័ត៌មានរបស់លោកទាក់ទងទៅនឹងហេតុការណ៍ ដែលកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

[១១:៤៦:៤៦]

**ផៈ** ខ្ញុំៗសូមបញ្ជាក់ថា ខ្ញុំយកប្រហែលជា ៥ឯកសារ។ ខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែថ្ងៃក្រោយមកដល់នៅជំរំជនភៀសខ្លួននៅប្រទេសថៃ ស្ទីវ ហេដឌ័រ គាត់បានជួបខ្ញុំ ហើយក៏គាត់ចង់ដឹងរឿងហ្នឹងច្បាស់លាស់ក៏គាត់ទៅស្រុកខ្មែរ ហើយគាត់ទិញៗម៉ាស៊ីនកូពី យកទៅប្រគល់ឲ្យមន្ទីរអេសវ៉ាំងតេអង់ ហើយក៏គាត់យកឯកសារហ្នឹងមួយចំនួនច្រើនមកឲ្យខ្ញុំទៀត ដើម្បីឲ្យខ្ញុំជួយបកប្រែឲ្យ ឡូរ៉ា សាំម៉ី ផង, ឲ្យអ្នកផ្សេងៗទៀតផង, ឲ្យអ្នកស្រាវជ្រាវផ្សេងៗ ឬក៏អ្នកនិពន្ធផ្សេងទៀត។ គឺបន្ទាប់ឯកសារដែលខ្ញុំបានក្រោយគឺ លោក -- បន្ទាប់ពីលោក ស្ទីវ ហេដឌ័រ ពេលនោះគាត់ទៅភ្នំពេញហើយគាត់ទិញៗម៉ាស៊ីនកូពីតាមខ្ញុំចាំយកទៅប្រគល់ឲ្យមន្ទីអេសវ៉ាំងតេអង់ហ្នឹង ហើយគាត់ -- ហើយខ្ញុំបានទទួលឯកសារហ្នឹងជា -- រហូតដល់សព្វថ្ងៃហ្នឹង យូរៗខ្ញុំក៏បានទទួលដែរ ពីព្រោះគេចង់ឲ្យខ្ញុំជួយបកប្រែឲ្យ។

[១១:៤៧:៥៦]

**សៈ** បាទ ហើយខ្ញុំគិតថា ការងារទាំងអស់ តើលោកអាចប្រាប់ខ្ញុំបានទេថា តើការអានចម្លើយសារភាពហើយនិងការបកប្រែឯកសារទាំងនោះជួយឲ្យលោកយល់ ការចេះដឹងពីរឿងហ្នឹង ដែលកើតឡើងក្នុងសម័យកាលហ្នឹង គឺលោកដឹងពីការងារហ្នឹង ដោយសារលោកធ្វើការងារហ្នឹង?

**ផៈ** តាមខ្ញុំយល់ គឺការនេះៗគឺជាការដែលខ្ញុំៗអានឯកសារដែលបានមកពីការទារុណកម្ម

ដូច្នេះខ្ញុំអានក្នុងឋានៈជា -- ខ្ញុំមិនជឿការនិយាយទាំងអស់ទេ ប៉ុន្តែខ្ញុំអានយកអ្វីដែលសំខាន់សម្រាប់ឲ្យខ្ញុំយល់ព្រឹត្តិការណ៍នៅកម្ពុជាប្រជាធិបតេយ្យ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងផ្តោតទៅលើឯកសារដែលកំពុងតែពិភាក្សានេះគឺ D108/27.19។ ខ្ញុំចង់សួរសំណួរលោកពីអ្វីដែលខុសពីខាងដើមនេះទេ។ អត្ថបទខ្មែរគឺ 00324691 ដល់ 92, អង់គ្លេស 00170705, បារាំង ERN 00648971។ លោកបាននិយាយនៅកន្លែងនេះថា បុគ្គលម្នាក់នេះមកជួបខ្ញុំ ហើយចូលខ្ញុំឲ្យចូលប្រជុំក្នុងការប្រជុំទី២ ជាមួយលោក ហេង សំរិន ដែលឲ្យចូលរួមជាមួយគណៈមជ្ឈិមរបស់រណសិរ្ស ហើយខ្ញុំបានធ្វើដូច្នោះ។ ហើយខ្ញុំចង់ឲ្យលោកបានបំភ្លឺខ្ញុំថា តើៗគណៈមជ្ឈិមរបស់រណសិរ្សនោះ តើជាគណៈមជ្ឈិមអ្វី? ហើយលោកជាសមាជិករយៈពេលប៉ុនណា ហើយមានការទទួលខុសត្រូវអ្វីខ្លះ ប្រសិនបើមាននោះ?

**ឆ៖** ខ្ញុំចាំ ខ្ញុំបាននិយាយ ថាពេលខ្ញុំនៅធ្វើនៅទួលស្លែងនោះ មានអ្នកជំនាញការវៀតណាមគេបានមកធ្វើការទាក់ទាញខ្ញុំឲ្យទៅធ្វើការក្នុងគណៈមជ្ឈិម ប៉ុន្តែខ្ញុំអត់បានធ្វើទេបាទ។

**ស៖** ខ្ញុំចង់សួរថា ទំព័រ -- ដើម្បីឲ្យខ្ញុំយល់ច្បាស់ទំព័រហ្នឹង គឺនិយាយថា "លោកបានក្លាយជាសមាជិករបស់រណសិរ្សៗ នោះគឺថា -- ប៉ុន្តែសក្ខីកម្មរបស់លោកនោះ លោកក្លាយជាសមាជិក លោកមិនធ្វើការងារអ្វីទេ ដូច្នេះហើយជាមូលហេតុដែលលោកភៀសខ្លួនទៅព្រំដែន តើអ៊ីចឹងដែរឬទេ?

[១១:៥១:៣៦]

**ឆ៖** ខ្ញុំអត់ទទួលស្គាល់ដាច់ខាតនូវការសរសេរនេះ គឺអត់ឈរលើការពិតអ្វីទាំងអស់បាទ។

**ស៖** បាទ ដើម្បីឲ្យខ្ញុំយល់សម្តីលោកឲ្យច្បាស់នោះ លោកបានបដិសេធនូវខ្លឹមសារអត្ថបទរបស់ ស្ទីវ ហេដឌ័រ ដែលគាត់បានកត់ត្រា ដែលគាត់កត់សម្គាល់ថា លោកគឺជាប្រភពនៃព័ត៌មាន។ នេះជាជំហររបស់លោកថ្ងៃនេះ គឺអ៊ីចឹង?

**ឆ៖** ខ្ញុំបាននិយាយជាមួយ ស្ទីវ ហេដឌ័រ ប៉ុន្តែខ្ញុំអត់បាន ដែលបាននិយាយថា ឬក៏អ្នកផ្សេងទៀត ប៉ុន្តែខ្ញុំអត់ដែលបាននិយាយថា ខ្ញុំចូលគណៈមជ្ឈិមអីផង។ ហើយលោកចាំបាច់សួរខ្ញុំអី លោកទៅសួរមើលសំណុំរឿងគណៈមជ្ឈិមទៅ បើខ្ញុំបានចូលឃើញលោកឃើញ បើខ្ញុំអត់ដែលឃើញឲ្យខ្ញុំ -- ឲ្យ--- បញ្ជាក់ថាម៉េច -- លោកចាំបាច់ចំណាយពេលសួរខ្ញុំរឿងហ្នឹងធ្វើអី បើយើងទៅៗរកទៅ ទៅឃើញថាវាមានគណៈមជ្ឈិម -- ធ្លាប់បានធ្វើគណៈមជ្ឈិមមែន លោកឃើញខ្ញុំ ឃើញឈ្មោះខ្ញុំបាត់ហើយ។

[១១:៥៣:០៦]

**ស៖** បាទ ដើម្បីឲ្យខ្ញុំយល់ច្បាស់ តើនេះទាក់ទងទៅនឹងផ្នែកនេះ។ ឯកសាររបស់ ស៊ីវ ហេងឆ័រ គឺជាពិសេសផ្នែកនេះ លោកបានច្រានចោលខ្លឹមសារនេះ ឬក៏លោកបដិសេធទាំងស្រុងទាក់ទងទៅនឹងខ្លឹមសារ ឬក៏បរិបទនេះបាទ?

**ឆ៖** ខ្ញុំសូមបដិសេធត្រង់កន្លែងថា ខ្ញុំដែល ពីណាដែលសរសេរថា ខ្ញុំធ្លាប់ចូលគណៈមជ្ឈិមហ្នឹង ខ្ញុំអត់ដែលមានកិត្តិយសចូលគណៈមជ្ឈិមហ្នឹងទេបាទ។ អាហ្នឹង គឺខ្ញុំសូមថ្លែងការណ៍ដោយដាច់អហង្ការ គឺថា ខ្ញុំអត់ដែលបានធ្វើជាសមាជិកគណៈមជ្ឈិមទេបាទ។

[១១:៥៤:០៦]

**ស៖** បាទ សូមអរគុណ។ ហើយយើងចូលទៅដល់ប្រធានបទថ្មីមួយទៀត ចំណុចនេះគឺទាក់ទងទៅនឹង ហោ ណាំហុង។ លោកបានបញ្ជាក់ពីគាត់នៅក្នុងសៀវភៅរបស់លោក គឺឈ្មោះរបស់គាត់បានឃើញនៅក្នុងសក្ខីកម្មរបស់លោកផងដែរ។ តាមដែលខ្ញុំយល់ពេលដែលស្តាប់សក្ខីកម្មរបស់លោកនោះ លោកនិយាយថា គេត្រូវបានចាត់តាំងគាត់ឲ្យធ្វើជាក្រុម -- អ្នកដឹកនាំក្រុមនៅកន្លែងនោះ តើលោកនៅចាំដែរឬទេ គឺនៅប-៣២?

**ឆ៖** បាទ ខ្ញុំនៅចាំ។

**ស៖** តាមដែលខ្ញុំយល់សក្ខីកម្មរបស់លោកគឺលោកវត្តមាននៅពេល ដែលគេចាត់តាំងឲ្យគាត់ធ្វើជាប្រធានក្រុមនោះ?

**ឆ៖** បាទ។

**ស៖** តាមដែលខ្ញុំយល់នៅក្នុងសក្ខីកម្មរបស់លោក នេះគឺថា នេះគឺជាលើកទី២ ដែលគេចាត់តាំងគាត់ នេះគឺមិនមែនជាតំណែងដែលគេចាត់តាំងលើកទី១ទេ គឺជាលើកទី២ ដែលគាត់ចាត់តាំងនោះ។ តើយ៉ាងម៉េចដែរ?

**ឆ៖** ការចាត់តាំងគាត់លើកទី១ ខ្ញុំអត់នៅទេ ពេលនោះខ្ញុំនៅដីក្រហមឯនោះ។ ពេលខ្ញុំមក ខ្ញុំមានវត្តមាន ពេលគេចាត់តាំងគាត់ជាលើកទី២។

[១១:៥៦:០១]

**ស៖** ឥឡូវនេះតើលោកចាំដែរឬទេ ថាតើនៅក្នុងការប្រជុំនោះដែលគេតែងតាំងគាត់នោះ តើលោក អៀង សារី វត្តមានឬទេ? ខ្ញុំជឿថា លោកឆ្លើយថា “បាទ” ប៉ុន្តែសូមឲ្យលោកបញ្ជាក់លើចំណុចនេះ។

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា លោក អៀង សារី មានវត្តមាននៅទីនោះ។

**ស៖** តាមដែលខ្ញុំយល់សក្ខីកម្មរបស់លោក លោកបាននិយាយថា "នៅឱកាសនោះ លោក អៀង សារី បាននិយាយដដែលៗ ដូចដែលនិយាយពីខាងដើម នៅក្នុងកិច្ចប្រជុំពីខាងមុនៗនោះ ដែលភាគច្រើននោះ លោកៗបាននិយាយនៅក្នុងសក្ខីកម្មរបស់លោក"។

**ឆ៖** --

[១១:៥៧:១៧]

**ស៖** ខ្ញុំមើលអត្ថបទខ្មែរ 0083349 (ស៊ីក) ដល់ 50, អង់គ្លេសទំព័រ៣៨, បារាំង ទំព័រ៤១ ដល់ ៤២ ហើយប្រតិចារឹកថ្ងៃទី០៩ ខែសីហា លោកនិយាយថា "ខ្ញុំ -- ថាលោកកុំឱ្យគេកត់សម្គាល់ ហើយគ្រាន់តែពិនិត្យមើល ហើយគេបានរក្សាទុកគាត់ជាប្រធានរបស់គណៈមួយ ដែលមានគ្នាប្រាំនាក់។ ហើយលោក អៀង សារី ក៏បាននិយាយដូចអ្វីៗ ដូចដែលបានគាត់និយាយខាងដើមដែរ"។ ហើយប្រសិនបើយើងចូលទៅក្នុងផ្នែកមួយទៀតនៃប្រតិចារឹក គឺថាគាត់បានប្រាប់ពីអ្វីៗ ដែលគាត់បាននិយាយនៅក្នុងការប្រជុំទី១។ ខ្ញុំចង់ឱ្យប្រាកដថាលោក ថាតើនៅក្នុងសក្ខីកម្មរបស់លោក ថាតើចំណុចណាមួយដែលពិតជាលោកនៅចាំច្បាស់នោះ?

**ឆ៖** ខ្ញុំចង់និយាយថា លោក អៀង សារី គាត់និយាយដដែលៗ គឺបញ្ជាថា ប្រទេសកម្ពុជានឹងបានទទួលជ័យជម្នះ។ ទី១ ប្រទេសកម្ពុជាកំពុងមានបញ្ហាខ្លាំងជាមួយវៀតណាម ហើយប្រជាជនកម្ពុជានឹងអាចនឹងមានជ័យជម្នះជាចុងក្រោយបំផុត។ ហ្នឹងខ្ញុំចាំជាងគេ គឺចំណុចហ្នឹងបាទ។

[១១:៥៩:០៣]

**ស៖** ចាតើមិនមែនជាករណីហ្នឹងទេឬ លោកសាក្សី? សូមលោកគិតត្រឡប់ទៅក្រោយវិញ តើលោកនៅចាំ នៅដឹងថាលោកនៅបឹងត្របែក គឺតាមការសិក្សាស្រាវជ្រាវ ថាតើដោយដឹងដោយពីការសិក្សារបស់លោក ឬក៏នៅពេលដែលលោកនៅបឹងត្របែក? ដូចជានៅខែតុលា, ខែវិច្ឆិកា ឆ្នាំ១៩៧៨ ជាដើម។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៥៩:៥៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ សំណួរមិនចោទសួរទៅលើអ្វី ដែលសាក្សីបានឮនៅពេលនោះ នោះទេ។ ក៏ប៉ុន្តែក៏ចង់បញ្ជាក់លើការស្រាវជ្រាវ ដែលសាក្សីបានធ្វើពេលក្រោយមកហើយ ហើយដែលថា កន្លែងនេះគឺថា សូមឲ្យសាក្សីនេះ ដើរតួជាអ្នកជំនាញហើយ ដែលឲ្យគាត់ឈរលើមូលដ្ឋាន លើអ្វីដែលគាត់បានស្រាវជ្រាវនៅពេលក្រោយ គឺតែត្រូវ -- តាមពិតទៅត្រូវតែសង្កត់ធ្ងន់លើអ្វីដែលគាត់បានដឹងពីមុនមកនោះទេ វត្តមានគាត់នៅពេលវៀតណាមមកហ្នឹងជាដើមនោះ។

[១២:០០:៣៥]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន អ្វីដែលគិតលើសពីអ្វី ដែលខ្ញុំគិតនោះ ថាយើងចាត់សាក្សីថាអ្នកជំនាញ។ ប៉ុន្តែខ្ញុំសួរគាត់ពីអ្វីដែលគាត់នឹកឃើញនៅកាលនោះ តើគាត់បានដឹងស្ថានភាពនៅកាលនោះដែរឬទេ ថាលោក អៀង សារី បានរៀបរាប់ពីស្ថានភាពរវាងកម្ពុជា និងវៀតណាម ឲ្យគាត់រៀបរាប់តាមបរិបទ ខែតុលា ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ប្រសិនជាគាត់មិនដឹង គឺគាត់ឆ្លើយថា មិនដឹងបាទ។

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** ខ្ញុំដឹងខ្លឹមសារ ដែលនៅចាំ ខ្លឹមសារដែលលោក អៀង សារី -- ខ្លឹមសារមួយចំនួន ដែលលោក អៀង សារី គាត់បាននិយាយនៅពេលនោះ។ ប៉ុន្តែខ្ញុំមិនដឹងថា គាត់និយាយពេលប្រជុំប-៣០ ឬប-៣១ ឬថ្ងៃចន្ទ ឬថ្ងៃអង្គារ ឬថ្ងៃខែនេះ ឬខែនោះ ខ្ញុំៗអត់ចាំទេ។ ប៉ុន្តែខ្លឹមសារមួយចំនួន ដូចខ្ញុំបានបញ្ជាក់ប្រាប់តុលាការហើយ ខ្ញុំធ្លាប់បាននិយាយបញ្ជាក់ហើយថា ខ្ញុំចាំជាខ្លឹមសារមួយចំនួននៅពេលនោះ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១២:០១:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ។ យ៉ាងម៉េចទៅ? លោកត្រូវការពេលវេលាប៉ុន្មានទៀត ដើម្បីជាក់ច្បាស់ ពីព្រោះដល់ពេលសម្រាកហើយ?

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមានសំណួរមួយទៀតលោកប្រធាន តែមួយទេ ហើយខ្ញុំនិយាយសំណួរ មិនមែនប្រធានបទទេបាទ។

**ប្រធានអង្គជំនុំ៖**

តែមួយ ហើយចប់ ឬក៏មួយហ្នឹងសម្រាប់ពេលបាយនេះ ហើយល្ងាចបន្តទៀត?

[១២:០២:៣៦]

**លោក ម៉ៃខល កាណាវាស៖**

ជាសំណួរមួយចុងក្រោយសម្រាប់សាក្សីរូបនេះបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះ លោកសាក្សី លោកបាននិយាយថា ហោ ណាំហុង បានវត្តមាននៅទីនោះ នៅពេលដែលលោក អៀង សារី នៅទីនោះ ដែលគាត់សម្តែងមតិនោះ ហើយលោកក៏វត្តមានដែរ។ តើលោកប្រាប់ខ្ញុំបានទេ ផ្អែកទៅលើការសង្កេតរបស់លោក ដែលលោកផ្ទាល់នៅទីនោះ ថាតើគាត់មានឋានៈជាអ្វី ដែល -- ដូចដែលលោកបានឮពីលោក អៀង សារី ដែរឬទេ? ខ្ញុំមិនឲ្យលោកសន្និដ្ឋានទេ។ ចង់សួរពីលោក ហោ ណាំហុង ថាតើគាត់ត្រូវតែស្តាប់អ្វីពី លោក អៀង សារី ដូចដែលលោកឮដែរឬទេ?

[១២:០៣:៣៥]

**លោក អ៊ុង ចុងហឿង៖**

**ឆ៖** ខ្ញុំ -- អ្វីដែលខ្ញុំឃើញថា លោក ហោ ណាំហុង គាត់ស្តាប់លោក អៀង សារី ហើយលោក អៀង សារី ចាត់តាំងគាត់ធ្វើជាប្រធានប-៣២ គាត់ធ្វើតាមលោក អៀង សារី ហើយខ្ញុំបញ្ជាក់ឡើងវិញ គឺថានេះជាការចាត់តាំងខ្មែរមកពីបរទេសទូទៅ គឺថាប-៣០ ក៏មានខ្មែរបរទេស ក៏ចាត់តាំងអ៊ីចឹងដែរ ប-៣១ ក៏ចាត់តាំងអ៊ីចឹងដែរ។ ហើយនៅជំរំផ្សេងៗដែលខ្ញុំបានរស់នៅ ក៏គេធ្វើរបៀបហ្នឹងដែរ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**លោក ម៉ៃខល កាណាវាស៖**

ក្នុងនាមលោក អៀង សារី ហើយខ្ញុំ និង អាង ឧត្តម ហើយខ្ញុំសូមអរគុណ ដែលលោកបានផ្តល់

សក្ខីកម្ម ហើយសូមអភ័យទោស ប្រសិនបើសំណួររបស់ខ្ញុំ ធ្វើឱ្យលោកមានការលំបាកក្នុងការឆ្លើយ។ សូមអរគុណតុលាការផងដែរ។ ខ្ញុំសូមបញ្ចប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី រសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកពិសាថ្ងៃត្រង់ ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០៥:១១]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ នួន ជា សូមអនុញ្ញាតទៅតាមដានសវនាការល្ងាចនេះនៅបន្ទប់ខាងក្រោមដោយសារគាត់មានជំងឺក្បាល ហើយនិងមិនអាចផ្តង់អារម្មណ៍បាន ហើយនិងឈឺខ្នងផងដែរ។ ហើយយើងខ្ញុំបានត្រៀមលិខិតបោះបង់សិទ្ធិ និងដាក់ជូនតុលាការតាមនីតិវិធី។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយមានបញ្ហាមូលហេតុសុខភាព ដោយមេធាវីបានសន្យាថា នឹងផ្តល់នូវ -- មកឱ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក អៀង សារី។

អង្គជំនុំជម្រះយល់ឃើញថា សំណើនេះមានលក្ខណៈសមស្រប។ អង្គជំនុំជម្រះសម្រេចយល់ព្រមនិងអនុញ្ញាតឱ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់ពេលធ្វើសវនាការពេញ

មួយរសៀលនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដែលមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

[១២:០៦:៣៣]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

ហើយបង្គាប់ឲ្យផ្នែកអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា និងខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់កាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី អ៊ុង ថុងហឿង។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ជម្រាបសួរលោក អ៊ុង ចុងហឿង។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិការពារក្តីលោកខៀវ សំផន។

[១៣:៣២:០៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជាបឋមខ្ញុំសូមជម្រាបជូនលោកថា សំណួររបស់ខ្ញុំនោះមិនវែងទេ ខ្ញុំគ្រាន់តែចង់សួរការបំភ្លឺអំពីលោកមួយចំនួនទៅលើចម្លើយមុនៗរបស់លោក ហើយក៏ខ្ញុំចង់សួរបញ្ជាក់ដែលដកស្រង់ចេញពីសៀវភៅ "ខ្ញុំជឿខ្មែរក្រហម" ដែលលោកសរសេរផ្ទាល់នេះ។ ចំណុចទី១ គឺកាលពីថ្ងៃទី៧ ខែសីហា កន្លងទៅនេះ លោកបានឆ្លើយថា៖ "លោកបានឃើញលោក ខៀវ សំផន ជាលើកទី១ នៅ --

**អ្នកបកប្រែ៖**

អ្នកបកប្រែសូមសួរម្តងទៀត តើនៅទីនេះឬដែលលោកៗឃើញលោកខៀវ សំផន ដោយផ្ទាល់ជាលើកទីមួយនោះ?

**លោក អ៊ុង ចុងហឿង៖**

**ឆ៖** កាលនៅ ខ្ញុំនៅពីក្មេង ខ្ញុំធ្លាប់ឃើញគាត់ម្តង ឃើញគាត់ជិះរថយន្តស៊ីត្រូអែនជាមួយលោក ហ៊ូ យន់។ ខ្ញុំប្រហែលជានៅវត្តលង្កាឯណោះ។ ខ្ញុំឃើញគាត់ពីចម្ងាយ។ អង្កាល់ហ្នឹងខ្ញុំនៅក្មេងតូចនៅឡើយ។ ហើយជាលើកទីមួយហើយដែលខ្ញុំជួបមានវត្តមាន មានកិត្តិយសជួបគាត់លើក នៅទីនេះ។

**ស៖** សូមអរគុណ។ ដើម្បីឲ្យបានច្បាស់នៅក្នុងប្រតិចារឹកសវនាការនោះ តើលោកឯកភាពទេនៅក្នុងការនិយាយថា លោកផ្ទាល់ និងប្រពន្ធរបស់លោក មិនដែលឃើញលោក ខៀវ សំផន ទេនៅបឹងត្របែកនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញគឺថា ខ្ញុំនិងប្រពន្ធខ្ញុំមិនដែលឃើញលោកខៀវ សំផនផ្ទាល់នៅបឹងត្របែកទេ។

[១៣:៣៤:៥៨]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ឥឡូវនេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញជូនលោកសាក្សីនូវឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ គឺ E3/97។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតផ្តល់ឯកសារដើមជាភាសាបារាំង ជូនសាក្សី គឺ ERN ទំព័រពាក់ព័ន្ធ គឺទំព័រ១២ ជាភាសាបារាំង។ ERN 00241889, ERN ជាភាសាខ្មែរ -- ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញឯកសារជាភាសាខ្មែរនេះ ជូនសាធារណជន គឺលេខ ERN 00270701, ជាភាសាអង់គ្លេស 00287109។ ខ្ញុំសូមការអនុញ្ញាតផ្តល់ជូនឯកសារជាភាសាបារាំងជូនលោកសាក្សី។

[១៣:៣៦:១០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ។ ហើយអនុញ្ញាតឲ្យបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ផងដែរ។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកសាក្សី ដើម្បីឲ្យខ្ញុំពន្យល់ឲ្យបានច្បាស់អំពីរបៀបនៃការសួរចម្លើយរបស់ខ្ញុំ។ ខ្ញុំសូមអានសម្រង់ចេញពីឯកសារនេះ នៅទំព័រទី១២ ជាភាសាបារាំង ហើយបន្ទាប់មកទៀត ខ្ញុំនឹងសួរសំណួរដើម្បីចម្លើយពីលោក ពាក់ព័ន្ធនឹងឯកសារនេះ។ ឯកសារ E3/97 នេះ គឺចុះថ្ងៃទី២២ ខែ១១ ឆ្នាំ២០០៨ ដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត នៃសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ ខ្ញុំសូមអានផ្នែកដំបូងនូវចំណុចដែលខ្ញុំចង់លើកឡើងនេះ ផ្នែកដែលពាក់ព័ន្ធនោះ គឺផ្នែកដំបូងនៃចម្លើយរបស់លោក។

[១៣:៣៧:២៥]

“ចៅក្រមស៊ើបអង្កេតប្រាប់លោកថា ខ្ញុំចង់បង្ហាញឲ្យលោកមើលនូវឯកសារមួយ សរសេរជាភាសាបារាំង ដែលតុលាការបានចុះបញ្ជីក្រោមលេខ 00142162។ លោកអាចប្រាប់យើងបានទេ ថាតើលោកព្រមទទួលស្គាល់នូវសេចក្តីថ្លែងការណ៍ដែលមានឈ្មោះលោកនៅក្នុងនោះទេ?” នៅពេលនោះលោកឆ្លើយទៅនឹងអ្នកស៊ើបអង្កេតថា “ខ្ញុំមិនដែលបានឃើញឯកសារនេះ ពីមុនមកទេ ហើយខ្ញុំទើបតែបានដឹងពីឯកសារនេះ ជាលើកដំបូងនេះឯង។ ខ្ញុំបានសង្កេតឃើញមានកំហុសខ្លះៗ ដែលខ្ញុំនឹងជម្រាបលោកឲ្យជ្រាប”។ នេះគឺជាផ្នែកដំបូងនៃចម្លើយរបស់លោក ដែលខ្ញុំអានចង់ឲ្យលោកបានរំឭកការចង

ចាំ។ ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកទី២ នៃចម្លើយរបស់លោក គឺនៅទំព័រដដែលជាភាសាសារាំង ប៉ុន្តែជាភាសាខ្មែរ គឺ ERN មានដូចតទៅនេះ 00270702។ ចំណុចដែលខ្ញុំចាប់អារម្មណ៍នោះ គឺផ្នែកចុងក្រោយនៃចម្លើយរបស់លោក។

[១៣:៣៨:៤០]

លោកបានបញ្ជាក់ថា "ខ្ញុំសូមជំទាស់នឹងឯកសារនេះ ដែលគេមិនបានឲ្យខ្ញុំអានឡើងវិញ និងចុះហត្ថលេខា។ ព្រមទាំងបានផ្ទុះបញ្ចាំងពីអ្វីៗ ដែលបាននិយាយតែផ្នែកខ្លះតែប៉ុណ្ណោះ"។ លោកសាក្សី ឥឡូវនេះ ខ្ញុំចូលទៅដល់សំណួរដែលខ្ញុំចង់សួរលោកហើយ ដែលសំណួរនេះ គឺពាក់ព័ន្ធទៅនឹងផ្នែកដែលលោកបានឆ្លើយនេះ។ ផ្អែកតាមចម្លើយនេះ គឺមានន័យថា នៅពេលដែលលោកជួបអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោកជំទាស់ទៅនឹងខ្លឹមសារនៃឯកសារដែលគេបានបង្ហាញជូនលោក។ ដូច្នេះ សំណួរដំបូងរបស់ខ្ញុំ ខ្ញុំចង់ដឹងថា តើលោកពិភាក្សាជាមួយអ្នកណា ដើម្បីឲ្យបានជាចម្លើយដែលគេបានបង្ហាញជូននេះ ដែលលោកជំទាស់នេះ?

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** ខ្ញុំអត់បានពិភាក្សាជាមួយអ្នកណាទេ។ គ្រាន់តែ -- ខ្ញុំគ្រាន់តែឃើញឯកសារហ្នឹង ខ្ញុំក៏ៗបញ្ជាក់ប្រាប់ថា ខ្ញុំអត់បាននិយាយដូច្នេះទេ។ ពីព្រោះវាខុសពីអ្វីៗដែលខ្ញុំសរសេរក្នុងសៀវភៅខ្ញុំ ហើយវាខុសអ្វីៗដែលខ្ញុំបានទទួលស្គាល់ ធ្លាប់ទទួលស្គាល់មក។

**ស៖** លោកសាក្សី ខ្ញុំចង់បានការបញ្ជាក់បន្តិចទៅលើចម្លើយរបស់លោកអម្បាញ់មិញនេះ។ លោកបានិយាយថា លោកមិនបានពិភាក្សាជាមួយអ្នកណាទាំងអស់។ អ៊ីចឹងតើមុនពេលដែលមានការសម្ភាសជាមួយនឹងសមាជិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ លោកមានបានជួបជាមួយអ្នកណាផ្សេងទៀតទេ ពាក់ព័ន្ធទៅនឹងរឿងក្តីដែលយើងកំពុងតែជំនុំជម្រះនៅថ្ងៃនេះ នេះ?

**ឆ៖** ខ្ញុំសូមអ្នកស្រីមេធាវីបញ្ជាក់ខ្ញុំដែលខ្ញុំចាំ គឺខ្ញុំបានជួបអ្នកតំណាងស៊ើបអង្កេតរបស់តុលាការម្តង ក្នុងឆ្នាំ -- ប្រហែលជាក្នុងឆ្នាំ២០០៧។ ហើយឯកសារនេះគឺជាៗខ្ញុំទុកឯកសារនេះជាឯកសារមូលដ្ឋាន ដែលៗៗខ្ញុំមកនេះ។

[១៣:៤១:៤២]

**ស៖** ដើម្បីឲ្យបានច្បាស់នោះ លោកសាក្សី ខ្ញុំបង្ហាញនូវចម្លើយដែលលោកបានជំទាស់។ ខ្ញុំព្យាយាមធ្វើតាមជំហានៗមួយៗដើម្បីឲ្យលោកបានច្បាស់ ជាពិសេសគឺសម្រាប់ប្រតិចារឹកតុលាការ។

លោកបានឆ្លើយថា លោកបានសម្ភាសជាមួយនឹងសមាជិកនៃការិយាល័យសហចៅក្រមនៅក្នុងប្រហែលជាឆ្នាំ២០០៧។ តើលោកមានចាំទេថា តើកិច្ចសម្ភាសន៍នេះប្រព្រឹត្តទៅនៅឯណាដែរ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ ប៉ុន្តែតាម -- មិនដឹងផ្ទះណាច្បាស់ទេ ប៉ុន្តែតាមៗខ្ញុំចាំគឺនៅជិតវិមានឯករាជ្យបាទ។

**ស៖** តើការសម្ភាសនេះប្រព្រឹត្តទៅនៅក្នុងការិយាល័យ នៅក្នុងកន្លែងផ្លូវការ ឬក៏នៅកន្លែងណាមួយ?

**ឆ៖** តាមខ្ញុំចាំនៅការិយាល័យរបស់តុលាការ។

**ស៖** តើថ្ងៃដែលគេសម្ភាសនោះ អ្នកដែលសម្ភាសនោះមានបានប្រាប់លោកថា គេនឹងធ្វើជាឯកសារលាយលក្ខណ៍បន្ទាប់ពីលោកឆ្លើយនេះ ដើម្បីផ្តល់ជូនតុលាការទេ?

**ឆ៖** បាទ គេបានបញ្ជាក់ៗខ្ញុំដូច្នេះមែន។

[១៣:៤៣:៥៦]

**ស៖** តើបន្ទាប់ពីការសម្ភាសចប់ បុគ្គលដែលនៅការិយាល័យសហចៅក្រមស៊ើបអង្កេតនោះមានបានអានចម្លើយដែលលោកឆ្លើយថ្ងៃនោះឡើងវិញ ហើយលោកមានបានកែប្រែទៅលើចម្លើយរបស់លោកទេ នៅថ្ងៃនុំងនោះ?

**ឆ៖** ខ្ញុំៗចង់និយាយពីឯកសារនេះ។ គឺខ្ញុំបានអាន ហើយខ្ញុំបានចុះហត្ថលេខា។

**ស៖** សូមអភ័យទោសលោកសាក្សី ខ្ញុំគិតថាប្រហែលជាខ្ញុំទេជាអ្នកមានកំហុសនោះ។ ខ្ញុំសូមឲ្យទុក លោកទុកឯកសារនេះទុកចោលម្ដុំសិន ខ្ញុំនឹង -- ខ្ញុំសូមអានជូនលោកនូវផ្នែកដែលខ្ញុំចង់សួរសំណួរ។ សំណួររបស់ខ្ញុំនេះ គឺពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍ជាមួយនឹងសមាជិកនៃការិយាល័យនៃសហចៅក្រមស៊ើប -- សូមទោស សមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា មុននឹងសម្ភាសជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត។ គឺនៅឆ្នាំ២០០៨ លោកបានសម្ភាស ហើយលោកមានឯកសារហ្នឹងនៅចំពោះមុខលោកហើយ។ គឺខ្ញុំសំដៅទៅលើកិច្ចសម្ភាសន៍លើកដំបូងនៅឆ្នាំ២០០៧ គឺពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា តើលោកមានចាំ ដឹងទេថាលោកធ្លាប់បានសម្ភាសជាមួយការិយាល័យសហព្រះរាជអាជ្ញាទេនៅឆ្នាំ២០០៧?

**ឆ៖** នេះជា២០០៨។ ខ្ញុំអត់ចាំទេ ប៉ុន្តែខ្ញុំជាៗ ខ្ញុំសូមបញ្ជាក់ថាខ្ញុំយកឯកសារឆ្នាំ២០០៨ ជាមូលដ្ឋាននៃការអ្វីដែលខ្ញុំបានសម្ភាសជាមួយតុលាការ។

**ស៖** លោកសាក្សីខ្ញុំស្តាប់ឮច្បាស់ណាស់ ប៉ុន្តែសំណួរខ្ញុំជាក់លាក់ខ្លាំងណាស់។ ខ្ញុំចង់ដឹងថា តើមុនពេលដែលលោកសម្ភាសដែលបានជាឯកសារនៅចំពោះមុខនេះ តើលោកមានធ្លាប់សម្ភាសជាមួយអ្នកណាផ្សេងទៀតទេ មុននឹងសម្ភាសឆ្នាំ២០០៨ ជាមួយសហចៅក្រមស៊ើបអង្កេតនោះ? តើលោកមានសម្ភាសជាមួយការិយាល័យណាផ្សេងក្រៅពីសហចៅក្រមស៊ើបអង្កេតទេ?

[១៣:៤៦:៥៦]

**ឆ៖** ខ្ញុំមិនច្បាស់ទេបាទ ខ្ញុំបានៗជួប ប្រហែលជាបានជួបមែន ប៉ុន្តែខ្ញុំអត់ច្បាស់។ ប៉ុន្តែខ្ញុំសូមយកឯកសារនេះជាមូលដ្ឋាន។ ហើយក្នុងពេលប្រជុំដែលជួបអ្នកតំណាងតុលាការ គឺខ្ញុំបានបញ្ជាក់ច្បាស់ថា ខ្ញុំសូមយកការប្រជុំ ការជួបឆ្នាំ២០០៨ នេះជាមូលដ្ឋាន។

**ស៖** លោកសាក្សី ខ្ញុំយល់ច្បាស់ណាស់។ ខ្ញុំមិនចង់ដឹងថា តើលោកប្រើឯកសារណាជាគោលនោះទេ សំណួររបស់ខ្ញុំ ខ្ញុំដឹងថា តើមុនពេលសម្ភាសដែលចេញបានជាឯកសារដែលលោកកំពុងមាននៅក្នុងដៃនេះ គឺឯកសារ E3/97 នេះ តើមុនពេលសម្ភាសដែលបានឯកសារនោះ លោកមានបានសម្ភាសជាមួយនឹងអ្នកណាផ្សេងទៀតមុននឹងសម្ភាសជាមួយនឹងសហចៅក្រមស៊ើបអង្កេត? នេះជាអ្វីដែលខ្ញុំចង់បាន។

**ឆ៖** ខ្ញុំមិនច្បាស់ទេបាទ។ ខ្ញុំបានជួប ខ្ញុំមកស្រុកខ្មែរម្តងៗ មានអ្នកមកជួបខ្ញុំជាញឹកញយ ប៉ុន្តែខ្ញុំមិនបានចាំថា ខ្ញុំបានជួប ហើយធ្វើអ្វី ប៉ុន្តែជាក់ស្តែងគឺ ដែលធ្វើក្នុងនាមតុលាការ គឺខ្ញុំចាំច្បាស់លើកទី១ ក្នុងឆ្នាំ២០០៨ ប៉ុន្តែពីមុនខ្ញុំមិនច្បាស់។ ប៉ុន្តែខ្ញុំតែងតែមកម្តងៗ ខ្ញុំតែងតែជួបអ្នកនេះអ្នកនោះជាការធម្មតាបាទ។

[១៣:៤៨:៥៦]

**ស៖** អម្បាញ់មិញនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ខ្ញុំលោកបានបញ្ជាក់ថា លោកបានជួបអ្នកណាម្នាក់នៅឆ្នាំ២០០៧ តើលោកមានចាំទេអំពីជំនួបរបស់លោកនៅឆ្នាំ២០០៧ នេះ?

**ឆ៖** ខ្ញុំថាបានជួប ប៉ុន្តែខ្ញុំមិនដឹងជាជួបក្នុងលក្ខខណ្ឌអី ខ្ញុំមិនបានចាំ។ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀត ហើយប្រសិន -- គឺក្នុងករណីណាក៏ដោយក៏ពេលជួបក្នុងឆ្នាំ២០០៨ ខ្ញុំ ដល់គេយកឯកសារហ្នឹងមកឲ្យខ្ញុំ ខ្ញុំបានបញ្ជាក់ថាខ្ញុំទទួលស្គាល់តែការជួបឆ្នាំ២០០៨ នេះទេ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ដើម្បីរំឭកការចងចាំលោកសាក្សី ខ្ញុំសូមអនុញ្ញាតបង្ហាញឧបសម្ព័ន្ធមួយនៃចម្លើយ

របស់លោកសាក្សី។ ខ្ញុំសូមផ្តល់ជូននូវលេខ ERN ជាភាសាបារាំង ERN 00142162, ឯកសារនេះក៏មានបកប្រែជាភាសាអង់គ្លេសផងដែរ។ ERN ជាភាសាអង់គ្លេស 00239987 ERN ជាភាសាខ្មែរ -- ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារជាភាសាខ្មែរនៅលើអេក្រង់គឺលេខ 00178330។ ខ្ញុំសូមឲ្យ លោកក្រឡាបញ្ជីផ្តល់ជូនឯកសារជាក្រដាសជូនទៅលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីជូនសាក្សីពិនិត្យ!

[១៣:៥១:៥៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ក្នុងពេលដែលលោកពិនិត្យមើលឯកសារនេះ លោកសាក្សី ខ្ញុំចង់ដឹងថា ឯកសារដែលលោកកំពុងតែពិនិត្យនេះ គឺជាឯកសារដែលគេបានបង្ហាញជូននៅពេលដែលលោកសម្ភាសជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយគឺជាឯកសារដែលលោកបញ្ជាក់ថា លោកជំទាស់នឹងខ្លឹមសារនោះ តើជាឯកសារហ្នឹងមែនទេដែលលោកជំទាស់នោះ?

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** បាទ ឯកសារហ្នឹងខ្ញុំជំទាស់ពីព្រោះ ទី១ នៅង-២ ខ្ញុំមិនដែលថា សហសេវិក-- មិត្តភក្តិខ្ញុំម្នាក់ដែលធ្វើការហ្នឹង គាត់សុំទៅសហករណ៍ ហើយគាត់ៗអត់បានទៅសហករណ៍ទេ។ ហើយខ្ញុំមិនដឹងជាយ៉ាងម៉េចបានជាក្នុងការសរសេរនេះថា គាត់ទៅសហករណ៍ ហើយគាត់ស្លាប់។ ហើយតាមខ្ញុំដឹងច្បាស់ថា គាត់វាដូចខ្ញុំសរសេរក្នុងសៀវភៅអ៊ីចឹង គាត់នៅរស់ ហើយសព្វថ្ងៃគាត់នៅរស់នៅស្រុកបារាំង។ ដូច្នេះ ខ្ញុំមិនដឹងៗជាយ៉ាងម៉េចបានសរសេរទៅជាអ៊ីចឹង។ អ៊ីចឹងបានខ្ញុំជំទាស់អ្វីដែលសរសេរនៅហ្នឹង។

[១៣:៥៣:១៦]

**ស៖** មានចំណុចសំខាន់មួយ ខ្ញុំចង់ត្រឡប់មកវិញ ពាក់ព័ន្ធទៅនឹងឯកសារនេះ គឺជាផ្នែកដែលខ្ញុំគូសបន្ទាត់ពីក្រោម ហើយដែលបានបញ្ជាក់ថា អៀង សារី និង ខៀវ សំផន បានមកបឹងត្របែក ដើម្បីធ្វើជាអធិបតេយ្យនៃការប្រជុំនយោបាយ។ ចំពោះខ្ញុំ ខ្ញុំបានឃើញ អៀង សារី ក្នុងខែតុលា ឆ្នាំ៧៨ ប្រពន្ធខ្ញុំបានឃើញ ខៀវ សំផន នៅទីនោះ។ លោកសាក្សី តើលោកឯកភាពទេ ថាផ្នែកនៃចម្លើយនេះ គឺថាវាមិនដូចគ្នាទៅនឹងអ្វីដែលលោកបានឆ្លើយទេ មែនទេ?

**ផ៖** ទី -- ខ្ញុំ -- ឯកសារនេះ ជាឯកសារច្របូកច្របល់ ហើយខ្ញុំ -- ប្រពន្ធខ្ញុំ គ្រួសារខ្ញុំ ភរិយាខ្ញុំ គាត់បានជួបលោក ខៀវ សំផន អង្គាល់គាត់មកដល់ស្រុកភ្លាមនៅក-១៥។ ដូច្នេះទាំង -- ឯកសារនេះ វាច្របូកច្របល់ ហើយខ្ញុំបានជួប ឃើញលោក អៀង សារី នៅឆ្នាំ២០០០ -- អ៎! នៅឆ្នាំ១៩៩-- ៧៨ ដូច្នេះៗឯកសារនេះ ខ្ញុំអត់យល់ៗ។ ហេតុដូច្នេះបានជាពេលដែលជួបតំណាងតុលាការឆ្នាំ២០០៨ ខ្ញុំសូមថា ខ្ញុំមិនទទួលស្គាល់ឯកសារនេះទេ។

[១៣:៥៤:៥៦]

**ស៖** លោកសាក្សី សំណួរខ្ញុំប្រហែលនឹងសួរទៅធ្វើឱ្យលោកច្បាស់នៅក្នុងចិត្តរបស់លោក។ កិច្ចសម្ភាសន៍ដែលបង្ហាញអំពីឯកសារ ហើយដែលលោកជំទាស់ខ្លឹមសារនេះ តើលោកចាំទេ? តើលោកចាំទេ ថាកាលលោកសម្ភាសជាមួយអ្នកណាដែរ ដែលមកបានមកជាឯកសារដែលលោកជំទាស់ហ្នឹង?

**ផ៖** បាទ ខ្ញុំចាំអត់ច្បាស់ទេ ខ្ញុំ -- ដូច្នេះបានខ្ញុំៗ ចេះតែឆ្ងល់ហើយឆ្ងល់ទៀត។ ខ្ញុំមើលឡើងវិញម្តងហើយម្តងទៀត ហេតុដូចម្តេចបានជាខ្ញុំនិយាយអ៊ីចឹង ហើយគេដាក់ថា -- គេសរសេរថាខ្ញុំនិយាយអ៊ីចឹង។ ដូច្នេះវាអត់ឈរលើការពិតទេបាទ។ អ៊ីចឹងបានឆ្នាំ២០០៨ ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា ខ្ញុំអត់ទទួលស្គាល់ឯកសារនេះទេ។

**ស៖** លោកបានឆ្លើយថា លោកមិនចាំច្បាស់អំពីកិច្ចសម្ភាសន៍លើកដំបូងនេះ។ ក៏ប៉ុន្តែលោកដឹងទេថា តើលោកសម្ភាសជាមួយអ្នកណាដែរនៅថ្ងៃនោះ? យ៉ាងហោចណាស់ក៏ថាមានអ្នកណាខ្លះដែលមានវត្តមាននៅក្នុងកិច្ចសម្ភាសន៍នោះ?

**ផ៖** ខ្ញុំអត់ចាំអ្នកសម្ភាសម្នាក់ ឈ្មោះ ម៉ូនិច សូខាន់ ខ្ញុំអត់ចាំៗ គាត់យ៉ាងម៉េចទេ ប៉ុន្តែឈ្មោះខេង ហាំខេង -- ខេង ហាំហេង នោះខ្ញុំៗ ស្គាល់គាត់ ព្រោះជាអ្នកមកពីបរទេសដូចខ្ញុំដែរ។ ប៉ុន្តែខ្ញុំឆ្ងល់ហើយឆ្ងល់ទៀត ហេតុដូចម្តេចបានជាគាត់ដឹងរឿងពិតហ្នឹងដែរ ម៉េចក៏សរសេរថា ម្នាក់ដែលនៅ ដ-២ នោះគេយកទៅសម្លាប់នៅសហករណ៍។ ខ្ញុំៗ អត់យល់ ខ្ញុំមិន -- ឯកសារនេះខ្ញុំអត់យល់បាទ ខ្ញុំអត់យល់។

**ស៖** ដូច្នេះតើវាជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាលោកមិនដែលធ្លាប់បានកែប្រែអ្វីទេមុននឹងលោកសម្ភាសជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ?

[១៣:៥៧:៥២]

**ផ៖** ខ្ញុំសូមសួរឡើងវិញ អ្នកស្រីមេធាវីចង់មានប្រសាសន៍ថាម៉េច?

**ស៖** អម្បាញ់មិញនេះខ្ញុំអានឃ្លាមួយនៃចម្លើយរបស់លោក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលលោកបញ្ជាក់ថា លោកជំទាស់ទៅនឹងខ្លឹមសារនៃឯកសារ។ ដូច្នេះខ្ញុំចង់ឲ្យបានច្បាស់ថា មុនពេលទទួលបានឯកសារពីសហចៅក្រមស៊ើបអង្កេតនោះ លោកមិនដែលធ្លាប់មានឯកសារទេ ហើយលោកក៏មិនដែលបានកែប្រែចម្លើយអ្វីនៅលើឯកសារដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំប្រាកដមែនហើយ ខ្ញុំអត់ចាំថា ខ្ញុំ គេឲ្យខ្ញុំមើលឯកសារនេះ ហើយខ្ញុំអត់ចាំបាទ ខ្ញុំអត់ចាំ ហើយមិនដឹងជាការ ឯកសារនេះវាៗបានមកដោយប្រភេទណា ខ្ញុំអត់ចាំ វាដូចថាវាផ្ទុយអ្វីៗ ដែលខ្ញុំធ្លាប់និយាយតាំងពីដើមមក។

**ស៖** សូមអរគុណលោកសាក្សី ចំពោះការបំភ្លឺទៅលើចំណុចមួយនេះ។ ដើម្បីឲ្យមានភាពច្បាស់លាស់ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ ដែលលោកបានឆ្លើយនៅចំពោះមុខសវនាការនេះ ហើយរូបលោកក៏បានឆ្លើយដែរប៉ុន្មាននាទីមុននេះ។ លោកថា "ប្រពន្ធរបស់លោកបានឃើញលោក ខៀវ សំផន ក៏ប៉ុន្តែគឺឃើញនៅមន្ទីរក-១៥"។ តើអ៊ីចឹងមែនទេ ចម្លើយរបស់លោកហ្នឹង គឺអ៊ីចឹងទេ?

[១៣:៥៩:៣៧]

**ឆ៖** បាទ ភរិយាខ្ញុំបានឃើញលោក ខៀវ សំផន ឆ្នាំ -- កាលគាត់មកដល់ស្រុកភ្លាម គឺថាក្នុងឆ្នាំ -- ដើមឆ្នាំ១៩៧៦ បាទ។

**ស៖** បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថានៅពេលនុ៎ង គឺលោកមិនទាន់ចូលទេមែនទេ មិនទាន់ចូលមកកម្ពុជាទេ?

**ឆ៖** ពិតប្រាកដមែនហើយបាទ។

[១៤:០០:២៣]

**ស៖** លោកសាក្សី ខ្ញុំសូមបញ្ចប់សំណួរពាក់ព័ន្ធទៅនឹងចំណុចឆ្នាំ២០០៧, ២០០៨នេះ។ ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា កំហុសដែលមានដកស្រង់នៅក្នុងឧបសម្ព័ន្ធ១ នៃចម្លើយឆ្នាំ២០០៧ គឺនៅក្នុងសំណុំរឿងមានប្រតិចារឹកនៃកំណត់ហេតុសម្ភាស ខ្សែអាត់ជាមួយនឹងសាក្សីរូបនេះ ដែលមានលេខកូដ D141/1.3។

លោកសាក្សី ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយជាមួយលោកពាក់ព័ន្ធទៅនឹងឃ្លាមួយចំនួននៃសៀវភៅរបស់លោកគឺ "ខ្ញុំជឿខ្មែរក្រហម" ដើម្បីឲ្យលោកបញ្ជាក់ឲ្យបានច្បាស់នូវចំណុចដែលខ្ញុំមិនសូវយល់។ ជាដំបូង ខ្ញុំសូមសំណួរ -- សួរសំណួរបឋមមួយចំនួនសិន ប្រសិនបើខ្ញុំយល់ច្បាស់អំពីវិធីសាស្ត្រ

នៅក្នុងការសរសេរសៀវភៅមួយនេះ គឺថាមួយផ្នែកលោកយកចេញមកពីកំណត់ហេតុរបស់ប្រពន្ធរបស់លោក មួយផ្នែកទៀតនោះយកពីកំណត់ហេតុរបស់លោកផ្ទាល់ខ្លួន ហើយផ្នែកខ្លះទៀតនោះលោកធ្វើការស្រាវជ្រាវបំពេញបន្ថែមក្នុងការសរសេរសៀវភៅរបស់លោក។ តើអ្វីដែលខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ ចំពោះវិធីសាស្ត្រនៃការសរសេរសៀវភៅរបស់លោកនេះ?

**ឆ៖** បាទ ពិតមែនហើយ។

[១៤:០២:១៧]

**ស៖** ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវដែលលោកបានធ្វើ តើលោកស្រាវជ្រាវព័ត៌មានចេញពីសៀវភៅរបស់លោកអ្នកនិពន្ធផ្សេងទៀត ឬក៏លោកទៅសម្ភាសជាមួយនឹងសាក្សីណាមួយនៃសម័យនោះ? តើប្រភពដែលលោកយកព័ត៌មានចេញមកនោះ ចេញមកពីណាខ្លះ?

**ឆ៖** ប្រភពដែលខ្ញុំយកជាព័ត៌មាននោះ គឺខ្ញុំបានអានដូចជា ឧទាហរណ៍ដូចខ្ញុំដាក់ឈ្មោះអ្នកដែលគេ -- ជនៗដែលគេចាប់យកទៅ អេស-ម្ភៃតេអង។ ខ្ញុំបានកត់ឈ្មោះអ្នកដែលចូលទៅ អេស-ម្ភៃតេអង ហើយខ្ញុំដាក់ឈ្មោះអ្នកហ្នឹង ដែលអ្នក អេស-ម្ភៃតេអង។ ហើយឯកសារ -- ហើយប្រភពមួយចំនួនទៀត គឺខ្ញុំបានអានអ្វីៗដែលអ្នកដែលជនរងគ្រោះបានសរសេរ។ អាហ្នឹង ខ្ញុំឈរជាមូលដ្ឋានធំលើដែលឯកសារទាំងនេះ។

**ស៖** សូមអរគុណចំពោះការពន្យល់បំភ្លឺនេះ។ ឥឡូវនេះ ខ្ញុំចង់ចូលទៅផ្នែកជាក់លាក់នៃសៀវភៅរបស់លោក។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីផ្តល់ជូនលោកសាក្សី។ សូមអភ័យទោសផង ខ្ញុំមិនបាន -- ខ្ញុំគ្មានសៀវភៅទាំងស្រុងទេ គឺខ្ញុំគ្រាន់តែថតចម្លងផ្នែកពាក់ព័ន្ធដែលខ្ញុំចង់យកមកប្រើប្រាស់។ ផ្នែកដំបូងដែលខ្ញុំចង់យកមកប្រើនៃសៀវភៅដែលមានលេខកូដ D141/1.2។ ផ្នែកដំបូងដែលខ្ញុំចង់យកមកសួរលោកនោះ គឺនៅក្នុងភាសាបារាំង គឺទំព័រ២០ និងទំព័រ២១។ ERN ជាភាសាបារាំង 00287899, ERN ជាភាសាខ្មែរ 00831078។ សូមអភ័យទោសផង ខ្ញុំមិនមានលេខ ERN ជាភាសាអង់គ្លេសទេ ពីព្រោះថាឯកសារនេះមិនមានជាភាសាអង់គ្លេសទេ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារជាភាសាខ្មែរនៅលើអេក្រង់ ហើយនិងផ្តល់ជូនឯកសារ ជូនលោកសាក្សី។ សូមការអនុញ្ញាតពីលោកប្រធានជូនឯកសារ ជាភាសាបារាំងជូនលោកសាក្សីជាក្រដាស។

[១៤:០៥:២៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ជាក្រដាសពីលោកស្រីមេធាវី យកជូនសាក្សីពិនិត្យ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

**សួរដោយកញ្ញា អង់តា ហ៊្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំគិតថា លោកមានឯកសារជាភាសាបារាំងនៅចំពោះមុខលោកហើយ គឺផ្នែកដែលពាក់ព័ន្ធនោះគឺនៅចុងទំព័រ២០ និងដើមទំព័រ២១ ជាភាសាបារាំង។ ខ្ញុំសូមអាន៖ “នៅឆ្នាំ ១៩៥៦ ខៀវ សំផន ឡើងជាប្រធានវង់ម៉ាក្ស-ឡេនីន និងជាប្រធានសហភាពនិស្សិតខ្មែរ បន្តពី អៀង សារី។ អ្នកធ្លាប់ស្គាល់ ខៀវ សំផន ម្នាក់និយាយថា ខៀវ សំផន ជាអ្នកតស៊ូសកម្មផុសផុល និងមានវិន័យ។ ប៉ុន្តែគាត់គ្មានបុគ្គលិកលក្ខណៈផ្ទាល់ខ្លួននោះទេ គាត់ធ្វើតែតាមគេ ហើយគាត់យល់ថា ថ្នាក់លើធ្វើអ្វីក៏ត្រូវរហូត”។ លោកសាក្សីពាក់ព័ន្ធទៅនឹងផ្នែកនេះ នៃសៀវភៅរបស់លោក តើលោកបានប្រភពមកពីណាដើម្បីសរសេរផ្នែកនេះនោះ?

**លោក អុង ថុងហឿង៖**

**ឆ៖** ខ្ញុំបានប្រភពពីអ្នកដែលធ្លាប់ជាសហការី របស់លោក ខៀវ សំផន កាលនៅវង់ម៉ាក្ស-ឡេនីន ដែលរស់នៅស្រុកបារាំងបាទ។

[១៤:០៧:៣៧]

**ស៖** តើលោកអាចរៀបរាប់ឈ្មោះបានដែរឬទេ អាចបញ្ជាក់ថាតើលោកបានពិភាក្សាជាមួយអ្នកណាខ្លះ?

**ឆ៖** ខ្ញុំមិនបានពិភាក្សាជាមួយអ្នកណាទេ គឺថាខ្ញុំបានព័ត៌មានពីម្នាក់ពីរនាក់អ៊ីចឹងទៅ អ្នកធ្លាប់រស់នៅជាមួយគាត់ ខ្ញុំក៏សរសេរអ៊ីចឹងទៅបាទ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ខ្ញុំចង់ដឹងថា តើលោកបានទទួលព័ត៌មានទាំងអស់នេះពីអ្នកណា? តើលោកអាចចាំឈ្មោះដែរឬទេ?

**ឆ៖** ខ្ញុំអត់ចាំឈ្មោះទេបាទ។

**ស៖** ហើយកិច្ចសម្ភាសន៍ទាំងអស់នេះ ដែលថាអាចលោកធ្វើការពិពណ៌នាលើលោក ខៀវ

សំផន នោះ តើលោកចាំថា លោកសម្ភាសហ្នឹងនៅពេលណាដែរទេ ទាក់ទងនឹងបុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន នេះ?

[១៤:០៩:០៨]

**ឆ៖** ខ្ញុំបានធ្វើឡើងប្រហែលជានៅឆ្នាំ២០០២ បាទ ព្រោះអត្ថបទនេះ ខ្ញុំសរសេរក្រោយ ដោយសារអ្នករោងពុម្ព គេចង់បានសេចក្តីសង្ខេបពីនិស្សិតខ្មែរ នៅប្រទេសបារាំង។ ដូច្នេះ ខ្ញុំសរសេរមុនការយកមកបោះពុម្ព ប្រហែលជាខ្ញុំសរសេរក្នុងរយៈពេលពីរបីខែមុនបោះពុម្ព នៅ២០០៣។

**ស៖** ហើយត្រង់ចំណុចនេះតែម្តង នៅពេលដែលនិយាយអំពីបោះពុម្ពផ្សាយសៀវភៅរបស់លោកនោះ លោក សៀវភៅរបស់លោកបោះពុម្ពនៅឆ្នាំ២០០៣ ជាភាសាបារាំង។ ហើយខ្ញុំយល់ថាឥឡូវនេះមានជាភាសាខ្មែរដែរ ហើយការបោះពុម្ពជាភាសាខ្មែរនេះ ទើបតែបោះពុម្ពនៅឆ្នាំ២០០៦ នោះទេ។ សំណួរខ្ញុំដូចតទៅនេះ តើលោកជាអ្នកទទួលបន្ទុកក្នុងការបកប្រែ ហើយនិងការអានការបកប្រែឡើងវិញនេះជាភាសាខ្មែរខ្លួនឯង ឬក៏បុគ្គលផ្សេងមួយទៀតជាអ្នកធ្វើ?

**ឆ៖** ជាភាសាៗខ្មែរ ខ្ញុំអ្នកបកខ្លួនឯងបាទ។

[១៤:១១:០២]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ហើយនិងមន្ត្រីតុលាការ ខ្ញុំចង់ជូនឯកសារជាភាសាខ្មែរទៅលោកសាក្សី។ ឯកសារដែលខ្ញុំចង់ប្រើ ពីព្រោះថាបើខ្ញុំមិនច្រឡំទេថា សមាជិករបស់ក្រុមខ្ញុំ ដែលជាជនជាតិខ្មែរនោះ បានបង្ហាញ បានប្រាប់ថាមានការភ័ន្តច្រឡំ ឬក៏ការបកប្រែខុសគ្នារវាងសំណៅទាំងពីរហ្នឹង។ អ៊ីចឹងសុំការអនុញ្ញាតបង្ហាញឯកសារនេះជាភាសាខ្មែរទៅសាក្សី សម្រង់មួយចំនួនទៅសាក្សី លោកប្រធាន។

[១៤:១១:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ជាក្រដាសពីលោកស្រីមេធាវីយកជូនសាក្សីពិនិត្យ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដូច្នេះ សំណៅជាភាសាខ្មែរនៅទំព័រ ERN 00831078 គឺហាក់ដូចជាមិនមានឈ្មោះលោក ខៀវ សំផន នោះទេ តែមានឈ្មោះលោក អៀង សារី ទៅវិញ។ តើលោកអាចជម្រាបទៅ

តុលាការថាមានការបោះពុម្ពផ្សាយខុស ឬក៏យ៉ាងម៉េច? ទាក់ទងនឹងឈ្មោះមនុស្សពីររូបនេះ លោក ខៀវ សំផន ហើយនិងលោក អៀង សារី?

[១៤:១៣:០១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែនៅក្នុងកថាខណ្ឌ ដែលមេធាវីលោក ខៀវ សំផន និយាយថាមានឈ្មោះទាំងពីរនេះ ជាភាសាបារាំងនោះ ខ្ញុំគិតថាអាចសំណួរតាមបែបផ្សេងវិញ ថាតើប្រាប់ថាឈ្មោះហ្នឹង ទាំងពីរហ្នឹងមានការផ្លាស់ប្តូរទៅវិញទៅមកហ្នឹង នៅកន្លែងណាឲ្យច្បាស់លាស់?

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី សុំឲ្យលោកអានជាភាសាខ្មែរ ក៏ប៉ុន្តែផ្នែកដែលខ្ញុំចាប់អារម្មណ៍នោះគឺថានៅឆ្នាំ១៩៥៦ ដែលខ្ញុំអានជាភាសាអង់គ្លេសអម្បាញ់មិញនេះ គឺថានៅកថាខណ្ឌចុងក្រោយ។ ខ្ញុំមិនអាចផ្តល់យោងជាភាសាខ្មែរបានទេ ទាក់ទងនឹងទំព័រនេះ "ក៏ប៉ុន្តែធ្វើយ៉ាងណាចាប់ផ្តើមដោយឆ្នាំ១៩៥៦ ខៀវ សំផន បានឡើងជាប្រធានវង់ម៉ាក្ស-ឡេនីន ជាប្រធានសហភាពនិស្សិតខ្មែរបន្ទាប់ពី អៀង សារី ហើយអ្នកធ្លាប់ស្គាល់ ខៀវ សំផន ម្នាក់និយាយថា ខៀវ សំផន ជាអ្នកតស៊ូសកម្មផុសផុល មានវិន័យ ក៏ប៉ុន្តែគ្មានបុគ្គលិកលក្ខណៈផ្ទាល់ខ្លួននោះទេ"។

[១៤:១៤:២១]

**លោក អុង ថុងហឿង៖**

**ឆ៖** ខ្ញុំសូមលោកស្រីមេធាវីជាទីគោរពអធ្យាស្រ័យ ឯកសារខ្ញុំបានជាភាសាខ្មែរ ហើយឯកសារដែលខ្ញុំនិយាយជាបារាំងហៅ "ប្រូលូក" វាខុសគ្នាឯកសារដែលខ្ញុំបានជាភាសាខ្មែរ គឺជាឯកសារនិយាយទាក់ទងនៅរឿង ដែលព្រឹត្តិការណ៍មួយផ្សេងទៀតដែលខ្ញុំនៅរោងចក្រដ-២។ ហើយឯកសារនេះជាឯកសារដែលលោកៗមេធាវីដ៏មហិមាប្រាប់ខ្ញុំនេះ គឺទាក់ទងនឹងរឿងដែលខ្ញុំធ្វើសិក្សាពីរឿងធ្វើសេចក្តីសង្ខេប ពីជាប្រវត្តិនិស្សិតខ្មែរនៅស្រុកបារាំង។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអភ័យទោសលោកសាក្សី អ៊ីចឹងខ្ញុំ នេះជាកំហុសរបស់ខ្ញុំ អ៊ីចឹងខ្ញុំសូមឲ្យទំព័រខុសជាភាសាខ្មែរ សូមឲ្យលោកមន្ត្រីតុលាការ ខ្ញុំសូមអភ័យទោស ដែលខ្ញុំសូមលោកផ្តល់ទំព័រត្រឹមត្រូវទៅលោកសាក្សី ហើយដើម្បីឲ្យគាត់ដឹង អាចដឹងពីយោងត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារជាក្រដាសពីលោកស្រីមេធាវីយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជាក្រដាសជូនសាក្សី)*

[១៤:១៥:៥៨]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ផ្នែកហ្នឹងមានគូសបន្ទាត់ពីក្រោម។ បាទ ឥឡូវឯកសារដែលលោកមាននៅកំពុងតែពិនិត្យហ្នឹងមានគូសជុំវិញហើយ។

**លោក អុង ហុងហឿង៖**

**ឆ៖** ខ្ញុំសូមឆ្លើយថា បកជាភាសា ការវ៉ៃជាភាសាខ្មែរមានការខុសបាទ។ ដាក់ អៀង សារី ជំនួស ខៀវ សំផន នេះ -- ប៉ុន្តែខ្ញុំនៅស្រុកបារាំង គឺខ្ញុំអត់បានពិនិត្យឡើងវិញ។

**ស៖** សូមអរគុណ។ ព័ត៌មានទាំងអស់នេះមានសារៈសំខាន់ណាស់ ពីព្រោះថាយើងធ្វើការជាបីភាសាហើយជាសំខាន់ណាស់ដែលថាយើងម្នាក់ៗគឺថា យល់ដូចគ្នាទាំងអស់បាទ។ ក្នុងភាសាខ្មែរលោកប្រធាន ថាមានកំហុសអម្បាញ់មិញនេះ លោកប្រធាន អ្វីដែលខ្ញុំបានរៀបរាបអម្បាញ់មិញនេះ។ ដើម្បីបញ្ចប់លើរបៀបសរសេរសៀវភៅរបស់លោក តើសំណៅទី១ របស់លោកនោះធ្វើជាភាសាខ្មែរ ឬក៏ជាភាសា បារាំង គឺថាលោកសរសេរជាដៃ សំណៅជាដៃ?

[១៤:១៨:០៣]

**ឆ៖** បាទ ជាភាសាបារាំង ហើយជាភាសាខ្មែរបកប្រែក៏សរសេរដៃដែរ ក៏ប៉ុន្តែដោយពិបាកវ៉ៃខ្ញុំមិនចេះវ៉ៃអង្គុលីលេខក៏បញ្ជូនអត្ថបទជាភាសាខ្មែរហ្នឹងមកឲ្យនៅរោងពុម្ពនៅស្រុកខ្មែរបោះ។ ហើយខ្ញុំអត់បានពិនិត្យឡើងវិញឲ្យបានដិតដល់ទេ នេះៗជាការធម្មតា ខ្ញុំក្នុងការបោះ -- បកប្រែពីភាសាមួយទៅភាសាមួយជារួមខ្លឹមសារនៅដដែល ប៉ុន្តែមានខុសខ្លះអីខ្លះ គឺថានេះជាការកំហុសបច្ចេកទេសបាទ។

**ស៖** ដូច្នេះ តើយើងឯកសារភាពថា យើងត្រូវតែយកឲ្យតម្លៃទៅលើសំណៅជាភាសាបារាំង

អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដមែនហើយ។

**ស៖** អ៊ីចឹង ខ្ញុំសូមអរគុណដែលបានបំភ្លឺ ហើយឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីផ្នែកមួយទៀតនៃសៀវភៅរបស់លោក។ គឺទំព័រ៧៧ ជាភាសាបារាំង ERN ជាភាសាបារាំង គឺ 00287956, ERN ជាភាសាខ្មែរគឺ 00881134 ហើយអត់មាន ERN ជាភាសាអង់គ្លេសទេ គួរឲ្យសោកស្តាយដែរ ប៉ុន្តែវគ្គដែលខ្ញុំចាប់អារម្មណ៍នៅពេលនេះ គឺជាការសន្ទនាដែលលោកបានរៀបរាប់ថា លោកបានធ្វើការសន្ទនានេះជាមួយនឹងលោក ប៊ុន រឿន បាទ ខ្ញុំសូមទោសបើសិនជាខ្ញុំអានឈ្មោះនេះពុំបានត្រឹមត្រូវ។ ហើយលោក ប៊ុន រឿន នេះនិយាយទៅកាន់លោកយ៉ាងដូច្នេះ “លោកដឹងថាអ្នកណាជា ប៉ុល ពត ទេ?” ឆ្លើយវិញថា “អត់ដឹងទេ។ អត់ដឹងច្បាស់ទេ” ហើយគាត់និយាយទៀតថា គឺ “សាឡុត ស ដែលមនុស្សពូកែណាស់ សូម្បីតែចិនក៏និយាយដែរ ថា សាឡុត ស នេះប្រៀបស្មើនឹងលោកប្រធាន ម៉ៅ”។ បាទ សំណួរខ្ញុំទី១ ទាក់ទងនឹងផ្នែកនេះ តើលោកអាចជម្រាបជូនតុលាការបានទេថា ប៊ុន រឿន នេះជាអ្នកណា?

[១៤:២០:៥៣]

**ឆ៖** ប៊ុន រឿន នេះជានិស្សិតមកពីប្រទេសអាល្លឺម៉ង់ខាងកើតបាទ ហើយសព្វថ្ងៃគាត់ស្លាប់ហើយ។

**ស៖** ទាក់ទងទៅនឹងពាក្យពេចន៍ដែលគាត់និយាយទាក់ទងទៅនឹង ប៉ុល ពត នៅក្នុងការសន្ទនានេះគាត់បានលើកឡើងថា សរសើរ ប៉ុល ពត សំណួរខ្ញុំដូចតទៅនេះ៖ តើលោកមានឱកាសក្នុងការសង្កេតឃើញថា គាត់ហ្នឹងស្ងើចសរសើរ ប៉ុល ពត អំពីសំណាក់អ្នកផ្សេងទៀត ចំពោះអ្នកផ្សេងៗទៀតដែរឬទេ អ្នកដឹកនាំផ្សេងៗទៀត នៅក្នុងសម័យខ្មែរក្រហមដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ ប៉ុន្តែខ្ញុំចាំ ដូចគាត់បាននិយាយប្រាប់ខ្ញុំអ៊ីចឹងបាទ។

**ស៖** ខ្ញុំសូមសួរម្តងទៀត ព្រោះថាចម្លើយរបស់លោកជាភាសាបារាំង បកប្រែជាភាសាបារាំងអំមិញនេះ ខ្ញុំមិនយល់ទេ។ អម្បាញ់មិញខ្ញុំសួរលោកថា តើក្រៅពី ប៊ុន រឿន នេះលោកបានជួបបញ្ញាជនផ្សេងទៀត ដែលបាននិយាយអំពី ប៉ុល ពត និយាយពី ប៉ុល ពត ហើយដោយស្ងើចសរសើរ ហើយនិងគួរឲ្យពេញចិត្តដូចគ្នាហ្នឹង តើធ្លាប់ទេ?

[១៤:២២:៥៣]

**ផ៖** ខ្ញុំតែងឮសួរជារឿយៗអ៊ីចឹង អ្នកដែល -- មិត្តភក្តិដែលបានទៅ ចេញទៅធ្វើការជាមួយបងប្អូនខ្មែរ ក្រៅពីៗជំរំអប់រំរបស់យើងខ្ញុំរស់នៅ។

**សះ** នៅពេលដែលលោកនិយាយថា លោកបានឮមិត្តភក្តិនិយាយជាមួយអ្នកផ្សេងទៀតនៅកន្លែងផ្សេងទៀត កន្លែងផ្សេងក្រៅពីជំរំកសាងកែប្រែនោះ តើលោកអាចៗនិយាយថា នៅចន្លោះ៧៥-៧៩ ឬក៏ក្រោយពេល -- ក្រោយឆ្នាំ៧៩?

**ផ៖** ខ្ញុំចង់និយាយពី មុន១៩៧៩ បាទ។

[១៤:២៤:១៦]

**សះ** បាទ សូមអរគុណ។ នៅទំព័របន្ទាប់មកទៀត ជាភាសាបារាំង គឺ ERN 00287957, ជាភាសាខ្មែរគឺ 00831134 ខ្ញុំមិនច្បាស់ទេ មិនដឹងថា ជា34 ឬក៏35 នោះទេ។ ខ្ញុំសូមអភ័យទោស ក៏ប៉ុន្តែផ្នែកដែលខ្ញុំចាប់អារម្មណ៍នេះ គឺថា វាមានជាប់គ្នាពីរទំព័រ។ លោកបានរៀបរាប់ បន្ទាប់មកទៀត បន្តពីការសន្ទនារបស់លោកជាមួយ ប៊ុន រឿន នោះលោកបានសួរគាត់ថា "ហើយចុះ ខៀវ សំផន ធ្វើអ្វី?"។ គាត់ឆ្លើយមកលោកវិញយ៉ាងដូច្នេះ "តាមខ្ញុំដឹងគាត់មិនមែនទាំងជាសមាជិកមជ្ឈិមបក្សកុម្មុយនីស្តផងទេ។ គាត់គ្រាន់តែជាមនុស្សទី៨ នៅក្នុងជួរបក្សប៉ុណ្ណោះ។ ចំណែកឯ ហ៊ូ យន់, ហ៊ូ នឹម មិនបាច់និយាយទេ ពួកគាត់គ្មានតួនាទីអ្វីសំខាន់នៅក្នុងបក្សទេ"។

សំណួរទី១ របស់ខ្ញុំដែលទាក់ទងនឹងផ្នែកនេះ តើនេះគឺជា គឺឆ្លុះ -- នេះឆ្លុះបញ្ចាំងអំពីការសន្ទនាពិតប្រាកដជាក់លាក់រវាងលោក ហើយនិងលោក ប៊ុនរឿន នេះទេ?

[១៤:២៦:០២]

**ផ៖** បាទ ពិតប្រាកដមែន។

**សះ** តើជាការសន្ទនាដែលលោកបានកត់ត្រានៅក្នុងសៀវភៅ កូនសៀវភៅរបស់លោក ហើយដែលក្រោយមកលោកប្រើកំណត់ហេតុរបស់លោកនេះ ដើម្បីសរសេរសៀវភៅ អ៊ីចឹងមែនទេ?

**ផ៖** បាទ ជាអ្វីៗដែលខ្ញុំបានចាំបាទ។

**សះ** បើសិនជាខ្ញុំមិនច្រឡំទេនោះ តើការសន្ទនានេះលោកមិនបានកត់ជាកំណត់ហេតុនៅក្នុងកូនសៀវភៅរបស់លោកទេ មែនទេ?

**ផ៖** ខ្ញុំមិនច្បាស់ទេបាទ មិនច្បាស់ទេ ប៉ុន្តែខ្ញុំចាំ នៅចាំ។

**សះ** បាទ ជាព័ត៌មាន តើលោករក្សាកំណត់ហេតុដែលលោកប្រើដើម្បីសរសេរសៀវភៅលោក

នេះដែរឬទេ?

[១៤:២៧:២៤]

**ឆ៖** ខ្ញុំនៅថែរក្សាទាំងអស់បាទ។

**ស៖** ទាក់ទងនឹង ប៊ុនរឿន ដែលនិយាយប្រាប់លោកអំពីការិយាល័យ -- មន្ទីរនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះ តើគាត់មានប្រាប់ពីប្រភពព័ត៌មាន ដែលគាត់ទាញយកប្រាប់លោកដែរឬទេ?

**ឆ៖** បាទ អត់ទេ ហើយខ្ញុំក៏អត់ប៊ានសួរដែរ គ្រាន់តែជួបគ្នាអ៊ីចឹងទៅ និយាយអ៊ីចឹងទៅ។ និយាយដោយស្ងាត់ៗ ព្រោះក្នុងសភាពការណ៍ជួបគ្នាអ៊ីចឹង វាដូចលោកស្រីជ្រាបស្រាប់ហើយ ពេលនោះគឺកិច្ចការអ៊ីចឹងៗ ជាការសម្ងាត់ហើយយើងមិនអាចនិយាយគ្នាដោយចំហទេបាទ។

**ស៖** ហើយត្រង់ចំណុចនេះតែម្តង ដោយសារលោកនិយាយអំពីការសម្ងាត់។ លោកបានប្រាប់ថានៅទំព័រដដែល ជាភាសាបារាំង គឺយោងដូចគ្នាទេ។ "ដោយគោរពតាមគោលការណ៍រក្សាសម្ងាត់ ខ្ញុំបានត្រឹមតែស្តាប់គាត់និយាយ ហើយមិនប៊ានសួរនាំអ្វីច្រើនទេ"។ បាទ ដើម្បីជាកំណត់ត្រា ខ្ញុំគិតថាផ្នែកនេះមិនមាននៅក្នុងភាសាខ្មែរទេ ផ្នែកនេះ។ លោកសាក្សី លោកបាននិយាយអំពីគោលការណ៍រក្សាការសម្ងាត់។ តើនេះជាបទបញ្ជាដែលគេផ្តល់ទៅលោកនៅពេលដែលលោកមកដល់ប្រទេសកម្ពុជាហើយលោកចង់និយាយអំពីបទបញ្ជាអ្វីដែរ?

**ឆ៖** នេះខ្ញុំចង់និយាយឡើងវិញពីគោលការណ៍ការសម្ងាត់ នៅពេលនោះជាគោលការណ៍សម្ងាត់នេះជា វាមានសារៈសំខាន់ក្នុងស្មារតីអង្គការ គឺថានៅពេលយើងខ្ញុំមកដល់វិញនោះ គេតែងតែក្នុងវគ្គសិក្សា ឬការទិតៀន ស្វ័យទិតៀន គឺថាត្រូវថែរក្សាការសម្ងាត់ឲ្យបាន។ ព្រោះការសម្ងាត់នេះជាការកត្តាកំណត់នៃជ័យជម្នះ។ នេះជាការដែលដូចឧបមាថា ការសម្ងាត់យ៉ាងម៉េច ឧបមាថា ជាការគោលការណ៍យើងជួបអ្នកណាក្រៅ នរណាក៏ដោយ យើងមិនត្រូវប្រាប់ថា យើងមកពីណា ឬក៏យើងធ្វើការណា ឬក៏ស្នឹងណាទេ។ គឺថានេះជាការរក្សាការសម្ងាត់នៅពេលនោះបាទ។ ខ្ញុំចង់និយាយអ៊ីចឹង។

[១៤:៣០:២៤]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយផ្នែកមួយទៀតនៃសៀវភៅរបស់លោក។ ជាភាសាបារាំង គឺទំព័រ២០៦ ERN 00288085, ជាភាសាខ្មែរគឺ 00831240, ជាភាសាអង់គ្លេស លើកនេះមានជាភាសាអង់គ្លេសដែរ គឺ ERN 00785869។

ខ្ញុំសូមការអនុញ្ញាតបញ្ចាំងផ្នែកជាភាសាខ្មែរនេះទៅសាធារណជនលោកប្រធាន។ ហើយខ្ញុំសូម

អានផ្នែកទី១ នៃកថាខណ្ឌទី១ នៅក្នុងទំព័រ២៦០ -- ២០៦ នៅទំព័រនេះ លោកនិយាយអំពី ប៉ុល ពត "វេទិកាអប់រំនេះជាកម្មវិធីផ្សព្វផ្សាយថ្មីមួយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ។ ថ្វីត្បិតតែគ្មានការបញ្ជាក់ថា ប៉ុល ពត ជាអ្នកនិយាយផ្ទាល់ក្នុងវិទ្យុពេលម៉ោងប្រាំមួយព្រឹកក៏ដោយ គេក៏ -- ក៏គេគ្រប់គ្នាដឹងរឿងនេះដែរ។ ហើយពួកដែលបានជួប ប៉ុល ពត ក៏បញ្ជាក់ថា ប៉ុល ពត ជាអ្នកនិយាយដែរ។ កាលពីសប្តាហ៍មុន គ្នាយើងខ្លះ ខ្លះដែលកំពុងទទួលការបណ្តុះបណ្តាលបច្ចេកទេសត្រូវបានជ្រើសរើសឲ្យទៅស្តាប់សន្និសីទរបស់លេខាបក្សនៅសាលចតុមុខ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺប្រកាសអំពីការបើកវិទ្យាស្ថានបច្ចេកទេស គឺនៅឱកាសនោះហើយដែលមិត្តភក្តិយើងខ្លះអាចឃើញលេខាបក្សផ្ទាល់ជាលើកទី១ និងបានស្តាប់បទឧទ្ទេសនាមរបស់គាត់ដោយផ្ទាល់។ អ្នកខ្លះចាប់អារម្មណ៍ខ្លាំងទៅលើបុគ្គលិកលក្ខណៈរបស់គាត់ ហើយនិងព្រមទាំងសិល្បៈក្នុងការនិយាយបញ្ចុះបញ្ចូលរបស់គាត់"។ ហើយខ្ញុំសូមបញ្ចប់ការដកស្រង់នៅត្រឹមនេះសិន។

[១៤:៣២:៤៧]

តើលោកធ្លាប់បានពិភាក្សាដោយផ្ទាល់ជាមួយអ្នក ដែលបានចូលរួមស្តាប់បទបង្ហាញរបស់លោក ប៉ុល ពត នេះដែរឬទេ? ប្រហែលជាអាចខ្ញុំចោទសួរសំណួរផ្សេងទៀតជាបឋម ហើយដូចឧទាហរណ៍សំណួរបឋមនោះ ថាតើលោកបានស្តាប់បទឧទ្ទេសនាមរបស់លោក ប៉ុល ពត ដោយផ្ទាល់ដែរឬទេ?

**ឆ៖** បាទ អត់បានចាប់ -- គេអត់បាន -- ខ្ញុំអត់មានឈ្មោះទៅស្តាប់លោក ប៉ុល ពត ទេ។ ប៉ុន្តែមិត្តភក្តិដែលទៅ ឃើញលោក ខៀវ សំផន មកទៅ។ ពេលជុំគ្នាទាំងអស់ លោក ខៀវ សំផន មកហើយគាត់ឈរដូចគេដូចឯងអ៊ីចឹង អត់មានពីណាទទួលគាត់ ឬទុកកៅអីជូនគាត់។ ហើយដល់ដូច្នេះអ្នកមកពីបរទេសទាំងអស់ហ្នឹង ក៏ចាប់អារម្មណ៍ថា "ចុម! បើគាត់ប្រមុខរដ្ឋ មាននាទីជាប្រមុខរដ្ឋអ៊ីចឹងគាត់មកអ៊ីចឹង វាដូចគ្មានអ្នកណាឃើញគាត់ -- គ្មានអ្នកណាចាំទទួលគាត់"។ ដូច្នេះវាធ្វើឲ្យអ្នកទៅប្រជុំហ្នឹងមានអារម្មណ៍យល់ និយាយដូចខ្ញុំបានសរសេរអ៊ីចឹងបាទ។

[១៤:៣៤:១១]

**ស៖** ដើម្បីឲ្យច្បាស់ជាងនេះទៅទៀត ទាក់ទងនឹងចម្លើយរបស់លោកនេះ នៅពេលដែលលោកប្រាប់ថា ពុំមានកៅអីសម្រាប់ឲ្យគាត់ទេ។ ពាក្យថា "គាត់" នេះ លោកសំដៅលើលោកខៀវ សំផន ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំចង់និយាយថា លោក ខៀវ សំផន។

**សៈ** ខ្ញុំសូមបន្តអានកថាខណ្ឌនេះទៅទៀត ហើយលោកនឹងអាចឆ្លើយបន្ថែមទៀត គឺនៅទំព័រដដែល លោកបានលើកឡើងដូចតទៅនេះ៖ “ជាក់ស្ដែងទៅ ខៀវ សំផន ដែលឥទ្ធិពលខ្លាំងលើការចូលប្រឡូកក្នុងនយោបាយរបស់គាត់ របស់គ្នាយើងនោះ គ្រាន់តែជាតុក្កតា ឬក៏អាយ៉ងនៅក្នុងកណ្ដាប់ដៃរបស់ ប៉ុល ពត តែប៉ុណ្ណោះ”។ តើនេះជាពាក្យពេចន៍ ដែលអ្នកចូលរួមក្នុងឧទ្ទេសនាមនេះ រៀបរាប់ប្រាប់លោក គឺថា បទឧទ្ទេសនាមដែលធ្វើនៅវិទ្យាស្ថានបច្ចេកទេសហ្នឹងមែនទេ?

[១៤:៣៥:៤២]

**ឆៈ** បាទ ពិតមែនហើយ។

**សៈ** តើលោកចាំឈ្មោះ អ្នកដែលនិយាយពាក្យពេចន៍ទាំងនេះប្រាប់លោកដែរឬទេ?

**ឆៈ** បាទ ខ្ញុំអត់ចាំទេបាទ។

**សៈ** ក៏ប៉ុន្តែលោកចាំថា លោកធ្លាប់បានសន្ទនាជាមួយ យ៉ាងហោចណាស់ក៏ម្នាក់ក្នុងចំណោមអ្នកទាំងអស់នេះ។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ អ៊ីចឹងមែនហើយ។

**សៈ** ដើម្បីឲ្យច្បាស់ទៀតនោះ ថាតើតែជាមួយម្នាក់ទេ ឬក៏ជាមួយមនុស្សច្រើន?

**ឆៈ** ខ្ញុំទទួលៗការចាប់អារម្មណ៍ពីយ៉ាងតិចក៏បី ឬបួននាក់ដែរបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សីខ្ញុំសូមអរគុណ ដែលបានឆ្លើយតបទៅនឹងសំណួរខ្ញុំទាំងអស់នេះ ហើយខ្ញុំសូមបញ្ចប់ការសួរសំណួរទៅលោកត្រឹមនេះតែម្ដង។ សូមអរគុណ។

[១៤:៣៧:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៨:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយលោក អ៊ុង ហុងហឿង ការស្ដាប់សក្ខីកម្មរបស់លោក រហូតដល់ពេលនេះបានចប់សព្វគ្រប់ហើយ។ ហើយលោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកមានបំណងទៅបានហើយ។

អង្គជំនុំជម្រះសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះលោក ដែលបានធ្វើដំណើរមកពី

ប្រទេសប៉ែលហ្សិក ដ៏សែនឆ្ងាយ ហើយនិងចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេលបីថ្ងៃកន្លងមកនេះ។ ហើយដោយលោកបានខិតខំអស់ពីសមត្ថភាព សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទាន ក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយសូមលោកជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់កន្លែង ដែលគាត់ស្នាក់នៅ ឬក៏កន្លែងដែលគាត់មានបំណងចង់ទៅបានហើយ។

[១៤:៣៩:១២]

ហើយអង្គជំនុំជម្រះសូមជម្រាបថា នៅក្នុងកិច្ចដំណើរការនៅរសៀលនេះ គឺដូចអង្គជំនុំជម្រះហើយ គឺកិច្ចដំណើរការសវនាការ អាចប្រព្រឹត្តទៅឆ្លាស់គ្នារវាងសាក្សី អ៊ុង ចុងហឿង និង សួង ស៊ីគឿន ដោយឥឡូវនេះនៅពេលវេលាមួយពេល ដែលមានរយៈពេល១ម៉ោង១០នាទី។ ដើម្បីពន្លឿន កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះក្រោយពេលសម្រាក គឺបន្តការសួរដេញដោលចំពោះសក្ខីកម្មសាក្សី សួង ស៊ីគឿន នៅក្រោយពេលសម្រាកនេះ។ ដូច្នេះ គឺសូមភាគីជ្រាប ហើយភាគីដែលអាចតាំងសំណួរសាក្សី សួង ស៊ីគឿន បន្តគឺក្រុមមេធាវីការពារក្តីដែលនៅក្នុងនោះ គឺពេលវេលាចុងក្រោយនៃសាក្សី -- អ៎! នៃពេលវេលាដែលបានទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទំនងជានៅសេសសល់សំណួរចុងក្រោយ ដែលដល់ក្រុមមេធាវីនាំ -- មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ហើយ។ បាទ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះហើយ ២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការនៅវេលាម៉ោងបី សូមឲ្យអញ្ជើញសាក្សី សួង ស៊ីគឿន ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលទៅសាក្សី ប្រសិនបើនៅមានសំណួរ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកសាក្សី។ យើងបានជួបគ្នារួចមកហើយ កាលពីប៉ុន្មានថ្ងៃមុននេះ។ ខ្ញុំសូមណែនាំខ្លួនជាថ្មីម្តងទៀត ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ជាមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ កាលពីលើកមុននោះ មុនពេលបែកគ្នានោះ យើងនិយាយអំពីការមិនទុកចិត្តអំពីបញ្ហាជនដែលត្រឡប់មកពីបរទេស។ ឥឡូវនេះ ខ្ញុំសូមចូលទៅកាន់ប្រធានបទមួយផ្សេងទៀត។

[១៥:០៣:៣៣]

ក្នុងពេលសវនាការនេះ លោកបាននិយាយអំពីអតីតប្រពន្ធរបស់លោក គឺលោកស្រី រ៉ូឡង់ ពិច ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីត្រឡប់មកនិយាយពាក់ព័ន្ធទៅនឹងចម្លើយពីមុនៗរបស់លោក ជាពិសេសគឺឯកសារដែលមានលេខ D154.2។ ឯកសារនេះ គឺជាមតិអត្ថាធិប្បាយទៅលើជីវប្រវត្តិប្រវត្តិរូបបដិវត្តន៍របស់លោក។ ជាភាសាបារាំង គឺ ERN 00290739 ខ្ញុំសូមអានលេខ ERN ជាភាសាបារាំងម្តងទៀត 00290739, ERN ជាភាសាអង់គ្លេស 00826586, ERN ជាភាសាខ្មែរគឺប្រហែលជាពីរទំព័រ 00824637 ទៅដល់ 00824638។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ជូនឯកសារក្រដាសជាភាសាបារាំងដែលជាច្បាប់ដើមជូនលោកសាក្សី ហើយសូមការអនុញ្ញាតបង្ហាញឯកសារភាសាខ្មែរនៅលើអេក្រង់កុំព្យូទ័រ។

សូមលោកមន្ត្រីតុលាការជួយយកឯកសារជូនលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីលោកស្រីមេធាវីយកជូន

សាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សីពិនិត្យ)*

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** ខ្ញុំសូមអានជាភាសាបារាំង គឺទំព័រទី៣៤ ជាទំព័រដែលខ្ញុំចាប់អារម្មណ៍។ លោកសរសេរថា "បទពិសោធន៍អាក្រក់ដូចគ្នានេះដែរ បានកើតឡើងប្រហែលជាពីរបីឆ្នាំមុន -- ក្រោយបានធ្វើឲ្យ ឡូរ៉ង់ ពិច ឈឺចាប់ជាខ្លាំង។ នៅខែតុលា ឆ្នាំ៧៥ ឡូរ៉ង់ ត្រូវបានគេបណ្ដេញចេញពីសិក្ខាសាលាមួយដែលរៀបចំឡើងសម្រាប់សមាជិកនៃរណសិរ្សរួបរួមជាតិកម្ពុជា ដែលទើបតែនឹងមកពីប្រទេសចិន ប៉ុន្តែលើកនេះការចេញបញ្ជាគឺមកពី ខៀវ សំផន។ យើងអាចយល់ថាច្បាស់ថា ឡូរ៉ង់ មានហេតុផលគ្រប់គ្រាន់ក្នុងការរក្សានូវគំនិតគុំកួនយ៉ាងស្រួចស្រាវ ចំពោះមេដឹកនាំខ្មែរក្រហម"។

[១៥:០៦:៣៨]

លោកសាក្សីសំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងថា តើលោកមានវត្តមានដែរឬទេ នៅក្នុងសិក្ខាសាលារបស់រណសិរ្សរួបរួមជាតិកម្ពុជានេះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** កាលនោះ ខ្ញុំមិនមានវត្តមាននៅក្នុងបរិវេណនោះទេ ប៉ុន្តែខ្ញុំចាំបានថា ខ្ញុំស្ថិតនៅខាងក្រៅៗសាលានោះបាទ។

**ស៖** ប្រសិនបើលោកមិនមានវត្តមាននៅក្នុងសិក្ខាសាលានោះទេ ហេតុអីបានជាលោកអាចនិយាយថា ការសម្រេចបណ្ដេញចេញនេះ គឺជាការបញ្ជាចេញមកពី ខៀវ សំផន នោះ តើជាលោកស្រី ឡូរ៉ង់ ពិច ឬជាអ្នកនិយាយរឿងនេះប្រាប់លោក?

[១៥:០៧:៥៨]

**ឆ៖** កាលនោះ ខ្ញុំនៅមាត់ទ្វារកន្លែងដែលគេប្រជុំហ្នឹង ហើយខ្ញុំនៅជាមួយលោក ទន់ជាតិ សារិន ជាមិត្តភក្តិរបស់ខ្ញុំ ដែលគាត់ជាអ្នកគ្រប់គ្រងសិក្ខាសាលាហ្នឹង។ ហើយខ្ញុំឃើញ ឡូរ៉ង់ ពិច ហ្នឹងគាត់ចេញមកពីក្នុងសាលហ្នឹងដោយទឹកភ្នែករហេមរហាម ហើយទាំងខ្ញុំ ទាំង ទន់ជាតិ សារិន ដែលជាមិត្តជិតស្និទ្ធរបស់ខ្ញុំនៅក្នុងវង់ ម៉ាក្ស-ឡេនីន ហ្នឹង ខំលួងលោមគាត់បាទ។

**ស៖** សូមអរគុណ ចំពោះការបញ្ជាក់បំភ្លឺនេះ។ សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងថា តើអ្នកណាជាអ្នកប្រាប់លោកថា សេចក្ដីសម្រេចបណ្ដេញ ឡូរ៉ង់ ពិច ចេញពីសិក្ខាសាលានោះ ចេញពី ខៀវ សំផន នោះ?

តើអ្នកណាជាអ្នកប្រាប់លោក ដូចដែលលោកបានសរសេរនៅក្នុងឯកសារមួយនេះ?

[១៥:០៩:១៩]

**ឆ៖** អត់មានអ្នកណាប្រាប់ទេ ព្រោះពេលនុ៎ងគឺថា លោក ខៀវ សំផន ជាអ្នកឧទ្ទេសនាមក្នុងសិក្ខាសាលាហ្នឹង។ ដូច្នោះ មានអ្នកណាសម្រេចថា នឹងមិនឲ្យគាត់ -- មិនឲ្យ ឡូវ៉ង់ ពិច ចូលរួមមានតែប្រធានហ្នឹងហើយ ដូច្នោះចាំបាច់នរណាប្រាប់ខ្ញុំបាទ។

**ស៖** ប្រសិនបើ ខ្ញុំយល់មិនច្រឡំទេ គឺជាការសន្និដ្ឋានរបស់លោកមែនទេ?

**ឆ៖** បាទ ជាការសន្និដ្ឋានបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមចូលទៅប្រធានបទមួយទៀត។ ជាច្រើនលើកច្រើនសាលោកបានឆ្លើយនៅចំពោះមុខអង្គសវនាការ ពាក់ព័ន្ធទៅនឹងសញ្ញាណនៃការរក្សាការសម្ងាត់ ហើយលោកបញ្ជាក់ថា គឺថាត្រូវគិតទៅលើការងារខ្លួនឯងទៅ កុំគិតទៅលើរឿងរបស់អ្នកដទៃ។ តើលោកអាចបញ្ជាក់ជូនតុលាការបានទេថា គោលការណ៍រក្សាការសម្ងាត់បែបនេះចេញមកពីណាដែរ?

[១៥:១០:៥០]

**ឆ៖** គោលការណ៍រក្សាការសម្ងាត់របៀប គឺថាជាគោលការណ៍ដ៏សំខាន់មួយរបស់បក្សកុម្មុយ-នីស្តកម្ពុជាបាទ គឺបក្សកុម្មុយនីស្តកម្ពុជាតែងតែអប់រំយើងខ្ញុំថា បើយើងរក្សាការសម្ងាត់បាន ទុកដូចជាយើងទទួលជ័យជម្នះបាន ៥០ភាគរយដែរបាទ។

**ស៖** ហើយជាក់ស្តែងនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោក ជាប្រធានផ្នែកនៅក្រសួងការបរទេស តើលោកមានធ្វើការជ្រើសសម្រាំងព័ត៌មាន ដែលលោកផ្តល់ទៅសហការី ឬក៏អ្នកនៅក្រោមបង្គាប់របស់លោកទេ?

**លោក សួង ស៊ីគឿន៖**

លោកប្រធាន សូមឲ្យលោកមេធាវី -- អ្នកស្រីមេធាវីបញ្ជាក់នូវសំណួរឲ្យច្បាស់បន្តិចបាទ។

**ស្ទួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** មិនជាបញ្ហាអ្វីទេលោកសាក្សី ខ្ញុំអាចបញ្ជាក់ម្តងទៀតបាន។ លោកទើបតែនិយាយអំពីសារៈសំខាន់នៃគោលការណ៍រក្សាការសម្ងាត់។ អ្វីដែលខ្ញុំចង់ដឹងនោះ ថាតើលោកយកទៅអនុវត្តដែរឬទេ នៅក្នុងក្របខ័ណ្ឌការងាររបស់លោកនៅក្នុងក្រសួងការបរទេសនោះ? ថាមានព័ត៌មានមួយចំនួនដែលលោករក្សាទុកតែខ្លួនឯង ហើយលោកមិនប្រាប់អ្នកដទៃ ដូចជាសហការីរបស់លោក ឬក៏មិនប្រាប់ទៅ

អ្នកនៅក្រោមបង្គាប់របស់លោកទេ តើអ៊ីចឹងមែនទេ?

[១៥:១២:៤៥]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំអាចថា ការដែលផ្ដល់ព័ត៌មានដល់អ្នកណាម្នាក់ ជាពិសេសចំពោះអ្នកនៅថ្នាក់ក្រោម គឺអាហ្នឹងប្រាកដជាមានហើយបាទ។ ក៏ប៉ុន្តែតាមគោលការណ៍របស់បក្ស ក្នុងឋានៈជាបក្ខជន យើងមិនត្រូវលាក់ព័ត៌មានដែលយើងដឹងចំពោះអ្នកដែលជាអ្នកដឹកនាំ ឬអ្នកទទួលខុសត្រូវរបស់យើងផ្ទាល់ទេបាទ។ យើងត្រូវតែប្រាប់ លាតត្រដាងព័ត៌មាននោះជូនដល់អ្នកទទួលខុសត្រូវរបស់យើង។ នេះជាសក្ខីកម្មមួយអំពីភក្ដីភាពរបស់យើងចំពោះបក្សកុម្មុយនីស្តបាទ។

**ស៖** លោកសាក្សី សំណួរខ្ញុំគឺចង់ដឹងអំពីសហការី និងកូនចៅ -- និងអ្នកនៅក្រោមបង្គាប់លោកទេ មិនមែនសំដៅទៅលើថ្នាក់លើទេ។

**ឆ៖** ចំពោះរឿងនេះ ខ្ញុំអាចឆ្លើយបានថា ជាគោលការណ៍ទូទៅ គឺខ្ញុំត្រូវតែលាក់ព័ត៌មានខ្លះដែលជាក្របខ័ណ្ឌរបស់អ្នកទទួលខុសត្រូវ។ មិនអាចនឹងផ្សាយឲ្យអ្នកនៅពីខាងក្រោមយើងបានដឹងទេណា។ ក៏ប៉ុន្តែអានេះជាគោលការណ៍ ក៏ប៉ុន្តែជាជាក់ស្ដែងខ្ញុំមិនបានចាំច្បាស់លាស់ទេបាទ។

[១៥:១៤:៤៧]

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ នៅពេលឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកបានបញ្ជាក់ថា លោកបានធ្វើជាអ្នកបកប្រែឲ្យលោក ខៀវ សំផន។ ជាអាទិ៍នៅក្នុងក្របខ័ណ្ឌនៃការទទួលស្គាល់អ្នកការទូតបរទេស។ ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺលោកធ្វើជាអ្នកបកប្រែជាភាសាបារាំង។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោក -- លោក ខៀវ សំផន គាត់និយាយភាសាបារាំងបានល្អណាស់។ អ៊ីចឹងតើមានហេតុផលអីបានជាត្រូវការលោកឲ្យទៅបកប្រែបារាំងឲ្យគាត់ទៅវិញនោះ? តើវាជាលក្ខខណ្ឌពិធីការ ឬក៏មានមូលហេតុអីផ្សេងទៀតដែលឲ្យលោកទៅធ្វើជាអ្នកបកប្រែនោះ?

**ឆ៖** តាមខ្ញុំយល់ គឺភាសាខ្មែរជាភាសារបស់ជាតិ របស់រដ្ឋ។ ដូច្នេះក្នុងការទាក់ទងជាផ្លូវការជាមួយនឹងបរទេស យើងជាខ្មែរ យើងត្រូវប្រើភាសាខ្មែរបាទ។ នេះជាគោលការណ៍មួយចម្បងរបស់កម្ពុជាប្រជាធិបតេយ្យ។ ក៏ប៉ុន្តែមិនមានន័យថា ឧបមាថា ខ្ញុំបកប្រែទៅវាខុស ន័យដែលគេនិយាយនោះ ហើយលោក ខៀវ សំផន ដែលគាត់ចេះស្ដាប់ភាសាបារាំងដែរ គាត់មិនកែខ្ញុំ មិនមែនមានន័យអ៊ីចឹងទេ។ ក្នុងករណីដែលខ្ញុំបកខុស ឬបកមិនចំពាក្យ គឺគាត់មានសិទ្ធិកែប្រែដែរបាទ។

[១៥:១៦:៥៦]

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំចំពោះចម្លើយរបស់លោកទេ គឺលោកចង់មានន័យថា សម្រាប់ជានិមិត្តរូបនោះ គឺគាត់និយាយភាសាខ្មែរ ព្រោះថាភាសាខ្មែរ ជាភាសារដ្ឋ ទោះបីជាមានអ្នកការទូតបារាំងក៏ដោយ ក៏គាត់ត្រូវតែនិយាយជាភាសាខ្មែរដែរ។ តើនេះជាអ្វីដែលខ្ញុំយល់ច្បាស់អំពីចម្លើយរបស់លោកទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា នេះជាគោលការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ឲ្យប្រើភាសាខ្មែរ ជាភាសារបស់ជាតិ។ ក៏ប៉ុន្តែមិនមានន័យថា អ្នកដឹកនាំដែលចេះភាសាបរទេសណាមួយមិនប្រើភាសាហ្នឹងទេ។ ឥឡូវខ្ញុំលើកឧទាហរណ៍មួយជាក់ច្បាស់ គឺខ្ញុំធ្លាប់បានទៅបកប្រែជូនបង នួន ជា ដែលគាត់ទទួលឯកអគ្គរដ្ឋទូតប្រទេសឡាវ។ ប្រទេសឡាវ ទូតឡាវ គាត់និយាយជាភាសាឡាវ ខ្ញុំបកជាបារាំង។ ក៏ប៉ុន្តែលោក នួន ជា គាត់ចេះភាសាថៃ គាត់ស្តាប់ឡាវបាន។ ដូច្នេះ គាត់ថា មិត្តមិនបាច់បកប្រែទេ ខ្ញុំនិយាយត្រង់ទៅវិញ។ ឃើញទេ! អានេះជាឧទាហរណ៍មួយ ថាក្នុងការអនុវត្តជាក់ស្តែងមិនមែនស្តាប់ក្រឡាដូច្នោះទេបាទ។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំចំពោះសក្ខីកម្មរបស់លោកទេ គឺលោកចង់បញ្ជាក់ថា មេដឹកនាំនិយាយភាសាបរទេស ឬក៏មិននិយាយក៏ដោយ ត្រូវតែមានអ្នកបកប្រែទៅជាមួយ។ តើអ៊ីចឹងមែនទេ ឬក៏ខ្ញុំយល់ច្រឡំទេ?

[១៥:១៩:០៩]

**ឆ៖** បាទ ធម្មតា គឺអ្នកដឹកនាំរដ្ឋ ឬអ្នកដឹកនាំបក្សទៅជួបនឹងភ្ញៀវបរទេស វាត្រូវមានអ្នកបកប្រែខាងភាគីកម្ពុជា។ ព្រោះខាងគេ ជួនកាលដូចឧបមាថា យើងទាក់ទងជាមួយវៀតណាម ជាមួយឡាវ ឬជាមួយចិនអី គេក៏មានអ្នកបកប្រែខាងគេដែរ។ គេបកប្រែដូចថា វៀតណាម គេបកប្រែ មានអ្នកចេះភាសាខ្មែរ ហើយខាងចិន ក៏មានចិនអ្នកបកប្រែចិន គេចេះភាសាខ្មែរ។ ដូច្នោះវា អាហ្នឹងជាទម្លាប់ក្នុងការទាក់ទងខាងផ្លូវទូតអ៊ីចឹងបាទ។

**ស៖** សូមអរគុណ ចំពោះការបញ្ជាក់ចំណុចនេះលោកសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវនេះ ខ្ញុំចង់សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារមួយទៀតជូនលោកសាក្សី។ ឯកសារនេះគឺជាកំណត់ហេតុថ្ងៃទី៦ ឧសភា ឆ្នាំ២០០៩ ដែលមានលេខ E3/42 ឬក៏

D167។ ឃ្លាដែលខ្ញុំចង់យកមកសួរនោះ គឺនៅ ERN ជាភាសាបារាំង 00327226, ERN ជាភាសាអង់គ្លេស 00327216, ERN ជាភាសាខ្មែរ 00327205។

ខ្ញុំសូមជំនួយពីមន្ត្រីតុលាការ ដើម្បីផ្តល់ឯកសារជាក្រដាសជូនលោកសាក្សី ដើម្បីឲ្យគាត់ពិនិត្យមើលឲ្យបានងាយស្រួល។

[១៥:២១:២៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ជាក្រដាសពីលោកស្រីមេធាវី យកជូនសាក្សីពិនិត្យ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី តើលោកឃើញទំព័រ ដែលខ្ញុំចង់អានហើយឬនៅ? បន្តិចទៀតនេះ ខ្ញុំនឹងអានឃ្លាដែលខ្ញុំចង់យកមកសួរលោក។ នេះគឺជាចម្លើយលើកទី២ ដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនៅពេលនោះអ្នកស៊ើបអង្កេត សុំឲ្យលោកធ្វើអត្ថាធិប្បាយទៅលើជីវប្រវត្តិរបស់លោក ដែលក្នុងនោះលោកមាននិយាយអំពីលោក ខៀវ សំផន។ ហើយលោកបានឆ្លើយទៅនឹងអ្នកស៊ើបអង្កេតថា "អ្វីដែលខ្ញុំបានសរសេរ ទាក់ទងនឹងសម័យនោះ ខ្ញុំបានស្គាល់ ខៀវ សំផន នៅប៉ារីស។ គាត់ត្រូវបានគេស្គាល់ ល្បីឈ្មោះដោយសារតែមានគុណភាព ជាមនុស្សរបស់គាត់។ គាត់គួរសម និងសាមញ្ញ ជាជាងការប្រឡូកក្នុងនយោបាយរបស់គាត់។ គាត់ត្រូវបានខ្មែរក្រហមចាត់ទុកថាជាកម្លាំង តាក់ទិក ឬក៏យុទ្ធវិធី ច្រើនជាងកម្លាំងយុទ្ធសាស្ត្រ"។ ខ្ញុំចង់សួរលោកថា តើលោកអាចពន្យល់ភាពខុសគ្នាបានទេ រវាងកម្លាំងយុទ្ធវិធីនិងកម្លាំងយុទ្ធសាស្ត្រ? ហើយតើកម្លាំងទាំងពីរនេះ មានន័យថាយ៉ាងម៉េច ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន នៅក្នុងចម្លើយរបស់លោកក្នុងឯកសារមួយនេះនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** កម្លាំងជាយុទ្ធវិធី គឺវាទាក់ទងនឹងបញ្ញាជន ជារួមទាំងអស់ ជាពិសេសបញ្ញាជន ដែលបានទៅរៀនសូត្រនៅប្រទេសបារាំង ហើយជាពិសេសគឺ បញ្ញាជនដែលបានចូលរួមក្នុងបក្ស អ៎! ក្នុងវង់ម៉ាក្ស-ឡេនីន។ គឺបក្សកុម្មុយនីស្តកម្ពុជាពេលនោះ ត្រូវការបញ្ញាជនទាំងនេះ ដើម្បីជាដូចថា ជាមុខមាត់ ហើយជាកម្លាំងប្រមូលមហាជនធំទូលាយ ពិសេសគឺថា បញ្ញាជន និស្សិត សិស្សសាលាទូទៅ ព្រោះពេលនោះជាការជាក់ស្តែងមួយ គឺបញ្ញាជនដែលគេហៅថា "បញ្ញាជនក្រហម" ហ្នឹង ច្រើនជាអ្នកដែល

ពូកែខាងការរៀនសូត្រ ហើយមានចរិតស្លូតបូត ដឹងចាស់ដឹង -- ដឹងចាស់ទុំ ហើយមានចិត្តទូលាយ ជួយអាសាអ្នកផងទាំងពួង សិស្ស និស្សិតផងទាំងពួង។ ដូច្នេះកម្លាំងនេះជា គេហៅថាកម្លាំងបញ្ញេះ ជាកម្លាំងជំនួយ ក៏ប៉ុន្តែមិនមែនជាកម្លាំងយុទ្ធសាស្ត្រទេ ព្រោះកម្លាំងយុទ្ធសាស្ត្រ លុះត្រាតែពួកនេះចូលមកលត់ដំប្រឡូកនៅក្នុងសភាពការណ៍បដិវត្តន៍ជាក់ស្ដែងនៅក្នុងប្រទេស ប្រែក្លាយធាតុជាអនុធនមកជាឲ្យមានធាតុជាអធន ធាតុជាកម្មករបាទ។ ហើយកម្លាំងយុទ្ធសាស្ត្រនេះ គឺជាកម្លាំងដែលនៅជាមួយបដិវត្តន៍ជារៀងរហូត គឺតាមបក្សកុម្មុយនីស្តកម្ពុជា ជំពូកជនណាដែលបានអប់រំ លត់ដំខ្លួន មានទស្សនៈអធន ដូចជាកម្មករ។ នេះគឺមានធាតុជាកម្មករបាន អាចប្រែខ្លួនទៅជាកម្លាំងយុទ្ធសាស្ត្រយូរអង្វែង។

[១៥:២៦:៤២]

**ស៖** សូមអរគុណចំពោះការពន្យល់បំភ្លឺរបស់លោក។ ខ្ញុំសូមសួរបន្តដដែល គឺនៅទំព័រដដែលនៃចម្លើយរបស់លោក។ បន្ទាប់មកទៀតលោកនិយាយអំពីលោក ខៀវ សំផន ដដែល "គាត់ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ព្រោះគាត់បានបំពេញលក្ខខណ្ឌមួយចំនួន។ គាត់ជាបណ្ឌិតសេដ្ឋកិច្ច គាត់នឹងធឹង និងហ្មត់ចត់។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៥ មក គាត់ដើរតួនាទីដែលមានតែឈ្មោះទេ គាត់ធ្វើអ្វីដែលបក្សប្រាប់ឲ្យគាត់ធ្វើ ហើយគាត់មិនស្ថិតនៅក្នុងចំណោមមេដឹកនាំ ដែលកាន់អំណាចពិតប្រាកដទៀតហើយ ផ្ទុយពីសមាជិកនៃគណៈអចិន្ត្រៃយ៍បក្ស"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាមានបទពិសោធន៍អ្វីខ្លះដែលលោកបានជួបប្រទះ លោកបានឃើញអ្វីខ្លះ ដែលអនុញ្ញាតឲ្យលោកបញ្ជាក់អះអាងបែបនេះនោះ? ដែលលោកបានអះអាងថា ខៀវ សំផន គាត់មានតួនាទីមានតែឈ្មោះ។ តើលោកអាចបញ្ជាក់អំពីចំណុចនេះបានទេ?

[១៥:២៨:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ គឺមានបញ្ហាពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការសួរ។ សំណួរ -- ចម្លើយត្រូវបានអានហើយ ប៉ុន្តែឃ្លាចុងក្រោយត្រូវបានកាត់ចោល ក៏ប៉ុន្តែគឺឃ្លានេះគឺថា ផ្ទុយពីសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ដូចជា នួន ជា និង អៀង សារី។ សុំឲ្យមេធាវីការពារក្ដីអានចម្លើយ

ទាំងស្រុង មិនត្រូវយកកាត់យកមកចំណុចដែលខ្លួនពាក់ព័ន្ធ ហើយទុកចោលនូវចំណុចមួយចំនួនដែលវាពាក់ព័ន្ធនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំភ្ញាក់ផ្អើលណាស់ចំពោះអន្តរាគមន៍របស់លោកសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។ អ្វីដែលខ្ញុំធ្វើនោះ គឺថាកាលពីប៉ុន្មានថ្ងៃមុននោះក៏ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គាត់អានតែមួយផ្នែកនៃសៀវភៅរបស់សាក្សីមុនដែរ។ គឺគាត់ផ្តោតចំណាប់អារម្មណ៍របស់គាត់តែទៅលើចំណុចដែលខ្លួនចាប់អារម្មណ៍ ទៅចំណុចដែលខ្លួនចង់សួរសំណួរ។ ដូច្នេះពេលនោះ ខ្ញុំមិនឃើញសហព្រះរាជអាជ្ញាឡើងមកជំទាស់ទេ។ ហើយឥឡូវនេះនៅពេលដែលខ្ញុំធ្វើបែបនេះដូចគ្នាដែរ ខ្ញុំសួរសាក្សីទៅលើចំណុចដែលខ្ញុំពាក់ព័ន្ធដែរ លោកសហព្រះរាជអាជ្ញាងើបឈរជំទាស់។

[១៥:២៩:៣៩]

ហើយប្រសិនបើលោកមានចាប់បំណងសួរអ៊ីចឹង លោកក៏អាចធ្វើបាននៅពេលដែលលោកសួរសំណួរនោះ មិនចាំបាច់មកជំទាស់អ៊ីចឹងទេ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យលោកសាក្សីឆ្លើយតបទៅនឹងសំណួរនេះ ឲ្យគាត់ពន្យល់ឲ្យបានច្បាស់ ថាគាត់ផ្អែកទៅលើអ្វីខ្លះ បានជាគាត់អាចប៊ាននិយាយថា ខៀវ សំផន មានតួនាទី -- មានតែឈ្មោះនោះ? ខ្ញុំសូមសង្កត់ធ្ងន់ទៅលើបទពិសោធន៍ផ្ទាល់របស់លោក ដែលលោកបានជួបប្រទះ? ពីព្រោះថាកាលពីសំណួរលើកមុនៗនោះ យើងបានសង្កត់ធ្ងន់ទៅលើបទពិសោធន៍ដែលលោកបានជួបប្រទះហើយ។ ដូច្នេះអានេះគឺជាចំណុចដែលខ្ញុំចង់បាននៅចំពោះមុខអង្គជំនុំជម្រះនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មិនសមស្របទេ។ សាក្សីឆ្លើយតបនឹងសំណួរដែលសួរ ដោយលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន អម្បាញ់មិញនេះ។

[១៥:៣០:៤៩]

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា នៅពេលនោះយើងខ្ញុំទាំងអស់គ្នាក្នុងឋានៈជាបក្ខជន ដែលបានទទួលការអប់រំនៅក្រៅប្រទេស ហើយជាពិសេសនៅប្រទេសដែលធ្លាប់ជាអាណានិគមនិយមរបស់យើង។ យើងយល់ច្បាស់ថាទស្សនៈ គោលជំហររបស់យើង របៀបរស់នៅរបស់យើង ជាឧបសគ្គដល់ការ ដល់ឋានៈ

យើងជាបក្ខជន។ ដូច្នោះយើងមិនមានជំទាស់ ឬមិនមានតូចចិត្តអ្វីទេនៅពេលនោះ ដែលបក្សកុម្មុយនីស្តកម្ពុជាទុកយើងជាកម្លាំងយុទ្ធសាស្ត្រ យើងសូមតែបម្រើជាតិទេ ព្រោះពេលដែលយើងចូលមកក្នុងធ្វើបដិវត្តន៍ចូលមកក្នុងបក្ស យើងបានប្ដេជ្ញាចិត្តច្បាស់លាស់ណាស់ ថានឹងជូនជីវិតរបស់យើង លះបង់អ្វីៗទាំងអស់ ដើម្បីបក្ស ដើម្បីបដិវត្តន៍ និងដើម្បីប្រជាជន។ ខ្ញុំមិនដឹងជាបងៗ ឬមិត្តភក្តិយើងខ្ញុំទាំងអស់គ្នាយល់យ៉ាងម៉េចទេ តែចំពោះខ្លួនខ្ញុំច្បាស់ណាស់ ទោះបីជាបក្សវិនិច្ឆ័យថាខ្លួនខ្ញុំជាក្បត់ជាតិក៏ដោយក៏ខ្ញុំព្រមទទួលការវិនិច្ឆ័យរបស់បក្ស ពីព្រោះអី? ពីព្រោះយើងខ្ញុំយល់ថាពេលនោះបក្សមានទស្សនៈច្បាស់លាស់ ត្រឹមត្រូវ មិនដែលវិនិច្ឆ័យលើរូបខ្ញុំផ្ទាល់បានត្រឹមត្រូវជាងរូបខ្ញុំវិនិច្ឆ័យចំពោះរូបខ្ញុំ ពីព្រោះទស្សនៈរបស់ខ្ញុំវាជាទស្សនៈមិនត្រឹមត្រូវ វាទស្សនៈដែលប្រឡាក់ប្រឡូកទៅដោយទស្សនៈរបស់វណ្ណៈជិះជាន់ របស់អាណានិគមនិយម របស់ចក្រពត្តិនិយម។ ដូច្នោះ ខ្ញុំព្រមទទួលការវិនិច្ឆ័យរបស់បក្ស ព្រោះតែជំនឿដ៏ក្លៀវក្លានេះហើយបានជាយើងទទួលបានជ័យជម្នះនៅថ្ងៃទី១៧ មេសា ១៩៧៥។

[១៥:៣៣:០៧]

ហើយចំពោះលោក ខៀវ សំផន ខ្ញុំស្គាល់គាត់ច្បាស់ណាស់ ព្រោះខ្ញុំឃើញថាគាត់ គឺថាបានពន្យល់គោលជំហររបស់គាត់ សេចក្តីប្ដេជ្ញារបស់គាត់ជាបន្តបន្ទាប់មកហើយ។ គាត់មិនទាមទារអ្វី នាទីអ្វីជា ដូចថានាទីដឹកនាំអ្វីធំដុំទេ អានេះគាត់ប្រគល់ខ្លួនរបស់គាត់ទៅឱ្យបក្ស ស្រេចតែបក្សវិនិច្ឆ័យថាគាត់អាចបំពេញភារកិច្ចបានល្អប្រសើរនៅកន្លែងណា? ពីព្រោះអី? ពីព្រោះគាត់ក៏ដូចខ្ញុំដែរ គាត់មានជំនឿពេលនោះគាត់មានជំនឿលើបក្សកុម្មុយនីស្តកម្ពុជា លើការដឹកនាំរបស់បក្ស ហើយការដឹកនាំនេះ ជំនឿនេះនៅពេលនោះ នៅពេលមុន៧៥ គឺថាបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចសមិទ្ធិផលយ៉ាងសន្ធោសន្ធៅដែលធ្វើឱ្យខ្ញុំទាំងអស់គ្នាមានការកត់ក្ដៅ ហើយមានជំនឿ។ ដូច្នោះ ខ្ញុំមិនមានអីពន្យល់ទេ មានឧទាហរណ៍ច្រើនណាស់ដែលខ្ញុំអាចពន្យល់បាន ដូចខ្ញុំថ្ងៃមុនអ៊ីចឹងគឺថា ដែលខ្ញុំនិយាយជម្រាបអង្គប្រជុំថា ពេលព្រឹកខ្ញុំទៅបកប្រែជូនលោក ខៀវ សំផន ក្នុងឋានៈលោកជាប្រធានគណៈប្រធានរដ្ឋ ដែលទទួលសារតាំងពីឯកអគ្គរដ្ឋទូតប្រទេសអាល់បានី ដល់ថ្ងៃរសៀល ថ្ងៃដដែលហ្នឹង ខ្ញុំទៅបកប្រែឱ្យគ្រូពេទ្យរបស់ក្រសួងទៅមើលប្រពន្ធឯកអគ្គរដ្ឋទូតអាល់បានីនោះ។ មានន័យថា លោកស្រីមេធាវីមានន័យថា ឋានៈរបស់លោក ខៀវ សំផន គឺស្មើនឹងឋានៈរបស់ពេទ្យសាមញ្ញធម្មតារបស់ក្រសួង។ នេះ អាហ្នឹងឧទាហរណ៍ហ្នឹង គឺច្បាស់ក្រឡែតហើយ។ មានឧទាហរណ៍ផ្សេងទៀតដែលខ្ញុំមិនបានចាំទេពេលនេះបាទ។ សូមអស់។

[១៥:៣៥:២៩]

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបញ្ជាក់លោកសាក្សី។ ក្រៅពីមុខងារជាអ្នកទទួលអ្នកការទូតបរទេសនេះ តើគាត់មានមុខងារផ្សេងទៀតដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** ខ្ញុំចង់អានសម្រង់មួយទៀត នូវចម្លើយរបស់លោក លោកបានជម្រាប -- នៅទំព័រ៥ដដែល ហើយលេខយោងដូចគ្នាដដែល គឺសំណួរបន្ទាប់ទៀតតែប៉ុណ្ណោះ។ នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត ដែលសួរលោក "តើលោកមានទំនាក់ទំនងអ្វីខ្លះជាមួយ ខៀវ សំផន នៅចន្លោះឆ្នាំ៧៥ ដល់៧៩ នុ៎ង" លោកឆ្លើយដូចតទៅនេះ៖ "ខ្ញុំធ្លាប់ជួបគាត់ជាអាទិ៍នាពេលដែលគាត់ទទួលលិខិតសារតាំងអំពីឯកអគ្គរដ្ឋទូតបរទេស ប៉ុន្តែខ្ញុំមិនដែលមានការជជែកពិភាក្សាល្អិតៗនោះទេ ពីព្រោះគាត់រវល់ការងារផ្សេងទៀត ឧទាហរណ៍ដូចជា *កុំម៉ង់* ទិញថ្នាំពីបរទេស ឬក៏គ្រឿងបន្លាស់...។ល។" សំណួរខ្ញុំទាក់ទៅនឹងផ្នែកនេះ នៅចម្លើយរបស់លោកគឺចង់ដឹងថា តើលោកដឹងថាគាត់ទទួលបន្ទុកផ្សេងៗទៀតហ្នឹង ដូចជា ទិញថ្នាំ ឬក៏គ្រឿងបន្លាស់នេះ តាមរបៀបណាដែរ?

[១៥:៣៧:៤២]

**ឆ៖** ខ្ញុំដឹងថា គាត់ទទួលទិញគ្រឿងបន្លាស់ហ្នឹង គឺថាខ្ញុំមានមិត្តភក្តិម្នាក់ ប៉ុន្តែឥឡូវគាត់ទទួលអនិច្ចកម្មហើយ គាត់ឈ្មោះ វ៉ាន់ រិទ្ធ។ គាត់ទទួលអនិច្ច -- គាត់ទទួលប្រធានគណៈកម្មាធិការពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ។ មានន័យថា គាត់ជារដ្ឋមន្ត្រីពាណិជ្ជកម្មក្រៅប្រទេស គាត់បានប្រាប់ខ្ញុំដែលខ្ញុំដឹងតាមរយៈគាត់ទេបាទ។

**ស៖** បាទ សូមអរគុណដែលបានបំភ្លឺ។ ខ្ញុំសូមបន្តនូវកថាខណ្ឌដដែល ហើយនេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោកឆ្លើយថា៖ "ក្រោយមកទៀត ខ្ញុំបានរស់នៅជាមួយគាត់ និង ប៉ុល ពត គឺឆ្នាំ៨១ និង៨២ ហើយខ្ញុំអាចសង្កេតឃើញថា គាត់មិនមានតួនាទីអ្វីនោះទេ នៅក្នុងការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីរបស់បក្ស គឺ ប៉ុល ពត ជាអ្នកសម្រេចទាំងអស់។ ត្រង់ចំណុចនេះដដែលលោកសាក្សី តើវាជាចម្លើយដែលលោកផ្តល់ជូនដោយសារលោកធ្លាប់បានឆ្លងកាត់រឿងទាំងអស់នេះ ហើយលោកអះអាងយ៉ាងដូច្នេះនេះ ដោយឈរលើមូលដ្ឋានអ្វី? យោងជាភាសាខ្មែរគឺ 00327206។

[១៥:៣៩:២៥]

**ឆ៖** ចំពោះបញ្ហាហ្នឹងខ្ញុំច្បាស់ណាស់ ព្រោះពេលនៅឆ្នាំ១៩៨១ និង១៩៨២ ខ្ញុំជាអ្នកតំណាង

កម្ពុជាប្រជាធិបតេយ្យចរចាដើម្បីបង្កើតរដ្ឋាភិបាលត្រីភាគីជាមួយនឹងភាគីសម្តេច នរោត្តម សីហនុ ហើយនិងភាគីរបស់ឯកឧត្តម សឺន សាន។ ខ្ញុំជាអ្នកធ្វើដំណើរពីមន្ទីររបស់គណៈមជ្ឈិមបក្សកុម្មុយនីស្ត កម្ពុជានៅពេលនុ៎ង គេហៅថា “ច្រក៥០៥” ហើយទាំងបាងកក។ ដូច្នេះ ឯកសារចរចា សេចក្តីសម្រេច យ៉ាងណានេះហ្នឹង គឺថាខ្ញុំមកវិញ ខ្ញុំរាយការណ៍ប្រាប់លោក ប៉ុល ពត ហើយគាត់បានណែនាំខ្ញុំផ្ទាល់ ឲ្យទៅ ខ្លឹមសារចរចាជាមួយភាគីពីរផ្សេងទៀតនៅបាងកកហ្នឹង ហើយលោក ខៀវ សំផន គាត់ស្នាក់ ជិតនុ៎ងដែរ ប៉ុន្តែខ្ញុំមិនឃើញលោក ប៉ុល ពត ហ្នឹងហៅ ខៀវ សំផន ហ្នឹងមកប្រជុំម្តងទេ អាហ្នឹងគឺថា ច្បាស់អ៊ីចឹងតែម្តង។

បាទ គឺថាគាត់ ប៉ុល ពត ហ្នឹងគាត់សម្រេចខ្លួនគាត់តែម្នាក់ឯង ហើយគាត់ណែនាំឲ្យខ្ញុំនាំការ ណែនាំហ្នឹងទៅគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យនៅឯបាងកកនោះបាទ។ ព្រោះខ្ញុំធ្វើដំណើរចុះឡើងៗ ម្តង២ថ្ងៃៗ រហូតដល់ការចរចាហ្នឹងសម្រេចបានជា នៅសាំងហ្គាពួរ នៅសិង្ហបុរី នៅថ្ងៃ០៤ ខែតុលា ឆ្នាំ១៩៨១ បង្កើតជាសម្ព័ន្ធភាពត្រីភាគីរវាងកម្ពុជាប្រជាធិបតេយ្យ រវាងកម្លាំងរបស់សម្តេច នរោត្តម សីហុន និងកម្លាំងរបស់ឯកឧត្តម សឺន សាន បាទ។

[១៥:៤១:៥២]

**កញ្ញា អង់តា ហ្គីសសេះ**

លោកសាក្សី ខ្ញុំសូមអរគុណជាអនេកប្បការ ដែលបានឆ្លើយតបនឹងសំណួររបស់ខ្ញុំ ហើយលោក ប្រធានខ្ញុំសូមបញ្ចប់ការចោទសំណួរទៅសាក្សីត្រឹមនេះតែម្តងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមវេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បី មានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងជម្រាបសួរ លោកសាក្សីដែលលោកបានអញ្ជើញមកថ្ងៃនេះ។ ខ្ញុំយល់ថា គឺជាការរង់ចាំយូរហើយសម្រាប់លោក ហើយខ្ញុំសូមសរសើរដោយលោកបានចំណាយពេលថ្ងៃនេះ ដើម្បីទទួលសំណួរមួយចំនួន និងឆ្លើយមួយ ចំនួន។

[១៥:៤២:៤៧]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សំណួរទី១របស់ខ្ញុំចំពោះលោក គឺទាក់ទងទៅនឹងប្រភពនៃចំណេះដឹងរបស់លោក។ ជាសំណួរទូទៅទាក់ទងទៅអ្វីដែលលោកបានអាន ចាប់ពីឆ្នាំ១៩៧៩។ សំណួរទី១របស់ខ្ញុំ ចាប់តាំងពីឆ្នាំ១៩៧៩ តើលោកបានអានសៀវភៅណាដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ប្រសិនបើដូច្នេះ សូមឲ្យលោកបញ្ជាក់ឈ្មោះសៀវភៅទាំងនោះផង។

**លោក សួង ស៊ីគឿន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតថា ឲ្យលោកមេធាវីបញ្ជាក់បន្តិច ព្រោះសៀវភៅអានហ្នឹងវាច្រើនដែរបាទ។ ដូច្នេះសុំឲ្យលោកមេធាវីគាត់សួរសំណួរឲ្យបានៗ ដូចថាឲ្យបានច្បាស់បន្តិច កុំទូទៅពេកបាទ។

[១៥:៤៤:០៥]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ខ្ញុំយល់ ហើយខ្ញុំព្យាយាមសួរឲ្យច្បាស់។ តើលោកសាក្សីបានអានសៀវភៅ ដែលនិយាយជាក់លាក់អំពីសម័យពីឆ្នាំ១៩៧៥ ដល់១៩៧៩ ដែរឬទេ នៅពេលដែលខ្មែរក្រហម ជាសៀវភៅដែលនិយាយពីខ្មែរក្រហមកាន់អំណាចនោះបាទ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ជារួមខ្ញុំអានសៀវភៅដែលសំខាន់ៗ។ ជួនកាលខ្ញុំមិនចាំចំណងនៃសៀវភៅហ្នឹងទេបាទ ដូចខ្ញុំបានអានសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ, សៀវភៅលោក ប៊ែន ឃៀរនិន, សៀវភៅលោក ហ្វីលីព ស្សូត ហើយនិងសៀវភៅមួយចំនួនផ្សេងទៀតបាទ។ តែខ្ញុំក្នុងពេលនេះ ខ្ញុំមិនបានចាំទេ។

**ស៖** សូមអរគុណលោកសាក្សី។ នេះជាចម្លើយច្បាស់ ហើយខ្ញុំចង់ឲ្យប្រាកដ លោកទើបតែបញ្ជាក់ថា លោកបានអានសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ, ហ្វីលីព ស្សូត ហើយនិង ប៊ែន ឃៀរនិន។ តើអ៊ីចឹងដែរឬទេបាទ?

**ឆ៖** បាទ អ៊ីចឹងហើយបាទ។

**ស៖** សូមអរគុណ។ តើលោកនៅអានសារព័ត៌មានដែរឬទេ សព្វថ្ងៃនេះ?

**ឆ៖** តាំងពីខ្ញុំវះបេះដូងមក ការអានសារព័ត៌មាន ខ្ញុំមានការលំបាក។ គឺខ្ញុំមិនអាចអានលើសពី១០នាទីទេ ហើយនាំឲ្យខ្ញុំហត់នឿយ។ អ៊ីចឹងខ្ញុំមិនសូវបានអានសារព័ត៌មានទេ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែស្តាប់

វិទ្យុបាទ។

[១៥:៤៦:២២]

**ស៖** នេះហើយជាសំណួរបន្ទាប់របស់ខ្ញុំ។ លោកបាននិយាយអំពីកម្មវិធីផ្សាយវិទ្យុនៅទីនេះ នៅក្នុងតុលាការកាលពីលើកមុននោះ។ ដូច្នេះ សូមលោកបញ្ជាក់ឈ្មោះវិទ្យុណាខ្លះ ដែលលោកបានស្ដាប់បច្ចុប្បន្ននេះបាទ?

**ឆ៖** វិទ្យុ ជារួមគឺថាខ្ញុំស្ដាប់វិទ្យុ FM-102 ហ្នឹងខាងព័ត៌មានស្ត្រីហ្នឹង ព្រោះវិទ្យុហ្នឹងដាក់បន្តផ្ទាល់ទៅវិទ្យុធំៗ ដូចជាវិទ្យុអូស្ត្រាលី វិទ្យុបារាំងអន្តរជាតិ សំឡេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរីបាទ។ ក៏ប៉ុន្តែជាព័ត៌មាន ខ្ញុំតាមដានព័ត៌មានទូរទស្សន៍បាយ័ន, ទូរទស្សន៍ស៊ី.ធី.អិន ហើយទូរទស្សន៍ថ្មីហ្នឹង ស៊ី.អិន.ស៊ី បាទ។ ក្រៅពីទូរទស្សន៍ ប៊ី.ប៊ី.ស៊ី, ទូរទស្សន៍ អេស៊ានញូវ ជាសិង្ហបុរី ហើយនិងទូរទស្សន៍ តេឡេម៉ុងដ៍ ឌីសែង ទូរទស្សន៍បារាំងបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្ដាប់វិទ្យុទាំងនោះ តើលោកបានស្ដាប់របាយការណ៍ដែលផ្សាយអំពីនីតិវិធីរបស់សាលាក្ដីនេះដែរឬទេ?

**ឆ៖** ខ្ញុំបានស្ដាប់តាមដានដែរ ប៉ុន្តែដោយសារបញ្ហាសុខភាព ពេលដែលខ្ញុំស្ដាប់ទៅ វិទ្យុហ្នឹងច្រើននៅពេលយប់ ខ្ញុំក៏ -- ជួនកាលខ្ញុំក៏អស់ហត់ហេវពេក ខ្ញុំក៏សម្រាកលក់ទៅ មិនបានស្ដាប់ចប់ចុងចប់ដើមទេបាទ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយបំភ្លឺបែបនេះ។ ប្រធានបទខុសគ្នាបន្តិចនេះ គឺដូចខាងក្រោមនេះ លោកបានរង់ចាំជាយូរដើម្បីផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយសាក្សីផ្សេងៗទៀត ពេលខ្លះក៏ត្រូវរង់ចាំផងដែរ។ សំណួរជូនលោកនោះ គឺថានៅពេលរង់ចាំក្នុងការផ្ដល់សក្ខីកម្មជូនតុលាការនេះនៅក្នុងអតីតកាលនោះ ១អាទិត្យមុន តើលោកបានជួបអ្នកណាម្នាក់ផ្សេងទៀតដែលផ្ដល់សក្ខីកម្មចំពោះតុលាការនេះដែរឬទេ?

[១៥:៤៩:២០]

**ឆ៖** ខ្ញុំបានជួបន៉េ-- ព្រោះពេលហ្នឹងខ្ញុំនៅម៉ាឡៃ ហើយគាត់មក ពេលដែលគាត់មកផ្ដល់សក្ខីកម្មហ្នឹង គាត់មកមុនខ្ញុំ។ លោក ភី ភួន ដែលខ្ញុំទុកគាត់ដូចជាប្អូនរបស់ខ្ញុំដែរ ព្រោះមានអនុស្សាវរីយ៍ជាមួយគ្នាច្រើន។ ហើយពេលដែលគាត់មកផ្ដល់សក្ខីកម្មហ្នឹង គាត់បានទូរស័ព្ទទៅខ្ញុំ ហើយខ្ញុំក៏សុំជួបគាត់។ គាត់ឲ្យខ្ញុំជួប ប៉ុន្តែខ្ញុំជួបគាត់នៅសណ្ឋាគារ[redacted]ហ្នឹង នៅជិត[redacted]ហ្នឹង។ ហើយពេលនោះ ក៏មាន

តំណាងរបស់អង្គភាពគាំពារសាក្សីដែរ ខ្ញុំមិនចាំគាត់ច្បាស់ទេ ហើយខ្ញុំអត់បាននិយាយអី សួរនាំទេ គ្រាន់ថា ខ្ញុំមិនលាក់លៀមគោលបំណងអីទេ គឺថា ខ្ញុំចង់ជួបគាត់ហ្នឹង ឲ្យដឹងថា តើគេសួរអីពីគាត់ខ្លះ តែប៉ុណ្ណឹងទេបាទ ដើម្បីខ្ញុំត្រៀម ព្រោះខ្ញុំដឹងថា ក្រោយពីគាត់ គឺថាខ្ញុំនឹងមកធ្វើសក្ខីកម្មនៅចំពោះមុខតុលាការនេះហើយបាទ។

[១៥:៥០:៤៧]

**ស៖** សូមអរគុណ ចំពោះចម្លើយពិស្តាររបស់លោក ហើយខ្ញុំនឹងត្រឡប់មកបញ្ហានេះ នៅពេលក្រោយបន្តិចទៀត។ ឥឡូវនេះ ខ្ញុំសូមចូលទៅរកខ្លឹម -- ប្រធានបទមួយដែលមានខ្លឹមសារសំខាន់ គឺនិយាយ អំពីរណសិរ្សរួបរួមជាតិកម្ពុជា ឬរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ខ្ញុំសូមចាប់ផ្តើមការសួរសំណួរចាប់ពីឆ្នាំ១៩៧១ លោកបាននិយាយថា លោកបានក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ១៩៧១។ តើលោកនៅចាំកាលបរិច្ឆេទ ជាក់លាក់ទេបន្ថែមលើឆ្នាំនេះបាទ?

**ឆ៖** បើខ្ញុំមិនច្រឡំទេ គឺដូចមួយថ្ងៃមុន ថ្ងៃកំណើតរបស់សម្តេចព្រះ នរោត្តម សីហនុ ដូចថ្ងៃ ៣០ ខែតុលា បាទ។

**ស៖** លោកបាននិយាយខាងដើមថា ប្រហែល គាត ឈន់ ជាអ្នកគាំទ្រការចូលជាសមាជិករបស់លោក ហើយតើលោកចាំទេ មុខងារ ឬក៏ឋានះរបស់គាត់នៅក្នុងចលនានោះ នៅក្នុងបក្សនៅកាលនោះគាត់ដូចម្តេចដែរ?

**ឆ៖** នៅពេលចូលបក្សហ្នឹង គឺថា គឺមានលោក គាត ឈន់ ហើយនិងលោក ជួន ប្រាសិទ្ធ ជាអ្នកធានា បើតាមគោលការណ៍របស់កុម្មុយនីស្តកម្ពុជា ត្រូវមានអ្នកធានាពីរនាក់។ ដូច្នោះ គាត់ធានាឲ្យខ្ញុំ ហើយគាត់ នៃ លោក គាត ឈន់ ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ពេលដែលនៅពេលនោះដែរ បាទ។

**ស៖** ខ្ញុំយល់ថា លោក គាត ឈន់ ជាសមាជិក នៃបក្សកុម្មុយនីស្តកម្ពុជា តើគាត់មានតួនាទីអ្វីពិសេស? តើគាត់មានតំណែងពិសេសអ្វីក្នុងបក្សទេនៅកាលនោះ?

[១៥:៥៣:០៣]

**ឆ៖** កាលនោះក្នុងបក្សហ្នឹង មិនមានតំណែងអីទេបាទ។ មានតែលោក អៀង សារី គាត់ជាអ្នកប្រធានបក្សហើយ ហើយលេខាបក្សហ្នឹង តាមខ្ញុំដឹងពេលនោះគឺថា គឺលោកស្រី សៀន អាន។ លោក សៀន អាន ជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងហាណូយ ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ គ្រួសារគាត់គឺថាជាលេខារបស់បក្ស។ ខ្ញុំចាំបានតែប៉ុណ្ណឹងទេ អ្នកឯទៀតដូចមិនមានការងារអីច្បាស់

លាស់ទេបាទ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ នៅលើអេក្រង់ គឺឯកសារលេខ D313/1.2.267 អង់គ្លេស ERN 00419033 ដល់ 40, បារាំង ERN 00774451 រហូតដល់ 57, ខ្មែរ ERN 00738357 រហូតដល់ 65។

សូមអនុញ្ញាត ដើម្បីបង្ហាញទំព័រទី១ នៅលើអេក្រង់ ជាភាសាខ្មែរ។ បាទ ហើយៗយើងនឹងជូនឯកសារលើក្រដាសទៅសាក្សី ជាភាសាអង់គ្លេស និងភាសាខ្មែរ។

[១៥:៥៤:៥២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីលោកមេធាវី ដើម្បីយកជូនសាក្សីពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៥:៥៥:១៦]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** នៅពេលដែលលោកសាក្សីអាន ហើយខ្ញុំនឹងពន្យល់ថាតើឯកសារនេះជាទូរលេខរបស់ស្ថានទូតសហរដ្ឋអារដ្ឋអាមេរិកនៅភ្នំពេញ ខែកញ្ញា ៣០ ឆ្នាំ១៩៧១ ជូនទៅរដ្ឋវ៉ាស៊ីនតោន នៅទំព័រទី១។ សេចក្តីផ្តើមនោះ គឺសូមដកស្រង់៖ ទៅខាងក្រោមនេះគឺជាព័ត៌មានរបស់វិទ្យុបរទេស គឺជាឈ្មោះមនុស្សដែលពាក់ព័ន្ធជាមួយនឹង ហ្យុង និង ហ្គ្រុង គឺថាយើងមានព័ត៌មាននិយាយ អំពីលក្ខណៈវិនិច្ឆ័យរបស់អង្គការនេះ។ អ្នកដែលមានសមាជិកលំដាប់ទី២ គឺជាអ្នកប្រឆាំងសម្តេច សីហនុ និងខ្មែរក្រហម និងក្នុងករណីមួយចំនួនទៀតជាក្រុមមិនចំកុម្មុយនីស្ត។ តុល្យភាពទំនាក់ទំនង គឺការចូលរួមជាមួយ សីហនុទៅចូលរួមជាមួយខ្មែរកុម្មុយនីស្ត។ តាមពិតសម្តេច សីហនុ ធ្លាប់បានគ្រប់គ្រង។ ឈ្មោះ៤០នាក់ ដែលបានចុះក្នុងបញ្ជីនេះ យ៉ាងហោចណាស់ក៏មានប្រាំបួននាក់ ក្នុងចំណោម៣៤នាក់ ត្រូវបានគេពិពណ៌នាថាអ្នកឆ្វេងនិយម ពួកឆ្វេងនិយមជ្រុល។ ហើយដូចដែលខ្ញុំចង្អុលបង្ហាញថា គឺថាដែលខ្ញុំបញ្ជាក់សញ្ញាផ្កាយនៅចំពោះឈ្មោះនេះ គឺថាជាចង្អុលបង្ហាញអំពីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ត្រូវធ្វើដំណើរវែងឆ្ងាយដើម្បីគ្រប់គ្រងទាំងស្រុង និងមានឥទ្ធិពលលើពួកនិស្សិតនៅបរទេស។ នេះជាសេចក្តីផ្តើមនៅទូរលេខ

នេះ។ ហើយឥឡូវនេះ ខ្ញុំនឹងចូលទៅដល់ទំព័របន្ទាប់ ដែលមានអត្ថបទជាភាសាអង់គ្លេស លេខ ERN 00419083, ខ្មែរ ERN 00738363។ ហើយសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ។ បន្ទាប់មក នៅក្នុងលេខ៣០ នៃលេខសារទូរលេខនេះ យើងបានឃើញឈ្មោះរបស់លោក លោក ស៊ុីគឿន ហើយ លោកត្រូវបានគេបញ្ជាក់ថា ជាសមាជិកគណៈមជ្ឈិមនៃរណសិរ្សរួបរួមជាតិកម្ពុជា។

[១៥:៥៧:៥១]

សំណួររបស់ខ្ញុំចំពោះលោកគឺដូចខាងក្រោមនេះ។ នេះជាទូរលេខរបស់ស្ថានទូតសហរដ្ឋអាមេរិក នៅភ្នំពេញ ដែលបញ្ជូនទៅ បាទក្រសួងការបរទេសនៅវ៉ាស៊ីនតោន ហើយលោកមិនបានឃើញទូរលេខ នេះពីមុនមកទេ។ សំណួរខ្ញុំសួរទៅលោកនោះ គឺលោក សួង ស៊ុីគឿន តើព័ត៌មាននេះត្រឹមត្រូវដែរឬទេ នៅខែកញ្ញា ឆ្នាំ១៩៧១ តើលោកជាសមាជិករបស់គណៈមជ្ឈិមនៃរណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ?

**លោក សួង ស៊ុីគឿន៖**

**ឆ៖** បាទ ព័ត៌មាននេះត្រូវ។ ខ្ញុំជាសមាជិកគណៈកម្មាធិការកណ្តាលរបស់រណសិរ្សរួបរួមជាតិ កម្ពុជា ហើយខ្ញុំជាលេខានៃគណៈកម្មាធិការកណ្តាលនៃរណសិរ្សរួបរួមជាតិកម្ពុជាបាទ។

**ស៖** សូមអរគុណ។ យើងត្រឡប់ទៅទំព័រពីរបីទៀត ដែលអង់គ្លេស ERN 00419035, ហើយ និងខ្មែរ ERN 00738860។ នៅកន្លែងនេះយើងឃើញលេខ១៣ គឺសូមដកស្រង់៖ "គាត ឈន់ លេខា ធិការ នៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីប្រតិភូរបស់នាយករដ្ឋ មន្ត្រី"។ សំណួររបស់ខ្ញុំចំពោះលោក -- ខ្ញុំរង់ចាំរហូតដល់លោកពិនិត្យឃើញខ្លឹមសារដែលពាក់ព័ន្ធសិន។

សំណួររបស់ខ្ញុំចំពោះលោកនោះ គឺលោក សួង ស៊ុីគឿន សូមទោស សំណួរគឺ តើព័ត៌មាននេះ ត្រឹមត្រូវដែរឬទេនៅខែកញ្ញា ឆ្នាំ១៩៧១ គឺលោក គាត ឈន់ ជាលេខាធិការនៃការិយាល័យនយោបាយ នៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីប្រតិភូរបស់នាយករដ្ឋមន្ត្រីនោះបាទ?

**ឆ៖** បាទ ព័ត៌មានហ្នឹងត្រឹមត្រូវបាទ។

**ស៖** តើលោកអាចពន្យល់ប្រាប់ខ្ញុំបានទេ ថាតើៗការិយាល័យនយោបាយរបស់រណសិរ្សរួបរួម ជាតិកម្ពុជានោះមានមុខងារធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំក៏មិនបានដឹងច្បាស់ដែរ ប៉ុន្តែ ខ្ញុំគ្រាន់តែដឹងថា ដោយសារការិយាល័យនយោបាយនេះ ដែលមានសម្តេច ប៉ែន នុត ជាប្រធាននេះស្ថិតនៅក្រៅប្រទេស។ ដូច្នោះការងារច្រើនជាការងារបរទេស បាទ មិនមានអីទាក់ទងនឹងការងារនៅលើសមរភូមិ ឬការងារជាក់ស្តែងនៅក្នុងប្រទេសទេបាទ។

[១៦:០១:១៤]

**ស៖** ក្នុងឋានៈជារដ្ឋមន្ត្រីប្រតិភូរបស់នាយករដ្ឋមន្ត្រីថា តើដឹងថាតួនាទីរបស់គាត់ធ្វើអ្វីទេលោកសាក្សី?

**ឆ៖** ខ្ញុំឃើញថាតួនាទីរបស់គាត់គឺពេលនុំងច្រើនតែជាតួនាទីតំណាងណ៎ា។ តំណាងទៅទទួលឥស្សរជនណានៅវាលយន្តហោះទៅ ទៅចូលរួមពិធីជប់លៀង ដែលខាងរដ្ឋាភិបាលមិនបានរៀបតាក់តែងអ៊ីចឹងទៅមិនមានអីច្បាស់លាស់ទេបាទ។

**ស៖** សូមអរគុណ--

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលត្រូវសម្រាកហើយ សម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះសម្រេចផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ហើយកិច្ចដំណើរការសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក នៅព្រឹកថ្ងៃពុធ ទី១៥ ខែសីហា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនោះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលសួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក នួន ជា ជាបន្តនៅពេលព្រឹក។ ហើយជាយថាហេតុនៅរសៀលអង្គជំនុំជម្រះអាចស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-609 ដែលនឹងចាប់ផ្តើមដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតបន្ទាប់ពីសំណួរបឋមរបស់អង្គជំនុំជម្រះ។

[១៦:០២:៥៨]

សូមភាគី និងសាធារណជនជ្រាប។

លោក សួង ស៊ីគឿន ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ហើយមេធាវីប្រឹក្សាដូចគ្នានឹងសាក្សីដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃ

ស្អែកឱ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*

ម